**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royalede Droit et des Scienes Économiques**

**Royal university of Law and Economics**


# សារណាបញ្ចប់ការសិក្សា

# ការគ្រប់គ្រងរដ្ឋបាលនៅសង្កាត់ក្បាលកោះ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ (ចាប់ពីឆ្នាំ ២០១៨ ដល់ ឆ្នាំ២០២០)

ស្រាវជ្រាវពីថ្ងៃទី ២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១


| ស្រាវជ្រាវដោយ ៖ | សាស្ត្រាចារ្យណែនាំ |
| --- | --- |
| និស្សិតឈ្មោះ: **កញ្ញា តែម រដ្ឋា** | **បណ្ឌិត ឌឹត សំណាង** |
| **កញ្ញា ស៊ុំ ចាន់ដាវ៉ាន់** | |
| ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ** | ឆ្នាំចូលសិក្សា ២០១៧ |
| ជំនាន់ទី១៤ | ឆ្នាំសរសេរសារណា ២០២១ |

# សេចក្តីថ្លែងអំណរគុណ

ជាបឋមយើងខ្ញុំទាំងពីររូបឈ្មោះ **នែម រដ្ឋា** និង **ស៊ុំ ចាន់ដាវ៉ាន់** ជានិស្សិតជំនាន់ទី១៤ ថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ យើងខ្ញុំទាំងពីរសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ៖

- **លោកអ្នកមានគុណទាំងពីរ** ដែលបានចិញ្ចឹមបីបាច់ថែរក្សាការពារ ទំនុកបម្រុងសព្វគ្រប់បែបយ៉ាង អប់រំ ណែនាំផ្តល់ដំបូន្មានល្អៗ និងបញ្ជូនកូនឱ្យបានរៀនសូត្ររហូតមកដល់សព្វថ្ងៃនេះផ្តល់ទាំងសម្ភារៈ និងកម្លាំងកាយចិត្តដល់រូបយើងទាំងពីរនាក់។
- **ឯកឧត្តមសាកលវិទ្យាធិការក៏ដូចជាសាកលវិទ្យាធិការរង លោកគ្រូ អ្នកគ្រូ និង សាស្ត្រាចារ្យ** គ្រប់រូបនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានបូជានូវកម្លាំងកាយចិត្ត និងស្មារតីខិតខំបង្ហាត់បង្រៀននិស្សិតគ្រប់រូបដោយទឹកចិត្តស្រឡាញ់មេត្តាករុណាបំផុត។
- លោកសាស្ត្រាចារ្យបណ្ឌិត **ឌឹត សំណាង** ជាសាស្ត្រាចារ្យណែនាំដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការផ្តល់យោបល់ដំបូន្មានល្អៗ និងត្រួតពិនិត្យសារណាបញ្ចប់ការសិក្សារបស់យើងខ្ញុំទាំងពីរយ៉ាងយកចិត្តទុកដាក់។
- លោកចៅសង្កាត់ **ឃី សុខ** និងលោកស្រីមេភូមិ **នុត ម៉ាលី** នៃសង្កាត់ក្បាលកោះ និងមន្ត្រីរាជការទាំងអស់នៅសង្កាត់ក្បាលកោះ។
- **មិត្តរួមថ្នាក់ និងរួមជំនាន់ជាមួយគ្នាទាំងអស់** ដែលបានជំរុញលើកទឹកចិត្ត និងការពិភាក្សាផ្លាស់ប្តូរយោបល់ ចំណេះដឹងរួមទាំងបទពិសោធន៍ល្អៗ ក្នុងការពង្រឹងសមត្ថភាពចំណេះដឹងបន្ថែមទៀត។

ជាកិច្ចចុងក្រោយយើងខ្ញុំទាំងពីរសូមលើកម្រាមដៃប្រណម្យគោរពជូនពរជ័យចំពោះលោកអ្នកមានគុណខាងលើទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចឱ្យជួបប្រទះតែពុទ្ធពរជ័យទាំងឡាយបួន ប្រការគឺមាន អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀង ឃ្លាតឡើយ ។

**សូមអរគុណ**!

# អារម្ភកថា

យើងខ្ញុំទាំងពីរជានិស្សិត ក្រុម $P_4C_2$ ថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈ ជំនាន់ទី១៤ (២០១៧-២០២១) នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានសម្រេចយកនូវការស្រាវជ្រាវ និងចងក្រងជាសារណាបញ្ចប់ឆ្នាំសិក្សាមួយស្តីពី « ការគ្រប់គ្រងរដ្ឋបាលនៅសង្កាត់ក្បាលកោះ » (ចាប់ពីឆ្នាំ២០១៨ ដល់ ២០២០) សម្រាប់បញ្ចប់ ការសិក្សាថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈ។

ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ គឺពិតជាមានសារៈសំខាន់ណាស់នៅក្នុងការចូលរួម ចំណែកអភិវឌ្ឍន៍សង្គមជាតិទាំងមូលឱ្យមានការជឿនលឿនរីកចំរើនទៅមុខ។ ជាងនេះទៅទៀតការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់ បានលើកកម្ពស់គុណភាពនៃការផ្តល់សេវាសាធារណៈ បង្កើនសុខុមាលភាព និងធ្វើការតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋានទាំងអស់ដែលធ្វើឱ្យរដ្ឋាភិបាល និងប្រជាពលរដ្ឋកាន់តែមានភាពជិតស្និទ្ធនិងគ្នា មិនតែប៉ុណ្ណោះមានការយល់កាន់តែច្បាស់អំពីតម្រូវការរបស់ប្រជាពលរដ្ឋថា ពួកគាត់មានតម្រូវការចង់បានអ្វី និងមិនចង់បានអ្វី ដើម្បីងាយស្រួលក្នុងការដោះស្រាយបញ្ហាជូនប្រជាពលរដ្ឋបានទាន់ពេលវេលា។

អាស្រ័យដូចបានរៀបរាប់ខាងលើរួចមកហើយ កត្តាទាំងអស់នេះហើយដែលធ្វើឱ្យយើងខ្ញុំទាំងពីរសម្រេចចិត្តជ្រើសរើសយកប្រធានបទ « ការគ្រប់គ្រងរដ្ឋបាលសង្កាត់ក្បាលកោះ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ » យកមកសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនេះ ព្រោះថាប្រធាននេះបានបង្ហាញឱ្យយើងមើលឃើញនូវការអនុវត្តជាក់ស្តែងអំពីការគ្រប់គ្រងរដ្ឋបាល ការអនុវត្តន៍តួនាទីភារកិច្ចរបស់មន្ត្រី ឃុំ សង្កាត់ ថាតើគោរពទៅបទដ្ឋានគតិយុត្តនានាដែរឬទេ។

ជាចុងក្រោយ សារណាដែលកំពុងស្ថិតនៅក្នុងដៃរបស់មិត្តអ្នកអាននេះ ទោះបីជាបានចេញជារូបរាងពិតមែនតែកំហុសដែលកើតឡើងដោយអចេតនាតែងតែមានដូចជា៖ ការប្រើពាក្យពេចន៍ការប្រើភាសា អក្ខរាវិរុទ្ធ ការប្រើប្រាស់វេយ្យាករណ៍ជាដើមដែលមិនអាចជៀសផុតឡើយ។ លើសពីនេះទៅទៀត កម្រិតនៃការយល់ដឹងពេលវេលា ឯកសារ កិច្ចសហការពីមន្ត្រីមូលដ្ឋានញ៉ាំងឱ្យកិច្ចការនេះមិនទាន់មានលក្ខណៈទូលំទូលាយនៅឡើយ។ ហើយជាចុងបញ្ចប់ យើងខ្ញុំទាំងពីរសង្ឃឹមថាសារណានេះនឹងផ្តល់ជាជំនួយ និងគន្លឹះខ្លះៗសម្រាប់មិត្តអ្នកអានណាដែលចង់ចេះដឹង ស្រាវជ្រាវ ស្វែងយល់ពីគ្រប់មជ្ឈដ្ឋានទាំងអស់។ ម្យ៉ាងវិញទៀត យើងខ្ញុំទាំងពីរនាក់ពិតជាមានសេចក្តីរីករាយ និងរងចាំទទួលយកគ្រប់យ៉ាងនូវការរិះគន់ ដើម្បីស្ថាបនាពីសំណាក់មិត្តអ្នកអានទាំងអស់ យើងខ្ញុំទាំងពីរនាក់ព្យាយាមខិតខំបន្តពង្រឹងស្ថាបនាឯកសារស្រាវជ្រាវឱ្យកាន់តែមានគុណភាព និងក្លាយទៅជាសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ របស់យើងខ្ញុំទាំងពីរ។

# មាតិកា

## សេចក្តីផ្តើម ទំព័រ

១.លំនាំបញ្ហានៃការស្រាវជ្រាវ................................................................................... ១
២. ចំណោទបញ្ហានៃការស្រាវជ្រាវ................................................................................ ១
៣. គោលបំណងនៃការស្រាវជ្រាវ.................................................................................២
៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ .....................................................................២
៥. សារៈសំខាន់នៃការស្រាវជ្រាវ ................................................................................២
៦. វិធីសាស្រ្តនៃការស្រាវជ្រាវ ......................................................................................២
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ...................................................................................៣

## ជំពូកទី១

## សញ្ញាណទូទៅនៃការគ្រប់គ្រងរដ្ឋបាល

**១.១ និយមន័យនៃការគ្រប់គ្រងរដ្ឋបាល** ................................................................. ៤
១.១.១ ទិសដៅនៃការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់ ............................................................... ៦
១.១.២ ការគ្រប់គ្រងរដ្ឋបាលថ្នាក់កណ្តាល(ថ្នាក់ជាតិ) .........................................................៧
១.១.៣ ការគ្រប់គ្រងរដ្ឋបាលថ្នាក់មូលដ្ឋាន (ថ្នាក់ក្រោមជាតិ)...................................................៨
**១.២ ការប្រព្រឹត្តទៅនៃការគ្រប់គ្រងរដ្ឋបាលសង្កាត់ក្បាលកោះ**............................................ ៩
**១.២.១ ទិដ្ឋភាពទូទៅរបស់សង្កាត់ក្បាលកោះ** ..................................................................... ៩
១.២.១.១ ប្រវត្តិរបស់សង្កាត់ក្បាលកោះ.......................................................................... ៩
១.២.១.២ ទីតាំងភូមិសាស្រ្តរបស់សង្កាត់ក្បាលកោះ ........................................................... ១០
១.២.១.៣ ស្ថានភាពទូទៅរបស់ប្រជាពលរដ្ឋ ..................................................................... ១០
**១.២.២ ការរៀបចំរដ្ឋបាលឃុំ សង្កាត់**.......................................................................... ១០
១.២.២.១ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់ ................................................ ១០
១.២.២.២ រចនាសម្ព័ន្ធ និងតួនាទីក្រុមប្រឹក្សា ឃុំ សង្កាត់................................................១២
១.២.២.៣ តួនាទី មុខងារ និងអំណាចរបស់រដ្ឋបាល ឃុំ សង្កាត់........................................... ១៨
**១.២.៣ កិច្ចការរដ្ឋបាលឃុំ សង្កាត់** ...........................................................................២០
១.២.៣.១ លិខិតបទដ្ឋានគតិយុត្ត ឃុំ សង្កាត់...................................................................២០
១.២.៣.២ លិខិតរដ្ឋបាល ឃុំ សង្កាត់.............................................................................២១

១.២.៣.៣ ការគ្រប់គ្រងបុគ្គលិក ឯកសារ និងសម្ភារៈបរិក្ខាររបស់ ឃុំ សង្កាត់......................២២
១.២.៣.៤ ការរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ........................................................២៣
**១.៣ ដំណើរការគ្រប់គ្រងរដ្ឋបាលរបស់សង្កាត់ក្បាលកោះ**...........................................២៧
**១.៣.១ ការរៀបចំ និង ការប្រព្រឹត្តទៅរបស់រដ្ឋបាលសង្កាត់ក្បាលកោះ**.............២៧
១.៣.១.១ សមាសភាពក្រុមប្រឹក្សា ............................................................................២៧
១.៣.១.២ គណៈកម្មាធិការនានារបស់សង្កាត់ក្បាលកោះ ................................................២៧
**១.៣.២ ការអភិវឌ្ឍរបស់សង្កាត់ក្បាលកោះ**.......................................................២៩
១.៣.២.១ ផែនការអភិវឌ្ឍន៍សង្កាត់...........................................................................២៩
១.៣.២.២ កម្មវិធីវិនិយោគ.........................................................................................៣៣
**១.៣.៣ ការគ្រប់គ្រងហិរញ្ញវត្ថុរបស់សង្កាត់**.........................................................៣៥
១.៣.៣.១ ការរៀបចំ និងអនុម័តថវិកា ........................................................................៣៦
១.៣.៣.២ ចំណូល និងចំណាយថវិការបស់សង្កាត់ ..........................................................៣៧
១.៣.៣.៣ ប្រព័ន្ធទូទាត់ គណនេយ្យភាព និងលទ្ធកម្ម.....................................................៣៨
**ជំពូកទី ២**
**ការវិភាគទិន្នន័យនៃការស្រាវជ្រាវ**
**២.១ សមិទ្ធផលដែលសម្រេចបានក្នុងការអនុវត្តសង្កាត់ក្បាលកោះ** .............................. ៤០
២.១.១ ផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ច ......................................................................... ៤០
២.១.២ ផ្នែកធនធានធម្មជាតិ បរិស្ថាន និងបន្សាំនិងការប្រែប្រួលអាកាសធាតុ .........................៤៣
២.១.៣ ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ............................................... ៤៤
**២.២ បញ្ហាប្រឈម**.............................................................................................. ៤៥
២.២.១ ផ្នែកធនធានហិរញ្ញវត្ថុ...................................................................................... ៤៥
២.២.២ ភាពក្រីក្រ ..................................................................................................... ៤៥
២.២.៣ ផ្នែកគមនាគមន៍ ............................................................................................. ៤៥
២.២.៤ ផ្នែកពាណិជ្ជកម្ម និងអាជីវកម្ម............................................................................ ៤៦
២.២.៥ ផ្នែកឧស្សាហ៍កម្ម និងសិប្បកម្ម............................................................................ ៤៦
២.២.៦ ផ្នែកទេសចរណ៍ .............................................................................................. ៤៦
២.២.៧ ផ្នែកអប់រំ និងយេនឌ័រ........................................................................................ ៤៦

២.២.៨ ផ្នែកសុខាភិបាល និងបរិស្ថាន ........................................ ៤៧
២.២.៩ ផ្នែករដ្ឋបាល សន្តិសុខ និងសណ្តាប់ធ្នាប់ ........................................ ៤៧
**២.៣ ដំណោះស្រាយ** ........................................ ៤៨
២.៣.១ ការកាត់បន្ថយភាពក្រីក្រ និងជំរុញឱ្យមានការអភិវឌ្ឍតាមមូលដ្ឋាន ........................................ ៤៨
២.៣.២ កែលម្អប្រព័ន្ធទូរគមនាគមន៍ ........................................ ៤៨
២.៣.៣ ពង្រឹងផ្នែកពាណិជ្ជកម្ម និងអាជីវកម្ម ........................................ ៤៩
២.៣.៤ ផ្នែកឧស្សាហ៍កម្ម និងសិប្បកម្ម ........................................ ៤៩
២.៣.៥ ផ្នែកទេសចរណ៍ ........................................ ៤៩
២.៣.៦ ការលើកកម្ពស់គុណភាពអប់រំ និងសមភាពយេនឌ័រ ........................................ ៤៩
២.៣.៧ ផ្នែកសុខាភិបាល និងបរិស្ថាន ........................................ ៥០
២.៣.៨ ការរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់ ........................................ ៥០
២.៣.៩ ការបង្កើនប្រសិទ្ធភាពការងាររដ្ឋបាល និងអភិបាលកិច្ចល្អ ........................................ ៥១
**២.៤ ទិសដៅអនាគត** ........................................ ៥១
២.៤.១ ការបណ្តុះបណ្តាលធនធានមនុស្ស ........................................ ៥២
២.៤.២ ការបង្កើនភាពជាម្ចាស់ និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សា ឃុំ សង្កាត់ ........................................ ៥២
២.៤.៣ បង្កើនថវិកាឃុំ សង្កាត់ ........................................ ៥៣
**សេចក្តីសន្និដ្ឋាន** ........................................ ៥៤
**អនុសាសន៍** ........................................ ៥៥
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

អស់រយៈពេលប្រមាណជិតបីទសវត្សរ៍មកហើយ ដែលប្រទេសកម្ពុជាបានឆ្លងកាត់នៅសង្គ្រាមជាច្រើន ពិសេសនោះគឺសង្គ្រាមប្រល័យពូជសាសន៍ក្រោមរបបដឹកនាំដ៏សែនសាហាវយង់ឃ្នងរបស់របប ប៉ុល ពត ដែលបានធ្វើឱ្យមនុស្សស្លាប់រាប់លាននាក់បាត់បង់ ធនធានមនុស្ស អ្នកប្រាជ្ញ បន្សល់ទុកនូវស្ត្រីមេម៉ាយ ក្មេងកំព្រា ខូចខាតហេដ្ឋារចនាសម្ព័ន្ធខ្ទេចខ្ទីស្ទើរតែគ្មានសល់ប្រទេសរស់នៅគ្មានច្បាប់ ។ ក្រោយមកផ្តើមចេញពីដឹកនាំរបស់រដ្ឋាភិបាលកម្ពុជាដែលបានដាក់ចេញនូវគោលនយោបាយ ឈ្នះ ឈ្នះ យុទ្ធសាស្ត្រនយោបាយ និង កំណែទម្រង់នូវយុទ្ធសាស្ត្រថ្មីៗ ដើម្បីកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ហើយជាពិសេសទៅទៀតនោះ ការធ្វើកំណែទម្រង់ទៅលើប្រព័ន្ធរដ្ឋបាលសាធារណៈ គឺក្នុងគោលបំណងផ្តល់នូវសេវាសាធារណៈជូនប្រជាពលរដ្ឋឱ្យកាន់តែមានភាពប្រសើរឡើងតាមរយៈការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យប្រកបដោយចីរភាព។

ទន្ទឹមនឹងនេះផងដែលនៅសង្កាត់ក្បាលកោះ ក៏មានការរីកចំរើនលើគ្រប់វិស័យផងដែលដូចជា វិស័យអប់រំ វិស័យសុខាភិបាលវិស័យសាធារណការ និងដឹកជញ្ជូន វិស័យទូរគមនាគមន៍ និងវិស័យធនធានទឹកជាដើម។ ហើយវិស័យទាំងអស់នេះហើយដែលចូលរួមចំណែកឆ្លើយតបទៅ និង តម្រូវការរបស់ប្រជាពលរដ្ឋតាមមូលដ្ឋានឱ្យកាន់តែមានភាពល្អប្រសើរឡើងជាលំដាប់តាមរយៈគោលនយោបាយរបស់រដ្ឋាភិបាល ដើម្បីកាត់បន្ថយភាពក្រីក្រប្រជាពលរដ្ឋ។ ដូច្នេះហើយ ដើម្បីចូលរួមលើកកម្ពស់ក្នុងការអភិវឌ្ឍ ការកសាងអនុវត្តនូវប្រព័ន្ធការគ្រប់គ្រងរដ្ឋបាលសាធារណៈ និងការអនុវត្តលទ្ធិបែបប្រជាធិបតេយ្យប្រកបដោយចីរភាពនៅតាមថ្នាក់មូលដ្ឋានរួមមានដូចជា គណនេយ្យភាព តម្លាភាព និងការកសាងនៃការអភិវឌ្ឍរយៈពេលវែងដែលមានភាពចាំបាច់បំផុត គឺតម្រូវឱ្យមានការចូលរួមសហការយ៉ាងខ្លាំងពីសំណាក់ប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋានទាំងអស់ ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ដើម្បីជាជំនួយទៅលើការសិក្សាស្រាវជ្រាវលើប្រធានបទ « ការគ្រប់គ្រងរដ្ឋបាលនៅសង្កាត់ក្បាលកោះ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ (ឆ្នាំ២០១៨ ដល់២០២០) » ឱ្យបានស៊ីជម្រៅ និងមានភាពច្បាស់លាស់ថែមទៀតនោះចំណោទបញ្ហាត្រូវបានលើកឡើងថា តើការគ្រប់គ្រងរដ្ឋបាលនៅសង្កាត់ក្បាលកោះមានលក្ខណៈមានបែបណា? តើរៀបចំរដ្ឋបាលឃុំ សង្កាត់មានដំណើរការយ៉ាងដូចម្តេច ដើម្បីឆ្លើយតបទៅនិងតម្រូវការប្រជាពលរដ្ឋនៅទីនោះ? តើប្រជាពលរដ្ឋនៅទីនោះមានការពេញចិត្ត ដែរឬទេ? តើរចនាសម្ព័ន្ធនៃការគ្រប់គ្រងរដ្ឋបាលនៅសង្កាត់ក្បាលកោះមាន លក្ខណៈបែបណា?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាលើប្រធានបទនេះ (ការគ្រប់គ្រងរដ្ឋបាលនៅសង្កាត់ក្បាលកោះ ពីឆ្នាំ២០១៨ ដល់ឆ្នាំ ២០២០) ក្នុងគោលបំណងស្វែងយល់អំពីការបែងចែករចនាសម្ព័ន្ធនៃការគ្រប់គ្រង និងអំពីតួនាទីភារកិច្ចរបស់ឃុំ សង្កាត់ មកកាន់ប្រជាពលរដ្ឋរួមទាំងសិទ្ធិអំណាចផងដែរ។ លើសពីទៅទៀតចង់ស្វែងយល់អំពីបញ្ហាប្រឈមនានាដែលបានកើតឡើងនៅក្នុងការអនុវត្តការងារផ្តល់សេវាសាធារណៈ និងស្វែងរកដំណោះស្រាយដ៏សមស្របមួយ ដើម្បីឱ្យកម្ពុជាកាន់តែមានការរីកចម្រើនជាងនេះក្នុងការបម្រើ ឬផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ចំពោះទំហ និង ដែនកំណត់នៃការការសិក្សាស្រាវជ្រាវនេះផ្តោតលើការយកចិត្តទុកដាក់យ៉ាងសំខាន់ទៅលើប្រធានបទមួយស្តីពី(ការគ្រប់គ្រងនៅសង្កាត់ក្បាលកោះ ដែលត្រូវបានកំណត់យកចាប់ពីឆ្នាំ២០១៨ ដល់២០២០) ដោយធ្វើការវែកញែកឱ្យច្បាស់អំពីដំណើរការក្នុងការគ្រប់គ្រង និងស្វែងរកហានិភ័យនៅក្នុងសង្កាត់។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះមានសារៈសំខាន់សម្រាប់សង្គម បុគ្គល និងជាការដកស្រង់នូវបទពិសោធន៍ពីការយល់ដឹងអំពី (ការគ្រប់គ្រងរដ្ឋបាលនៅសង្កាត់ក្បាលកោះក្នុងឆ្នាំ ២០១៨ - ២០២០) ។ ការស្រាវជ្រាវផ្តល់សារប្រយោជន៍ជាច្រើនដូចជា៖

**ចំពោះអ្នកសិក្សាស្រាវជ្រាវ៖** បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវនេះ បានធ្វើឱ្យយើងយល់កាន់តែច្បាស់អំពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។ ផ្តល់នូវបទពិសោធន៍ ចំណេះដឹងជាក់ស្តែងក្នុងការអភិវឌ្ឍទៅថ្ងៃអនាគត និងចងក្រងទុកជាឯកសារសម្រាប់មនុស្សជំនាន់ក្រោយ។

**ចំពោះសង្គម៖** អាចបង្ហាញទិន្នន័យពិតប្រាកដ និងជាក់ស្តែងដល់បណ្តាពាក់ព័ន្ធផ្សេងៗ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

វិធីសាស្ត្រនៃការស្រាវជ្រាវ គឺជាការស្រាវជ្រាវតាមបែបទិន្នន័យបន្ទាប់បន្សំដោយធ្វើការចុះទៅអង្កេត និងស្រាវជ្រាវនៅសាលាសង្កាត់ដោយការស្នើសុំឯកសារផ្សេងៗពីសង្កាត់បានការពិភាក្សា និងទទួលបានការពន្យល់ពីសាស្ត្រាចារ្យណែនាំ សាស្ត្រាចារ្យនានា និងការស្រាវជ្រាវឯកសារទាក់ទងដែលមាននៅក្នុងបណ្ណាល័យនានាជាពិសេសនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងតាមប្រព័ន្ធអេឡិចត្រូនិច ស្វែងរកព័ត៌មាននានា តាមបណ្តាគេហទំព័រដែលនិយាយពីបញ្ហាពាក់ព័ន្ធ ដើម្បីធ្វើឱ្យប្រធានបទកាន់តែមានភាពស៊ីជម្រៅ និងផ្តល់ជាសៀវភៅមួយដែលអាចទុកជូនអ្នកស្រាវជ្រាវផ្សេងៗ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

រចនាសម្ព័ន្ធក្នុងការរៀបចំនៃឯកសារស្រាវជ្រាវមួយនេះ យើងខ្ញុំបានកំណត់លើយកនូវប្រធានបទស្តីពី «ការគ្រប់គ្រងរដ្ឋបាលនៅសង្កាត់ក្បាលកោះ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ(ឆ្នាំ២០១៨ ដល់២០២០)» ត្រូវបានរៀបចំដូចខាងក្រោម៖

- សេចក្តីផ្តើម
- ជំពូកទី១៖ សញ្ញាណទូទៅនៃការគ្រប់គ្រងរដ្ឋបាល។
- ជំពូកទី២៖ ការវិភាគទិន្នន័យនៃការស្រាវជ្រាវ។
- សេចក្តីសន្និដ្ឋាន
- អនុសាសន៍
- ឯកសារយោង
- ឧបសម្ព័ន្ធ

# ជំពូកទី១

# សញ្ញាណទូទៅស្តីពីការគ្រប់គ្រងរដ្ឋបាល

## ១.១ និយមន័យនៃពាក្យការគ្រប់គ្រងរដ្ឋបាល

បើតាមវចនានុក្រមរបស់សម្តេចព្រះសង្ឃរាជ ជួន ណាត បានបញ្ជាក់ថា "រដ្ឋបាល" មកពីពាក្យ "រដ្ឋ" បូកជាមួយនឹងពាក្យ "បាល"។ "រដ្ឋ" គឺជាពាក្យបាលីដែលប្រែសំរាយទៅជាភាសាខ្មែរថាជានគរ ប្រទេស ឬដែន។ ចំណែកពាក្យថា "បាល" ជាពាក្យបាលីដែលប្រែសំរាយទៅជាភាសាខ្មែរថាជា គ្រប់គ្រង ថែរក្សាការពារ ផ្គត់ផ្គង់ ត្រួតត្រាមើលការខុសត្រូវ។ ដូច្នេះ បើតាមទស្សនៈនេះពាក្យថា " រដ្ឋបាល " មានន័យថា ជាកិច្ចការងាររបស់រដ្ឋ ការគ្រប់គ្រងរដ្ឋ ឬការគ្រប់គ្រងប្រទេស[1]។ ចំណែក លោក សាយ បូរី ក្នុងសៀវភៅនីតិរដ្ឋបាលទូទៅ បានសរសេរពាក្យ" រដ្ឋបាល " ដោយប្រើប្រាស់ភាសាបារាំង Administration និង Administration Publique បកប្រែមកជាភាសាខ្មែរយើងថា "រដ្ឋបាលសាធារណៈ"។

បើតាមន័យទូលាយវិញពាក្យថា " រដ្ឋបាល " អាចប្រើប្រាស់បានក្នុងន័យពីរយ៉ាងដោយនៅពេលខ្លះគេប្រើប្រាស់សំដៅទៅលើសកម្មភាពគ្រប់គ្រងពេលខ្លះទៀតគេសំដៅទៅលើអង្គភាព។ បើតាមន័យនេះ រដ្ឋបាលមានន័យថា ជាការគ្រប់គ្រងទៅលើដំណើរការការងាររបស់ស្ថាប័នណាមួយ ឬមួយទៀតអាចនិយាយបានថាជាស្ថាប័នដែលអនុវត្តការងាររដ្ឋបាលផ្សេងៗ។ ចំណែកនៅក្នុងវចនានុក្រមរដ្ឋបាលសាធារណៈរបស់លោកឆែន ដ្លើរ (Chandler) និង លោកប្លាណូ (Plano) បានពោលថា រដ្ឋបាល គឺជាដំណើរការនៃការអនុវត្តនូវសេចក្តីសម្រេច និងគោលនយោបាយនានា។[2]

សរុបមកពាក្យថា "រដ្ឋបាល" មានន័យថាជាស្ថាប័ន ឬអង្គភាពមួយដែលដំណើរការការងារ និងគ្រប់គ្រងកិច្ចការងារផ្សេងៗ ដែលប្រមូលផ្តុំគ្នាទាំង លិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ នីតិវិធី ប្រព័ន្ធវចនាសម្ព័ន្ធអង្គការចាត់តាំងបុគ្គលិកដើម្បីអនុវត្តសេចក្តីសម្រេច និងគោលបំណងរបស់របស់ស្ថាប័ន ឬអង្គភាពនោះប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល និងការទទួលខុសត្រូវខ្ពស់។

ពាក្យថា "សាធារណៈ" បើតាមវចនានុក្រមសម្តេចសង្ឃរាជ ជួន ណាត មានន័យថាជាទូទៅដែលប្រើបានទាំងអស់គ្នាដែលមិនចំពោះបុគ្គលណាម្នាក់។

សេវាសាធារណៈ ត្រូវបានកំណត់និយមន័យជាច្រើនទៅតាមប្រភពផ្សេងៗគ្នា។ ខាងក្រោមនេះជាការស្រង់នូវប្រភពមួយចំនួនបង្ហាញអំពីនិយមន័យនៃសេវាសាធារណៈដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា។

[1] ជួន ណាត វចនានុក្រមខ្មែរភាគទី១ ឆ្នាំ១៩៦៧ ទំព័រ ១៤០

[2] ឆែនដ្លើរ (Chandler) និងលោកប្លាណូ(Plano) វចនានុក្រមរដ្ឋបាលសាធារណៈ ១៩៩៨

តាមនិយមន័យរបស់កម្មវិធីអភិវឌ្ឍអង្គការសហប្រជាជាតិ (UNDP) ដែលមានចែងនៅក្នុងកំណត់ត្រាអនុវត្តនៃកំណែទម្រង់រដ្ឋបាលសាធារណៈ បានលើកឡើងដោយចាត់ទុក « រដ្ឋបាល » ថាជាម៉ាស៊ីនប្រមូលផ្ដុំគ្នានូវគោលនយោបាយ លិខិតបទដ្ឋាន នីតិវិធី ប្រព័ន្ធរចនាសម្ព័ន្ធ អង្គការចាត់តាំង បុគ្គលិក ដែលផ្ដល់ប្រាក់ដោយថវិការបស់រដ្ឋ ហើយមានការទទួលខុសត្រូវក្នុងការគ្រប់គ្រងមានគោលដៅឆ្ពោះទៅរកការងារទាំងឡាយរបស់រដ្ឋាភិបាលមានការធ្វើអន្តរសកម្មភាពជាមួយភ្នាក់ងារដែលនឹងពាក់ព័ន្ធនានា មាននៅក្នុង រដ្ឋ សង្គម ឬ បរិស្ថានខាងក្រៅផ្សេងៗទៀត។[3] បើតាមនិយមន័យនេះ រដ្ឋបាល ត្រូវបានគេប្រៀបប្រដូចទៅនឹងម៉ាស៊ីន អង្គការចាត់តាំងដែលមានរចនាសម្ព័ន្ធច្បាស់លាស់មានការបែងចែកចំពោះសម្រាប់ ការងារ តួនាទី ការទទួលខុសត្រូវលើការងាររបស់រដ្ឋាភិបាលដោយមានអន្តរកម្មគ្នាទៅវិញទៅមក នៅក្នុងស្ថាប័នតែមួយ និងទំនាក់ទំនងជាមួយស្ថាប័នខាងក្រៅផ្សេងៗទៀតផងដែរ។

នៅក្នុងសៀវភៅ "នីតិមូលដ្ឋានស្វយ័ត" របស់លោក ឯក ឆេងហួត បានអោយនិយមន័យពាក្យ"រដ្ឋបាល" ថាជារបៀបចាត់ចែងការងារបម្រើអោយបុគ្គល ឬសមូហភាពណាមួយ ដើម្បីសម្របសម្រួលឋានានុក្រមការងារនោះជូនបុគ្គល ឬសមូហភាពដែលខ្លួនស្ថិតនៅ។[4]

តាមបណ្ឌិត សាយ បូរី បានបញ្ជាក់ថាសេវាសាធារណៈមានន័យ ៣យ៉ាង៖[5]

(១) សេវាសាធារណៈ គឺជាអង្គការដែលមានបុគ្គលិក ភ្នាក់ងារធ្វើការ និងមធ្យោបាយសម្រាប់បម្រើប្រយោជន៍សាធារណៈ។ រដ្ឋ និងសមូហភាពវិមជ្ឈការអាចបង្កើតសេវាសាធារណៈបានដោយខ្លួនឯង។ នេះគេហៅថា ការឱ្យនិយមន័យតាមលក្ខណៈ " អង្គការ " ដែលភាគច្រើនសំដៅទៅលើ " ក្រសួង ឬ មន្ទីរបស់ក្រសួង" នៃអង្គការរដ្ឋ និង អង្គការវិមជ្ឈការ។

(២) សេវាសាធារណៈ គឺជាសកម្មភាពបម្រើផលប្រយោជន៍ជូនទៅរបស់រដ្ឋ។ សកម្មភាពនេះជួនកាលរដ្ឋកាន់កាប់ដោយខ្លួនឯងផ្ទាល់( ហៅថា" រដ្ឋាករ " ) ជួនកាលរដ្ឋប្រគល់ឱ្យឯកជនកាន់កាប់ ប៉ុន្តែស្ថិតក្រោមការត្រួតពិនិត្យរបស់រដ្ឋ (ហៅថា"សម្បទានសាធារណៈ")។ នេះជាការឱ្យនិយមន័យទៅតាមខ្លឹមសារនៃកម្មវត្ថុ។

(៣) សេវាសាធារណៈ គឺជាអត្ថន័យសំខាន់មួយនៃនីតិរដ្ឋបាលដែលសំដៅទៅលើសកម្មភាពរបស់រដ្ឋនៅក្នុងរបបគតិយុត្តពិសេស ឬរបបគតិយុត្តបដិប្បញ្ញត្តិនីតិរួម។ នេះជាការឱ្យនិយមន័យតាមលក្ខណៈគតិយុត្ត (ច្បាប់)។

[3] កៅមុយថង រដ្ឋបាលសាធារណៈទំនើប បណ្ណាគារអង្គរ ឆ្នាំ២០០៧ ទំព័រ៩

[4] ឯក ឆេងហួត នីតិមូលដ្ឋានស្វយ័ត ឆ្នាំ២០០៣ ទំព័រ៨

[5] សាយ បូរី នីតិរដ្ឋបាលទូទៅ ទំព័រទី៤០៣

ចំពោះធនាគារពិភពលោកបានបង្ហាញថាសេវាសាធារណៈមានដូចជា ការសិក្សាអប់រំ ការថែទាំសុខភាព និងការការពារសង្គម ដែលមានសារៈសំខាន់ក្នុងការកាត់បន្ថយគម្លាតប្រាក់ចំណូលរបស់ប្រជាជននៅក្នុងទីក្រុង និងជនបទដែលបង្កលក្ខណៈឱ្យប្រជាជនរស់នៅក្នុងតំបន់ជនបទមានកំរិតជីវភាពរស់នៅសមរម្យ និងអាចចូលរួមការអភិវឌ្ឍសេដ្ឋកិច្ច។[6]

តាមគោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈបានកំណត់អំពីនិយមន័យនៃសេវាសាធារណៈថា៖ " រាល់កម្មភាពទាំងឡាយដែលធ្វើដោយស្ថាប័នមានសមត្ថកិច្ច និងស្ថាប័នទទួលសមត្ថកិច្ច ក្នុងគោលដៅបម្រើផលប្រយោជន៍សាធារណៈគឺជាសេវាសាធារណៈ"។

"ស្ថាប័នមានសមត្ថកិច្ច" នៅក្នុងន័យនេះគឺសំដៅដល់ស្ថាប័នរដ្ឋ ឬភ្នាក់ងារ ឬអាជ្ញាធរគ្រប់លំដាប់ថ្នាក់ទាំងអស់របស់រដ្ឋដែលបំពេញការងារតាមដែនសមត្ថកិច្ចរបស់ខ្លួន។

"ស្ថាប័នទទួលសមត្ថកិច្ច" នៅក្នុងន័យនេះគឺសំដៅដល់ផ្នែកឯកជន និងសង្គមស៊ីវិលដែលទទួលបានសិទ្ធិ និងទទួលភារកិច្ចពីរដ្ឋ ហើយដែលស្ថិតនៅក្រោមការគ្រប់គ្រង ត្រួតពិនិត្យរបស់រដ្ឋ ឬភ្នាក់ងាររដ្ឋ។[7] ការគ្រប់គ្រងត្រួត ពិនិត្យរបស់រដ្ឋ ឬភ្នាក់ងាររដ្ឋទៅលើផ្នែកឯកជន និងសង្គមស៊ីវិលដែលរដ្ឋបានប្រគល់សិទ្ធិអំណាចឱ្យត្រូវធ្វើឡើងផ្អែកលើលក្ខខណ្ឌ ដូចមានចែងក្នុងសេចក្តីសម្រេច កិច្ចព្រមព្រៀងឬកិច្ចសន្យា ដែលបានប្រគល់ភារកិច្ចក្នុងរង្វង់ដែនសមត្ថកិច្ចមួយច្បាស់លាស់ និងពិនិត្យទៅលើសកម្មភាពការងារលទ្ធផលដែលបានសម្រេចបានគោលដៅទៅអនាគត និងផលប៉ះពាល់ផ្សេងៗជាយថាហេតុដែលអាចកើតមានចំពោះសង្គមជាតិ។

➢ **និយមន័យការគ្រប់គ្រងរដ្ឋបាលតាមបែបវិមជ្ឈការ** មានន័យថា រាជរដ្ឋាភិបាលប្រគល់ឱ្យក្រុមប្រឹក្សានូវភាពជាម្ចាស់លើមុខងារសិទ្ធិអំណាច និងធនធានដើម្បីឆ្លើយតបទៅ និងតម្រូវការរបស់មូលដ្ឋាន។ ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋមូលដ្ឋានលើបញ្ហាទាំងនេះ។[8]

### ១.១.១ ទិសដៅនៃការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

ទិសដៅនៃការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់គឺ

- ផ្តល់ឱកាសដល់ប្រជាពលរដ្ឋឱ្យចូលរួមកាន់តែទូលំទូលាយ នៅក្នុងការធ្វើសេចក្តីសម្រេចចិត្តដែលមានផលប៉ះពាល់ទៅជីវភាពរស់នៅ និងអនាគតរបស់ខ្លួន។
- លើកកម្ពស់លទ្ធិប្រជាធិបតេយ្យ អភិបាលកិច្ចល្អ និងគុណភាពនៃជីវភាពរស់នៅ
- ធានាការអភិវឌ្ឍប្រកបដោយចីរភាព រួមទាំងការផ្តល់សេវាជាមូលដ្ឋានផងដែរ។[9]

[6] ធនាគារពិភពលោក, សេវាកម្មសាធារណៈ, ទំព័រទី១

[7] ប៉ូល ពីខូ, បទបង្ហាញ ការកែលម្អគុណភាពសេវាសាធារណៈ, ២០១៦

### ១.១.២ ការគ្រប់គ្រងរដ្ឋបាលកណ្តាល (ថ្នាក់ជាតិ)

រដ្ឋបាលកណ្តាលមានពីរលំដាប់គឺ៖

**ថ្នាក់រដ្ឋាភិបាល** ៖ មានទីស្តីការគណៈរដ្ឋមន្ត្រី ដែលជាទីតាំងការិយាល័យរដ្ឋបាលរបស់រដ្ឋដែលមាននាយករដ្ឋមន្ត្រីជាអ្នកដឹកនាំការងាររបស់ទីស្តីការគណៈរដ្ឋមន្ត្រី។ រដ្ឋមន្ត្រីជាអ្នកដឹកនាំការងាររបស់ទីស្តីការគណៈរដ្ឋមន្ត្រី។ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី មានអំណាចធ្វើសេចក្តីសម្រេចលើគ្រប់វិស័យទាំងអស់របស់ក្រសួងនិងក្នុង វិនិយោគទុន ពាណិជ្ជកម្ម ធនាគារ ការធានារ៉ាប់រង និងផ្នែកសេដ្ឋកិច្ច។

**ថ្នាក់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន៖** មានរដ្ឋមន្ត្រី ឬរដ្ឋលេខាធិការជាប្រធានស្ថាប័នជាអ្នកគ្រប់គ្រងមន្ត្រីភ្នាក់ងាររាជការដែលនៅក្រោមឱវាទ។

ក្រសួងនីមួយៗចែកជា៖

- **ខុទ្ទកាល័យ៖** ជាលេខាធិការដ្ឋានផ្ទាល់ឬជាសេនាធិការដ្ឋានផ្ទាល់របស់រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការ ។
- **ផ្នែករដ្ឋបាល៖** ចែកចេញជានាយកដ្ឋាន ឬការិយាល័យ។ ក្រុមនេះ ជាអ្នកបច្ចេកទេស ឬ ឯកទេសសម្រាប់រៀបចំផែនការ គម្រោងការរបស់ក្រសួង និងជាសសរទ្រូងរបស់ក្រសួង ឬរដ្ឋលេខាធិការដ្ឋាន។
- **ក្រុមអធិការកិច្ច៖** មាននាទីជាអ្នកតាមដានត្រួតពិនិត្យលើការងារ បច្ចេកទេស ការងារថវិការបស់មន្ត្រីទាំងអស់នៅក្នុងក្រសួង។
- **ផ្នែកទីប្រឹក្សា៖** ជាអ្នកផ្តល់យោបល់លើគម្រោងការផ្សេងៗមុននឹងប្រធានស្ថាប័នធ្វើសេចក្តីសម្រេចចិត្ត[10]។

[8] ការគ្រប់គ្រងរដ្ឋបាលតាមបែបវិមជ្ឈការ ឆ្នាំ២០១៧ ទំព័រ១

[9] ការគ្រប់គ្រងរដ្ឋបាលតាមបែបវិមជ្ឈការ ឆ្នាំ ២០១៧ ទំព័រ ២

[10] សាយ បូរី នីតិរដ្ឋបាលទូទៅ ទំព័រ ៤១១

### ១.១.៣ ការគ្រប់គ្រងរដ្ឋបាលថ្នាក់មូលដ្ឋាន (ថ្នាក់ក្រោមជាតិ)

រដ្ឋបាលមូលដ្ឋាន ត្រូវបានត្រួតពិនិត្យដោយរដ្ឋាភិបាលជាតិតាមរយៈក្របខណ្ឌស្ថាប័ន និងច្បាប់។ នៅតាមកម្រិតនៃរដ្ឋបាលដែនដីនីមួយៗ មន្ទីរ សាខាខេត្ត និងរាជធានីភ្នំពេញនៃក្រសួងរាជរដ្ឋាភិបាលនៅរួមរស់ជាមួយនឹងអភិបាលហើយពួកគេទាំងពីរតំណាងឱ្យ ក្រសួងរាជរដ្ឋាភិបាល និងរដ្ឋាភិបាលកណ្តាលដែលជាអង្គនីតិប្រតិបត្តិ។ លើសពីនេះខណៈដែលសាលាដំបូង មានទីតាំងនៅតាមបណ្តាខេត្ត និងរាជធានីសេចក្តីសម្រេចរបស់តុលាការទាំងនេះ ជាធម្មតាអាចនឹងត្រូវធ្វើជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍ នៅចំពោះមុខតុលាការជាន់ខ្ពស់ (មើលប្រព័ន្ធច្បាប់ និង ប្រព័ន្ធតុលាការ)។ ម្យ៉ាងវិញទៀត ដីការបស់ក្រុមប្រឹក្សានៃរដ្ឋបាលមូលដ្ឋានមានឋានានុក្រមទាបជាងអនុក្រឹត្យ ចេញដោយនាយករដ្ឋមន្ត្រីដែលជាប្រមុខនៃអង្គនីតិប្រតិបត្តិ និងច្បាប់អនុម័តដោយសភា ។

អាជ្ញាធរគ្រប់លំដាប់ថ្នាក់នៃរដ្ឋបាលដែនដី អាចបំពេញភារៈកិច្ចក្នុងក្របខណ្ឌនៃយុត្តាធិការ និងហិរញ្ញវត្ថុផ្តល់ឱ្យប៉ុណ្ណោះ។ ជាទូទៅ វិស័យរបស់រដ្ឋបាលមូលដ្ឋានមិនអាចទៅហួសពីវិស័យរបស់រដ្ឋាភិបាលជាតិទេ។

ឧទាហរណ៍៖ ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មិនអាចសម្រេចបណ្តឹងលែងលះអំពើហិង្សាក្នុងគ្រួសារធ្ងន់ធ្ងរ បទល្មើសមជ្ឈឹម បទឧក្រិដ្ឋ និងបណ្តឹងនៅតុលាការបានទេ។ ចំណូលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិបានមកពីចំណូលនៃការផ្តល់សេវាពន្ធដារ និងវិភាគនៃកញ្ចប់ថវិកាជាតិយល់ព្រមដោយសភា។

ការគ្រប់គ្រងរដ្ឋបាលនៃប្រទេសកម្ពុជាចែកចេញជាបីថ្នាក់រួមមាន រាជធានី/ខេត្ត/ក្រុង ស្រុក/ខណ្ឌ និងឃុំ/សង្កាត់៖

- **រាជធានី៖** ភ្នំពេញ គឺជារាជធានីនៃប្រទេសកម្ពុជា។ រាជធានី ត្រូវបានបែងចែកជា ខណ្ឌ ហើយខណ្ឌចែកចេញជាសង្កាត់។[11]
- **ខេត្ត៖** ចែកចេញជាក្រុង និងស្រុក។ ខណៈដែលក្រុងត្រូវបានបែងចែកជាសង្កាត់ ស្រុកត្រូវចែកចេញជាឃុំ និងសង្កាត់។

រដ្ឋបាលឃុំ សង្កាត់ត្រូវបានគ្រប់គ្រងដោយច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានគ្រប់គ្រងដោយច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ វិមជ្ឈការ និង វិសហមជ្ឈការ គឺជាប្រព័ន្ធរដ្ឋបាលដែលអនុវត្តទៅគ្រប់ការគ្រប់គ្រងថ្នាក់ក្រោមជាតិ។ ឃុំ សង្កាត់មានបុគ្គលភាពគតិយុត្តឯករាជ្យផ្សេងពីរដ្ឋាភិបាលជាតិ ធនធានហិរញ្ញវត្ថុ និងការគ្រប់គ្រងផ្ទាល់ខ្លួន។ ប្រភពចំណូលបានមកពីពន្ធបន្ទុកសេវាកម្ម វិភាគពីចំណូលជាតិ ការផ្ទេរតម្លៃសម្រាប់ការបំពេញមុខងារ និងស្ថាប័នជាតិ។

---

[11] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០១៨ មាត្រា៤

រដ្ឋបាលថ្នាក់ក្រោមជាតិ មានក្រុមប្រឹក្សាកើតចេញពីការបោះឆ្នោតជាតំណាង។ ក្រុមប្រឹក្សាមានសិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងប្រតិបត្តិ។ គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង មេឃុំ ចៅសង្កាត់ មានភារកិច្ចអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាហើយក្រុមប្រឹក្សាមានសិទ្ធិត្រួតពិនិត្យមើលពីលើការអនុវត្តនេះ។ ទន្ទឹមនឹងនេះ ច្បាប់រៀបចំអង្គការបានប្រគល់តួនាទីឱ្យអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជាតំណាងឱ្យក្រសួងស្ថាប័ននានារបស់រាជរដ្ឋាភិបាលក្នុងការសម្របសម្រួលជាមួយមន្ទីរ អង្គភាពខ្សែបណ្តោយរបស់ក្រសួង ស្ថាប័នទាំងនោះផងដែរ។កិច្ចដំណើរការកំណែទម្រង់គឺជាការផ្ទេរជាជំហានៗនូវការទទួលខុសត្រូវក្នុងការផ្តល់សេវា និងការអភិវឌ្ឍមួយចំនួនរបស់រដ្ឋបាលថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិជាពិសេសរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដោយមានការសម្រេចចិត្តយ៉ាងច្បាស់លាស់ស្របគ្នាជាមួយនឹងការពង្រឹងសមត្ថភាពរដ្ឋ បាលថ្នាក់ រាជធានី ខេត្ត ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រ ការសម្របសម្រួល ការគាំទ្រ និងការត្រួតពិនិត្យមើលពីលើ។

## ១.២ ការប្រព្រឹត្តទៅនៃការគ្រប់គ្រងរដ្ឋបាលសង្កាត់ក្បាលកោះ

### ១.២.១ និដ្ឋភាពទូទៅរបស់សង្កាត់ក្បាលកោះ

#### ១.២.១.១ ប្រវត្តិរបស់សង្កាត់ក្បាលកោះ

បើតាមការរៀបរាប់របស់ លោកចៅសង្កាត់ **ឃី សុង** សង្កាត់នេះធ្លាប់ជាឃុំនៃឃុំក្បាលកោះ ស្រុកកៀនស្វាយ ខេត្តកណ្តាល។ ឃុំក្បាលកោះ ជាឃុំដែលកកើតតាំងពីយូរលង់ណាស់មកហើយ ពោលគឺមុនសម័យអាណានិគមនិយមបារាំងមកម្ល៉េះ។ ក្រោយមកមានការប្រែប្រួល និងការអភិវឌ្ឍយោងតាមអនុក្រឹត្យលេខ ១៤៣ អនក្រ.បក ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១០ ស្តីពីការប្តូរឃុំនៃរាជធានីភ្នំពេញទៅជាសង្កាត់។ កាត់យកឃុំវាលស្បូវ ឃុំព្រែកឯង ឃុំក្បាលកោះ និងឃុំព្រែកថ្មី នៃស្រុកកៀនស្វាយ ខេត្តកណ្តាល បញ្ចូលក្នុងខណ្ឌមានជ័យ រាជធានីភ្នំពេញវិញ ហើយប្តូរជាសង្កាត់វាលស្បូវ សង្កាត់ព្រែកឯង សង្កាត់ក្បាលកោះ សង្កាត់ព្រែកថ្មី។ ហើយការគ្រប់គ្រងរដ្ឋបាលមាន ភាពល្អប្រសើរ សន្តិភាព ភាពសម្បូរសប្បាយ រចនាសម្ព័ន្ធល្អ ការកសាងថ្មីៗក៏បង្កើតឡើង។ បន្ទាប់មករដ្ឋបាលឃុំ សង្កាត់ក៏បានផ្លាស់ប្តូរនៅឈ្មោះសារជាថ្មីដោយយោងតាមអនុក្រឹត្យលេខ ៥៧៩ អនក្រ.បក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតខណ្ឌច្បារអំពៅនៃរាជធានីភ្នំពេញ។ សង្កាត់ចំនួន ០៨ នៃខណ្ឌមានជ័យ ត្រូវកាត់ដាក់បញ្ចូលក្នុង ខណ្ឌ ច្បារអំពៅថ្មី រួមមាន សង្កាត់ច្បារអំពៅទី១ សង្កាត់ច្បារអំពៅទី២ សង្កាត់និរោធ សង្កាត់ព្រែកប្រា សង្កាត់វាលស្បូវ សង្កាត់ព្រែកឯង សង្កាត់ក្បាលកោះ និងសង្កាត់ព្រែកថ្មី រហូតមកដល់ពេលបច្ចុប្បន្ននេះ[12]។

[12] សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល សង្កាត់ក្បាលកោះ ឆ្នាំ២០១៨-២០២០

#### ១.២.១.២ ទីតាំងភូមិសាស្ត្ររបស់សង្កាត់ក្បាលកោះ

សង្កាត់ក្បាលកោះ គឺជាសង្កាត់មួយក្នុងចំណោមសង្កាត់សរុបទាំង៨ នៃខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ដែលមានព្រំប្រទល់ស្ថិតនៅខាងលិចទល់នឹងសង្កាត់ព្រែកឯង ខណ្ឌច្បារអំពៅ ខាងកើតទល់នឹងឃុំភូមិធំ ស្រុកកៀនស្វាយ ខេត្តកណ្ដាល ខាងជើងទល់នឹងទន្លេមេគង្គ ស្រុកល្វាឯម ខេត្តកណ្ដាល ខាងត្បូងទល់នឹង សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មានផ្ទៃដីសរុបចំនួន ២៩១,១៤៥ ហិចតា និងមានភូមិចំនួន៨ គឺ ភូមិជ្រោយអំពិល , ភូមិជ្រោយអំពិល១ , ភូមិជ្រោយអំពិល២ , ភូមិយកបាត្រ , ភូមិយកបាត្រ១ , ភូមិព្រែកធំ , ភូមិព្រែកធំ១, ភូមិព្រែកធំ២។

#### ១.២.១.៣ ស្ថានភាពទូទៅរបស់ប្រជាពលរដ្ឋ

នៅសង្កាត់ក្បាលកោះ មានប្រជាពលរដ្ឋសរុបចំនួន ៣៨២៩គ្រួសារមានប្រជាជនសរុបចំនួន ១៧៦៥១ នាក់ ក្នុងនោះស្រីមានចំនួន ៨៧០២នាក់ ចំនួនប្រជាពលរដ្ឋចាប់ពីអាយុ ១៨ឆ្នាំឡើងមានចំនួន ១៣៤០០ នាក់ ក្នុងនោះ ស្រីមានចំនួន ៦៥៧១ នាក់។ ប្រជាពលរដ្ឋដែលមានអាយុចាប់ពី ០ ឆ្នាំ ដល់ ១៧ ឆ្នាំ មានចំនួន ១៩,៤% ប្រជាពលរដ្ឋដែលមានអាយុចាប់ពីអាយុ ១៨ ឆ្នាំ ដល់ ៦០ ឆ្នាំ មានចំនួន ៦៧% ប្រជាពលរដ្ឋដែលមានអាយុចាប់ពី៦១ ឆ្នាំ ឡើងទៅមានចំនួន ១៣,៦% មេគ្រួសារជាស្ត្រីមានចំនួន ២៣,៣%កំណើនប្រជាពលរដ្ឋប្រចាំឆ្នាំ ១៥,៣% អត្រាភាពក្រីក្រ១៤,៣%។ ការប្រកបមុខរបរសម្រាប់ចិញ្ចឹមជីវិតប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋនៅក្នុងសង្កាត់ក្បាលកោះ ភាគច្រើនប្រកបមុខរបរផ្នែកសិប្បកម្មដែលមានតួរលេខចំនួន ១,១% និងផ្នែកសេវាកម្មមានចំនួន ៩៨,៩% [12]។

### ១.២.២ ការរៀបចំរដ្ឋបាលឃុំ សង្កាត់

#### ១.២.២.១ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានបោះឆ្នោតជ្រើសរើសឡើងដោយប្រជាពលរដ្ឋនៃឃុំ សង្កាត់របស់ខ្លួនតាមការបោះឆ្នោតជាទូទៅ ជាសកល ដោយសេរី ត្រឹមត្រូវយុត្តិធម៌ ដោយស្មើភាព ដោយចំពោះ និងដោយសម្ងាត់។ ការបោះឆ្នោតនេះត្រូវបានធ្វើឡើងរៀងរាល់ប្រាំឆ្នាំម្តង ដោយការបោះឆ្នោតនៅគ្រប់ឃុំ សង្កាត់ទាំងអស់ត្រូវធ្វើឡើងនៅថ្ងៃអាទិត្យតែមួយថ្ងៃគត់។[13] ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវអនុវត្តន៍តាមប្រព័ន្ធសមាមាត្រ ដោយបែងចែកអាសនៈតាមមធ្យមភាគខ្ពស់បំផុតក្រោមសមត្ថកិច្ច រៀបចំចាត់ចែង និងគ្រប់គ្រងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ ដំណើរការប្រព្រឹត្តិទៅនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់ និងត្រូវរៀបចំតាមលំដាប់លំដោយដូចតទៅៈ

---

[13] មាត្រា ៣ថ្មី នៃច្បាប់វិសោធនកម្ម ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

### ក. ការចុះឈ្មោះបេក្ខជនបោះឆ្នោត

បេក្ខជនដែលមានបំណងឈរឈ្មោះបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបញ្ចូលឈ្មោះរបស់ខ្លួនទៅក្នុងបញ្ជីបេក្ខជននៃគណៈបក្សនយោបាយដែលបានចុះបញ្ជីត្រឹមត្រូវតាមលក្ខខណ្ឌកំណត់ក្នុង ច្បាប់ស្តីពីគណៈបក្សនយោបាយ។[14] បន្ទាប់មកគណៈបក្សនយោបាយ ត្រូវដាក់ពាក្យសុំចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតដែលចុះហត្ថលេខាដោយប្រធានគណៈបក្សនយោបាយ ឬតំណាងដែលទទួលបានការផ្ទេរសិទ្ធិទៅជាគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតក្នុងរយៈពេលយ៉ាងតិច ៩០ មុនថ្ងៃបោះឆ្នោតដោយមានភ្ជាប់មកជាមួយនូវបញ្ជីរាយនាមបេក្ខជនដែលមានចំនួនយ៉ាងហោចណាស់ស្មើនឹងពីរដងនៃចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់។ ហើយប្រជាពលរដ្ឋទាំងពីរភេទ ដែលមានបំណងឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម:

- មានសញ្ជាតិខ្មែរពីកំណើត
- ចេះអាន និងសរសេរអក្សរខ្មែរ
- ចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតក្នុងឃុំ សង្កាត់ដែលខ្លួនមានបំណងឈរឈ្មោះ
- មានអាយុយ៉ាងតិច ២៥ឆ្នាំ គិតមកដល់ថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។

➢ **ចំណែកបេក្ខជនត្រូវហាមមិនអោយឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់រួមមាន៖**

- សមាជិករដ្ឋសភា ព្រឹទ្ធសភា សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ សមាជិករាជរដ្ឋាភិបាល និងចៅក្រម
- ប្រតិភូរាជរដ្ឋាភិបាល អភិបាល ឬអភិបាលរងរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ
- សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បុគ្គលិកបម្រើការងារក្នុងគណៈកម្មាធិការជាតិ រៀបចំការបោះឆ្នោត និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់
- មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងយោធាពលខេមរភូមិន្ទ ឬនគរបាលជាតិក្នុងមុខតំណែង។
- ព្រះសង្ឃ ឬបុព្វសាសនា
- ស្មៀនឃុំ សង្កាត់។

[14] មាត្រា ៤៩ ថ្មី នៃច្បាប់វិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០០៦

### ខ. ការរៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោត

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវរៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សាឃុំ សង្កាត់ឱ្យបានយ៉ាងតិច ៩០ ថ្ងៃមុនថ្ងៃបោះឆ្នោត។[15] បន្ទាប់ពីរៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់រួចគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវកំណត់រយៈពេលនៃការត្រួតពិនិត្យបញ្ជីឈ្មោះអ្នកបោះឆ្នោតសម្រាប់ឃុំ សង្កាត់នីមួយៗមិនត្រូវតិចជាង ១៥ថ្ងៃ ឡើយ។ ដើម្បីមានដែលសិទ្ធិចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ប្រជាពលរដ្ឋទាំងពីរភេទត្រូវបំពេញនូវលក្ខខណ្ឌដូចខាងក្រោម ៖

- មានសញ្ជាតិខ្មែរ
- មានអាយុ ១៨ឆ្នាំ ឡើងគិតមកដល់ថ្ងៃបោះឆ្នោត
- មិនស្ថិតក្នុងស្ថានភាពជាទណ្ឌិត ឬស្ថានភាពជាជនវិកលចរិកជាដើម។[16]

### ១.២.២.២.រចនាសម្ព័ន្ធ និងតួនាទីរដ្ឋបាលឃុំ សង្កាត់

រដ្ឋបាលឃុំ សង្កាត់នីមួយៗត្រូវមានរចនាសម្ព័ន្ធជាក់លាក់របស់ខ្លួន ដោយផ្អែកតាមបទបញ្ញត្តិដែលមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។ ក្រុមប្រឹក្សាឃុំ សង្កាត់មានសមាជិកពី ៥ ទៅ ១១ នាក់អាស្រ័យទៅតាមទំហំរបស់តំបន់ និងចំនួនប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុងឃុំ សង្កាត់នោះ។[17] ចំនួនជាក់ស្តែងនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានកំណត់ដោយអនុក្រឹត្យ។ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗមានប្រធាន ០១រូប ដែលហៅថា ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ហើយប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ គឺជាមេឃុំ ឬចៅសង្កាត់។[18] ឃុំ សង្កាត់ នីមួយៗមានមេឃុំ ឬចៅសង្កាត់ម្នាក់។ ស្ត្រី និងបុរសអាចជ្រើសរើសឱ្យធ្វើចៅសង្កាត់ដោយផ្អែកលើលទ្ធផលនៃការបោះឆ្នោត។ មេឃុំ ឬចៅសង្កាត់ មានជំនួយការ០២រូប គឺជំទប់ទី១ ឬចៅសង្កាត់រងទី១ និងជំទប់ទី២ ឬចៅសង្កាត់រងទី២។ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវរៀបចំជ្រើសរើសឱ្យមានមេភូមិម្នាក់សម្រាប់ភូមិនីមួយៗក្នុង ឃុំ សង្កាត់របស់ខ្លួន។ មេឃុំ ឬចៅសង្កាត់ អាចចាត់តាំងបង្កើតគណៈកម្មាធិការ ដើម្បីផ្តល់យោបល់ និងជួយកិច្ចការនានាតាមការចាំបាច់។[19]

---

[15] មាត្រា ៤៣ នៃច្បាប់វិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០០៦

[16] មាត្រា ១៩ ថ្មី នៃច្បាប់វិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០០៦

[17] មាត្រា១២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, ឆ្នាំ២០០១

[18] មាត្រា២៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, ឆ្នាំ២០០១

[19] មាត្រា២៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, ឆ្នាំ២០០១




### ក. ក្រុមប្រឹក្សាឃុំ សង្កាត់

ក្រុមប្រឹក្សាឃុំ សង្កាត់មានសមាជិក ៥,៧,៩ ឬ១១ នាក់ផ្អែកតាមទំហំរបស់តំបន់ និងចំនួនប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុងឃុំ សង្កាត់នោះ។ ចំនួនជាក់ស្តែងនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវកំណត់ដោយអនុក្រឹត្យ។ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗមានប្រធានមួយរូប ដែលហៅថាប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ហើយប្រធានក្រុមប្រឹក្សា ឃុំ សង្កាត់ គឺជាមេឃុំ ឬចៅសង្កាត់ ។

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់មានតួនាទីភារកិច្ចដូចខាងក្រោម ៖

- ធ្វើជាអធិបតីនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- ធានាថាក្រុមប្រឹក្សាឃុំ សង្កាត់បានប្រជុំយ៉ាងហោចណាស់ម្តងក្នុងមួយខែ

- ធានាឱ្យសម័យកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនដំណើរការបានត្រឹមត្រូវទៅតាមវិធាន និងស្រប តាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។
- រក្សារបៀបរៀបរយ និងសណ្តាប់ធ្នាប់ពេលប្រជុំ។[20]

- **សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់** មានតួនាទីភារកិច្ចដូចខាងក្រោម៖

- ធានាថាក្រុមប្រឹក្សាឃុំ សង្កាត់ប្រើប្រាស់អំណាច តួនាទី និងមុខងារដូចមានចែងក្នុងច្បាប់ និងលិខិត បទដ្ឋានពាក់ព័ន្ធ
- ចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- ធ្វើសហប្រតិបត្តិការជាមួយនឹងប្រជាពលរដ្ឋ។

ជាមួយគ្នានេះផងដែរក្រុមប្រឹក្សាឃុំ សង្កាត់ក៏អាចធ្វើប្រតិភូកម្មអំណាចដល់មេឃុំ ឬចៅសង្កាត់ផងដែរ។ លើសពីនេះទៅទៀតប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ធានាអោយមានកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់យ៉ាងតិចមួយ ដងក្នុងមួយខែជាដាច់ខាត ។ ហើយក្រុមប្រឹក្សាឃុំ សង្កាត់ក៏ត្រូវរៀបចំអនុវត្តន៍ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់របស់ ខ្លួនដោយចាត់វិធានការដូចជា វាយតម្លៃជាអាទិភាព និងសកម្មភាពអភិវឌ្ឍន៍ ប្រមូលផ្តុំសេចក្តីត្រូវការ និង កំណត់អាទិភាពនៃសេចក្តីត្រូវការទាំងនោះអោយបានជាក់លាក់ ដោយផ្អែកលើធនធានដែលមានស្រាប់ រៀបចំ កម្មវិធីអភិវឌ្ឍន៍ទៅក្នុងគម្រោងថវិកាឃុំ សង្កាត់ផ្តល់សេវា និងអភិវឌ្ឍន៍តាមថវិកាដែលសង្កាត់មានហើយត្រួត ពិនិត្យនិងវាយតម្លៃចំពោះលទ្ធផលក្រោយការអនុវត្ត។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើសេចក្តីរាយការណ៍ពីការ អភិវឌ្ឍជូនប្រជាពលរដ្ឋរបស់ខ្លួន និងធ្វើសេចក្តីរាយការណ៍ប្រចាំឆ្នាំ ក្រោយពីបានអនុម័តយល់ព្រមដោយក្រុម ប្រឹក្សាឃុំ សង្កាត់ និងចម្លងជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ហើយតម្កល់ទុកជាសាធារណៈចម្លងចែកជូនអង្គការ សមាគមន៍ និងសាធារណៈជនសំខាន់ដោយគិតត្រឹមថ្លៃដើម ។

### ខ.មេឃុំ ឬចៅសង្កាត់

ចំពោះមេឃុំ ចៅសង្កាត់វិញមានតួនាទីដូចជា អនុវត្តន៍សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។ ការធ្វើ សេចក្តីរាយការណ៍ពីសកម្មភាពការងាររបស់ខ្លួនអោយបានយ៉ាងតិចមួយខែម្តង។ ហើយក៏នៅមានការអនុវត្ត បទបញ្ញត្តិ និងគោលការណ៍នានាដែលបានទទួលពីក្រុមប្រឹក្សាឃុំ សង្កាត់នឹងការផ្តល់យោបល់ផ្សេងៗទៀត និង ជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការរៀបចំផែនការហិរញ្ញវត្ថុ និងចាត់ចែងអនុវត្តន៍តួនាទីមុខងារ និងសិទ្ធិ អំណាចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ព្រមទាំងកិច្ចការផ្សេងៗទៀត ដែលក្រុមប្រឹក្សាសង្កាត់បានប្រគល់ឱ្យ ។ ជាង នេះទៅទៀតមេឃុំ ឬចៅសង្កាត់ក៏ជាអ្នកអនុវត្តន៍ តាមគោលនយោបាយរបស់រដ្ឋ និងទទួលការធ្វើប្រតិភូកម្ម អំណាចពីក្រុមប្រឹក្សា ឃុំ សង្កាត់ ហើយអ្វីដែលសំខាន់នោះចៅសង្កាត់ក៏ជាមន្ត្រីអត្រានុកូលដ្ឋានផងដែរ។ ឃុំ

សង្កាត់នីមួយៗមានមេឃុំ ឬចៅ សង្កាត់ម្នាក់។ស្ត្រី និងបុរសអាចត្រូវបានជ្រើសរើសឱ្យធ្វើជាមេឃុំ ឬចៅសង្កាត់។ មេឃុំ ឬចៅសង្កាត់មាន តួនាទី ភារកិច្ចដូចខាងក្រោមៈ

- ធានាថាសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានអនុវត្តន៍
- រាយការណ៍អំពីការបំពេញការងារប្រចាំខែជូនក្រុមប្រឹក្សាឃុំ សង្កាត់
- ផ្ដល់យោបល់ និងជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់លើការងារកសាងផែនការ ការរៀបចំហិរញ្ញវត្ថុ និងការអនុវត្ត អំណាច តួនាទី និងមុខងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- បំពេញភារកិច្ចផ្សេងទៀតដែលក្រុមប្រឹក្សាឃុំ សង្កាត់ប្រគល់ឱ្យ
- ផ្ទេរសិទ្ធិដល់ជំទប់ ចៅសង្កាត់រងតាមឋានានុក្រមនៅពេលខ្លួនអវត្តមាន។[21]

**គ. ជំទប់ឃុំ ឬ ចៅសង្កាត់រង**

មេឃុំ ចៅសង្កាត់ត្រូវមានជំនួយការ ២រូបចាំបាច់នោះគឺៈ ជំទប់ទី១ ឬចៅសង្កាត់រងទី១ និងជំទប់ទី២ ឬចៅសង្កាត់រងទី២ ដែលមានតួនាទីភារកិច្ចដូចខាងក្រោមៈ

- **ជំទប់ទី១ ចៅសង្កាត់រងទី១ៈ**

- ទទួលជួយមេឃុំ ចៅសង្កាត់លើកិច្ចការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- មេឃុំ ឬចៅសង្កាត់អាចប្រគល់ភារកិច្ចបន្ថែមដល់ជំទប់ទី១ ឬចៅសង្កាត់រងទី១
- បំពេញការងារជាមេឃុំ ឬចៅសង្កាត់ស្ដីទីក្នុងករណីមេឃុំ ឬចៅសង្កាត់អវត្តមាន

- **ជំទប់រងទី២ ឬចៅសង្កាត់រងទី២**

- ជួយមេឃុំ ឬចៅសង្កាត់ក្នុងការងារផ្នែករដ្ឋបាល សេវាសង្គមកិច្ច សេវាសាធារណៈ និងកិច្ចការសណ្ដាប់ធ្នាប់សាធារណៈនៅក្នុងមូលដ្ឋាន
- មេឃុំ ឬចៅសង្កាត់អាចប្រគល់លើការងារបន្ថែមដល់ជំទប់ទី២ ឬចៅសង្កាត់ទី២
- បំពេញការងារជាមេឃុំ ឬចៅសង្កាត់ស្ដីទី ក្នុងករណីមេឃុំ ឬចៅសង្កាត់ និងជំទប់រងទី១ និងចៅសង្កាត់រងទី១ អវត្តមាន ។

**ឃ.គណៈកម្មាធិការនានា**

គណៈកម្មាធិការនានារបស់ ឃុំ សង្កាត់ ត្រូវបានបង្កើតឡើងក្នុងករណីដែលឃុំមាន ការចាំបាច់ក្នុងការអនុវត្តគោលនយោបាយរបស់ឃុំ សង្កាត់ហើយគណៈកម្មាធិការនានាមានតួនាទីផ្ដល់យោបល់ និងជួយការងារជាក់លាក់ណាមួយរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ដូចជា ការកសាងផែនការ និងថវិកាសង្កាត់ រាយការណ៍អំពីការអភិវឌ្ឍប្រចាំខែរបស់ខ្លួន និងផ្ដល់យោបល់ពីវិធានការដែលត្រូវអនុវត្តន៍ពាក់ព័ន្ធជាមួយនឹងការងារ។ មេឃុំ ឬចៅសង្កាត់អាចចាត់តាំងគណៈកម្មាធិការផ្ដល់យោបល់។ គណៈកម្មាធិការនេះមានសមាជិកយ៉ាងតិច ០៣នាក់

(អាចយកក្នុងចំណោម សមាជិកក្រុមប្រឹក្សា) ដើម្បីផ្តល់យោបល់ និងជួយការងារដល់ក្រុមប្រឹក្សាឃុំ សង្កាត់នឹងមេឃុំ ឬចៅសង្កាត់អំពីបញ្ហាជាក់លាក់ណាមួយ។

គណៈកម្មាធិការនានាមានតួនាទី ភារកិច្ចដូចខាងក្រោម៖

- ផ្តល់យោបល់ និងជួយការងារជាក់លាក់ណាមួយរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ដូចជា ការកសាងផែនការអភិវឌ្ឍន៍ និងថវិកា (គណៈកម្មាធិការកសាងផែនការ និងថវិកា) ជាដើម
- រាយការណ៍អំពីការអភិវឌ្ឍប្រចាំខែរបស់ខ្លួន
- ផ្តល់យោបល់ពីវិធានការត្រូវអនុវត្តន៍ដែលពាក់ព័ន្ធនឹងការងារ។

**ខ. ស្មៀនឃុំ សង្កាត់**

នៅគ្រប់ឃុំ សង្កាត់ទាំងអស់មិនមែនត្រឹមតែសង្កាត់ក្បាលកោះប៉ុណ្ណោះទេ ត្រូវមានបុគ្គលិករដ្ឋបាលក្រសួងមហាផ្ទៃ ដែលជាមន្ត្រីមុខងារសាធារណៈ តែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ហើយអាចផ្លាស់ប្តូរតាមសំណើររបស់មេឃុំ ចៅសង្កាត់ដោយផ្អែកតាមការសម្រេចពីក្រុមប្រឹក្សាឃុំ សង្កាត់នោះរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងចេញប្រកាសផ្លាស់ប្តូរ ។ ហើយស្មៀនឃុំជាមន្ត្រីក្របខណ្ឌរដ្ឋបាលរបស់ក្រសួងមហាផ្ទៃដែលចាត់អោយទៅបម្រើការងារជាជំនួយការរដ្ឋបាលឃុំ សង្កាត់ដែលមានភារកិច្ចធានានិរន្តភាពកិច្ចការរដ្ឋបាលឃុំ សង្កាត់។ ដូច្នេះស្មៀនឃុំ មានចៅហ្វាយពីរ គឺមន្ត្រីក្រសួងមហាផ្ទៃ និងក្រុមប្រឹក្សាឃុំ សង្កាត់។ ស្មៀនឃុំ សង្កាត់មានតួនាទី ដូចខាងក្រោម៖

- ជួយក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ឬចៅសង្កាត់ ជំទប់ ឬចៅសង្កាត់រង និងគណៈកម្មាធិការនានាបំពេញតួនាទី និងមុខងារស្របតាមតម្រូវការច្បាប់
- បំពេញការងាររដ្ឋបាល
- ធានាថាសេចក្តីសម្រេច និងការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ស្របទៅតាមលក្ខខណ្ឌច្បាប់
- ជួយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការរៀបចំ និងអនុវត្តន៍កិច្ចប្រជុំរបស់ក្រុមប្រឹក្សា និងគណៈកម្មាធិការនានារបស់ឃុំ សង្កាត់
- ចូលរួមកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ឬគណៈកម្មាធិការ លើកលែងតែទទួលបានការអនុញ្ញាតឱ្យអវត្តមានជាមុនពីក្រុមប្រឹក្សាឃុំ សង្កាត់ ឬមេឃុំ ចៅសង្កាត់
- ជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការរៀបចំឱ្យមានក្តារខៀនព័ត៌មានមួយ ឬច្រើនកន្លែង ដើម្បីបិទផ្សាយសេចក្តីជូនដំណឹង សេចក្តីសម្រេច និងលិខិតបទដ្ឋានផ្សេងៗរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។[22]

**ច. បុគ្គលិកឃុំ សង្កាត់**

ឃុំ សង្កាត់ អាចជ្រើសរើសបុគ្គលិកដើម្បីជួយសម្រួលកិច្ចការរបស់ខ្លួនបាន ប៉ុន្តែបុគ្គលិកប្រភេទនេះជាបុគ្គលិកដែលស្ថិតនៅក្រៅក្របខណ្ឌរដ្ឋ។ ការជ្រើសរើសនេះធ្វើឡើងតាមរយៈការសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ នោះផ្ទាល់ ។ បុគ្គលិកឃុំ សង្កាត់មានភារកិច្ចជួយកិច្ចការតាមសេចក្តីត្រូវការចាំបាច់នៃការងារ និងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងអាណត្តិ ហើយអាចបន្តការងារតាមការសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិបន្ទាប់។[23]

**ឆ. មេភូមិ**

ក្រុមប្រឹក្សាឃុំសង្កាត់នីមួយៗ ត្រូវរៀបចំជ្រើសរើសឱ្យមានមេភូមិមួយនាក់សម្រាប់ភូមិនីមួយៗនៅក្នុងសង្កាត់របស់ខ្លួន ។ មេភូមិមានតួនាទី ភារកិច្ចដូចខាងក្រោម៖

- ជាតំណាងឱ្យប្រជាពលរដ្ឋទាំងអស់ក្នុងភូមិ
- ជាអ្នកទំនាក់ទំនងរវាងភូមិ និងក្រុមប្រឹក្សាឃុំ សង្កាត់
- ទទួលការណែនាំ និងធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រុមប្រឹក្សាឃុំ សង្កាត់
- ចូលរួមក្នុងកិច្ចប្រជុំនានារបស់ឃុំ សង្កាត់នៅពេលដែលក្រុមប្រឹក្សាឃុំ សង្កាត់តម្រូវ ដើម្បីផ្តល់យោបល់អំពីកិច្ចការពាក់ព័ន្ធនឹងភូមិរបស់ខ្លួន
- ធ្វើសេចក្តីរាយការណ៍រាល់បញ្ហាដែលពាក់ព័ន្ធ និង ភូមិរបស់ខ្លួន ដើម្បីដាក់ចូលរបាយការណ៍ ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- ផ្តល់ព័ត៌មានដែលពាក់ព័ន្ធ និង ភូមិដល់ប្រជាពលរដ្ឋរបស់ខ្លួន
- ទទួលខុសត្រូវចំពោះកិច្ចការដែលបានប្រគល់ឱ្យដោយក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន ។

[20] មាត្រា ១៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលក្រុមប្រឹក្សាឃុំ សង្កាត់ ២០២១

[21] ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ តាមបែបវិមជ្ឈការ ២០១៧ ទំព័រទី១៣

[22] ប្រកាសលេខ ១៣២៩ ប្រ.ក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០១ ស្តីពីតួនាទី ភារកិច្ច និងសិទ្ធិរបស់ស្មៀនឃុំ សង្កាត់

[23] មាត្រា២៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, ឆ្នាំ២០០១

### ១.២.២.៣ តួនាទី មុខងារ និងអំណាចរបស់រដ្ឋបាលឃុំ សង្កាត់

ផ្អែកតាមបញ្ញត្តិនៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់ ក្រុមប្រឹក្សា ឃុំ សង្កាត់ ត្រូវបានផ្ទេរឱ្យនូវ តួនាទី មុខងារ និងអំណាចមួយចំនួនសម្រាប់បម្រើប្រជាពលរដ្ឋ និងការអភិវឌ្ឍនៅក្នុងមូលដ្ឋានរបស់ខ្លួន។

រដ្ឋបាល ឃុំ សង្កាត់ មានតួនាទីជម្រុញនឹងគាំពារអភិបាលកិច្ចល្អដោយចាត់ចែងប្រើប្រាស់ធនធានប្រកបដោយចីរភាពសម្រាប់បំពេញសេចក្តីត្រូវការជាមូលដ្ឋានក្នុង ឃុំ សង្កាត់ របស់ខ្លួនបម្រើនូវផលប្រយោជន៍របស់ប្រជាពលរដ្ឋ និងគោរពប្រយោជន៍ជាតិស្របតាមគោលនយោបាយទូទៅរបស់រដ្ឋ។[24]

#### ក. អំណាចរដ្ឋបាលឃុំ សង្កាត់

រដ្ឋបាលឃុំ សង្កាត់ ត្រូវដឹកនាំគ្រប់គ្រងដោយក្រុមប្រឹក្សាឃុំ សង្កាត់។ រដ្ឋបាលឃុំ សង្កាត់មានអំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិ ។

- **អំណាចបញ្ញត្តិរបស់ឃុំ សង្កាត់** ត្រូវធ្វើឡើងតាមរយៈដីកាឃុំ សង្កាត់តាមការសម្រេចរបស់ក្រុមប្រឹក្សាឃុំសង្កាត់ហើយត្រូវចុះហត្ថលេខាដោយមេឃុំ ចៅសង្កាត់សម្រាប់គ្រប់គ្រងកិច្ចការនានាក្នុងក្របខណ្ឌតួនាទីមុខងារ និងអំណាចរបស់ខ្លួនដែលច្បាប់បានប្រគល់ឱ្យ។ ដីកាឃុំ សង្កាត់មានប្រសិទ្ធភាពអនុវត្តន៍តែនៅក្នុងរង្វង់ដែនដីរបស់ខ្លួនប៉ុណ្ណោះ។ ដីកាឃុំ សង្កាត់មិនត្រូវផ្ទុយពី សន្ធិសញ្ញា អនុសញ្ញាអន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ស្មារតីរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋាននានាដែលពាក់ព័ន្ធឡើយ។ បើដីកាណាមួយដែលផ្ទុយពីបទដ្ឋានគតិយុត្តខាងលើនេះដីកានោះនឹងត្រូវឮ ចាត់ទុកជាមោឃៈដាច់ខាត ។
- **អំណាចប្រតិបត្តិរបស់ឃុំ សង្កាត់** មានន័យថារដ្ឋបាលឃុំ សង្កាត់មានសិទ្ធអនុវត្តន៍សេចក្តីសម្រេចរបស់ខ្លួននៅក្នុងក្របខណ្ឌ តួនាទី មុខងារ និងអំណាចរបស់ខ្លួនដែលច្បាប់បានប្រគល់ឱ្យ។ អំណាចប្រតិបត្តិនេះត្រូវបានធ្វើប្រតិភូកម្មឱ្យទៅចៅសង្កាត់ជាអ្នកអនុវត្តន៍ក្នុងនាមក្រុមប្រឹក្សាឃុំសង្កាត់របស់ខ្លួន។

ព្រំដែននៃអំណាចរបស់រដ្ឋបាលឃុំ សង្កាត់អាចធ្វើសកម្មភាពបានតែនៅក្នុងក្របខណ្ឌ អំណាច តួនាទី និងមុខងារដែលច្បាប់បានប្រគល់ឱ្យប៉ុណ្ណោះ។ ពោល គឺរដ្ឋបាលឃុំសង្កាត់មិនអាចធ្វើសកម្មភាពណាមួយដែលផ្ទុយនឹងគោលការណ៍ និងបទបញ្ញត្តិដែលបានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញច្បាប់ ព្រះរាជក្រឹត្យ ប្រកាស លិខិតបទដ្ឋាននានាឡើយ។[25]

---

[24] មាត្រា៤១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១

[25] មាត្រា ៤៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១

- **រដ្ឋបាលឃុំ សង្កាត់គ្មានអំណាចសម្រេចលើវិស័យដូចជាៈ**

- ព្រៃឈើប្រៃសណីយ៍ និងទូរគមនាគមន៍
- ការពារជាតិ
- សន្តិសុខជាតិ
- រូបិយវត្ថុ
- នយោបាយក្រៅប្រទេស
- គោលនយោបាយសារពើពន្ធ ។
- វិស័យផ្សេងទៀតដែលមានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធ។

### ខ. តួនាទី និងមុខងាររបស់រដ្ឋបាលឃុំ សង្កាត់

រដ្ឋបាល ឃុំ សង្កាត់ មានតួនាទីពីរប្រភេទ គឺតួនាទីបំរើកិច្ចការមូលដ្ឋាន និងតួនាទីជាភ្នាក់ងារតំណាងរដ្ឋ។

- **តួនាទីបម្រើកិច្ចការមូលដ្ឋាន**

រដ្ឋបាល ឃុំ សង្កាត់ មានភារកិច្ចធានារក្សាសន្តិសុខសណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ។ ហើយរៀបចំចាត់ចែងសេវាសាធារណៈចាំបាច់ និងមើលការខុសត្រូវឱ្យកិច្ចការទាំងនោះដំណើរការបានល្អ។ ផ្តល់នូវការលើកទឹកចិត្តឱ្យមានការបង្កើតផាសុកភាព និងសុខុមាភាពរបស់ប្រជាពលរដ្ឋដោយជំរុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងលើកកម្ពស់នៅជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ដើម្បីការពារថែរក្សាបរិស្ថានធនធានធម្មជាតិ វប្បធម៌ បេតិកភណ្ឌជាតិ និងសម្របសម្រួលទស្សនៈរបស់ប្រជាពលរដ្ឋឱ្យមានការយោគយល់អធ្យាស្រ័យទៅវិញទៅមក។ បំពេញកិច្ចការជាទូទៅ ដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ[26]។

- **តួនាទីជាភ្នាក់ងារតំណាងរដ្ឋ**

រដ្ឋបាលឃុំ សង្កាត់ជាភ្នាក់ងារមួយតំណាងរដ្ឋដែលមានភារកិច្ច អនុវត្តន៍ទៅតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានដែលពាក់ព័ន្ធ។ ក្នុងករណីនេះអាជ្ញាធររដ្ឋអាចធ្វើប្រតិភូកម្មអំណាចដល់ឃុំ សង្កាត់ដោយភ្ជាប់ជាមួយនូវការបង្កើនសមត្ថភាព និងផ្គត់ផ្គង់ មធ្យោបាយ សម្ភារៈ ថវិកាសម្រាប់អនុវត្តន៍។ ប្រតិភូកម្មខាងលើនេះត្រូវផ្តល់ចំពោះតែសមូហភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់តែប៉ុណ្ណោះ ។

[26] មាត្រា៤៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១

### ១.២.៣ កិច្ចការរដ្ឋបាលឃុំ សង្កាត់

កិច្ចការរដ្ឋបាលរបស់ឃុំ សង្កាត់ មានដូចជា លិខិតបទដ្ឋានគតិយុត្ត លិខិតរដ្ឋបាល ការគ្រប់គ្រងបុគ្គលិក ការគ្រប់គ្រងឯកសារ ការគ្រប់គ្រងសម្ភារៈបរិក្ខារ និងការរៀបចំកិច្ចប្រជុំជាដើម។

#### ១.២.៣.១ លិខិតបទដ្ឋានគតិយុត្ត ឃុំ សង្កាត់

លិខិតបទដ្ឋានគតិយុត្តរបស់រដ្ឋបាលឃុំ សង្កាត់ គឺជាលិខិតដែលកំណត់នូវវិធានបទបញ្ញត្តិ បទបញ្ជា ឬគោលការណ៍នានាសម្រាប់ការគ្រប់គ្រង ការតែងតាំង ការបង្កើតឡើងនូវយន្តការ និងការណែនាំអនុវត្តន៍កិច្ចការនានា ។ ប្រភេទលិខិតបទដ្ឋានគតិយុត្តរបស់រដ្ឋបាលឃុំ សង្កាត់មានដូចជា៖

##### ក. ដីកាឃុំ សង្កាត់

ដីកាឃុំ សង្កាត់ គឺជាលិខិតបទដ្ឋានគតិយុត្ត ដែលកំណត់នូវបទបញ្ញត្តិទាំងឡាយដែលរដ្ឋបាល ឃុំ សង្កាត់ បង្កើតឡើងសំដៅបម្រើផលប្រយោជន៍ប្រជាពលរដ្ឋទូទៅក្នុងឃុំ សង្កាត់ ដោយស្មើភាពមិនរើសអើង និងសម្រាប់គ្រប់គ្រងកិច្ចការនានាក្នុងក្របខណ្ឌតួនាទី មុខងារ និងអំណាចអនុវត្តន៍ក្នុងរង្វង់ដែនដីរបស់ខ្លួន។ ដីកាឃុំ សង្កាត់មិនត្រូវផ្ទុយ និងច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តនានារបស់រដ្ឋឡើយ។ ដីការបស់ឃុំ សង្កាត់ ត្រូវចុះហត្ថលេខាដោយមេឃុំ ចៅសង្កាត់តាមការសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ដែលមានចំនួនលើសពីពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូល ។

##### ខ. សេចក្តីសម្រេចឃុំ សង្កាត់

សេចក្តីសម្រេចឃុំ សង្កាត់ គឺជាលិខិតបទដ្ឋានគតិយុត្តដែលបង្កើតឡើង ដើម្បីអនុវត្តន៍ដីការបស់ខ្លួន ឬលិខិតបទដ្ឋាននានារបស់រដ្ឋ ឬចែងអំពីការបង្កើត ការតែងតាំង ការរៀបចំ ឬការគ្រប់គ្រងកិច្ចការនានាក្នុងក្របខណ្ឌ តួនាទី មុខងារ និងអំណាចអនុវត្តន៍ក្នុងរង្វង់ដែនដីរបស់ខ្លួន ។

សេចក្តីសម្រេចមានលក្ខណៈប្រហាក់ប្រហែល និងដីកាឃុំ សង្កាត់ដែរ ប៉ុន្តែមានឋានានុក្រមទាបជាងដីកា និងខ្ពស់ជាងលិខិតរដ្ឋបាលសាមញ្ញធម្មតាផ្សេងៗទៀតក្នុងឃុំ សង្កាត់ ។ សេចក្តីសម្រេច ឃុំ សង្កាត់មិនត្រូវផ្ទុយនឹងច្បាប់ ឬលិខិតបទដ្ឋាននានារបស់រដ្ឋ និងដីការបស់ខ្លួនឡើយ ។ សេចក្តីសម្រេចរបស់ ឃុំ សង្កាត់ត្រូវចុះហត្ថលេខាដោយមេឃុំ ចៅសង្កាត់តាមការសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ដែលមានចំនួនលើសពីពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សា ឃុំ សង្កាត់ ទាំងមូល។ ក្នុងករណីប្រធានសក្តិបន្ទាន់បំផុតដែលមិនអាចកោះប្រជុំក្រុមប្រឹក្សា ឃុំ សង្កាត់ បានមេឃុំ ឬចៅសង្កាត់អាចចេញសេចក្តីសម្រេច ដើម្បីដោះស្រាយស្ថានភាពបន្ទាន់នោះ។ សេចក្តីសម្រេចនេះ និងត្រូវបានដាក់ជូនកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់នៅកិច្ចប្រជុំបន្ទាប់ដើម្បីពិនិត្យឡើងវិញអំពីភាពមិនត្រឹមត្រូវតាមច្បាប់។[27]

### ១.២.៣.២. លិខិតរដ្ឋបាល ឃុំ សង្កាត់

**លិខិតរដ្ឋបាល** គឺជាលិខិតដែលរៀបចំតាក់តែងឡើងជាលាយលក្ខណ៍អក្សរសម្រាប់ជាមធ្យោបាយទំនាក់ទំនងផ្លូវការរបស់រដ្ឋបាលឃុំ សង្កាត់ជាមួយស្ថាប័ន អង្គភាពនឹងបុគ្គលនានាក្នុងគោលបំណងជូនព័ត៌មាន ណែនាំ អញ្ជើញរាយការណ៍ ផ្សព្វផ្សាយ ឆ្លើយតប ឬចាត់តាំង បុគ្គលណាមួយអោយទៅបំពេញបេសកម្ម ។

- **លិខិតរដ្ឋបាល ឃុំ សង្កាត់** ដែលប្រើប្រាស់ជាផ្លូវការរួមមាន លិខិតស្នើ លិខិតជូនដំណឹង ឬសេចក្តីជូនដំណឹង លិខិតអញ្ជើញ លិខិតបញ្ជាបេសកម្ម របាយការណ៍ កំណត់ហេតុ លិខិតផ្ទេរសិទ្ធិ និងដីកាអម ។
- **លិខិតស្នើ** ៖ គឺជាលិខិតដែលឃុំ សង្កាត់រៀបចំឡើងដើម្បីបង្ហាញពីគោលបំណងនឹងមូលហេតុនៃតម្រូវការជាក់លាក់ណាមួយរបស់ខ្លួនថ្លែងទៅកាន់រូបវន្តបុគ្គល នីតិបុគ្គលសាធារណៈឯកជន ក្រសួងស្ថាប័ន អង្គការ ឬសង្គមស៊ីវិលដែលមានសិទ្ធិអំណាចសម្រេច ឬដោះស្រាយចំពោះការស្នើសុំនោះ ។
- **សេចក្តីជូនដំណឹង៖** គឺជាលិខិតដែលឃុំ សង្កាត់រៀបចំឡើង ដើម្បីធ្វើការទំនាក់ទំនងជាមួយបុគ្គល ក្រសួង ស្ថាប័ន អង្គការសង្គមស៊ីវិល មានខ្លឹមសារជាការឆ្លើយបំភ្លឺចំពោះបញ្ហា ឬជាការឆ្លើយតបចំពោះសំណើរឬជាការជូនដំណឹងអោយសាធារណៈជន បានដឹងនូវព័ត៌មានទាំងឡាយដែលឃុំ សង្កាត់ត្រូវការផ្សព្វផ្សាយ ។
- **លិខិតអញ្ជើញ**៖ គឺជាលិខិតដែល ឃុំ សង្កាត់ រៀបចំឡើងដើម្បីធ្វើការអញ្ជើញបុគ្គល ឬតំណាងក្រសួងស្ថាប័ន អង្គការសង្គមស៊ីវិលឱ្យចូលរួមក្នុងសកម្មភាពរបស់ឃុំ សង្កាត់ចំពោះកិច្ចការដែលពាក់ព័ន្ធទៅនិងបុគ្គល ឬអង្គភាពទាំងនោះដោយមានបញ្ជាក់ឈ្មោះ និងឋានៈ (អ្នកដែលត្រូវអញ្ជើញ) ទីកន្លែងប្រជុំឬប្រារព្ធពិធី កាលបរិច្ឆេទកម្មវិធី ឬរបៀបវារៈប្រជុំ (និងអាចមានឯកសារដែលពាក់ព័ន្ធ និង ការប្រជុំភ្ជាប់ជាមួយ)។
- **លិខិតបញ្ជាបេសកម្ម**៖ គឺជាលិខិតដែលឃុំ សង្កាត់រៀបចំឡើង ដើម្បីចាត់តាំងមន្ត្រីបុគ្គលិកឃុំ សង្កាត់ឱ្យចូលរួមក្នុងសកម្មភាពនានា នៅក្រៅឃុំ សង្កាត់។ លិខិតនេះ មានភ្ជាប់ជាមួយនូវទិដ្ឋាការធ្វើដំណើរ។ ទិដ្ឋាការធ្វើដំណើរ គឺជាលិខិតរដ្ឋបាលមួយប្រភេទសម្រាប់ឱ្យអ្នកដែលមានភារកិច្ចទៅបំពេញបេសកម្មយកទៅចុះទិដ្ឋាការនូវទីកន្លែង ការបរិច្ឆេទ មធ្យោបាយធ្វើដំណើរ និង ហត្ថលេខារបស់អង្គភាពមានសមត្ថកិច្ចដែលបានអនុញ្ញាត និងអង្គភាពដែលបានទទួលដឹងលឺអំពីការចេញដំណើរ និង ការមកដល់ពីដំណាក់មួយមកដំណាក់មួយទៀត។ នៅពេលត្រឡប់មកវិញត្រូវធ្វើរបាយការណ៍ ឬរាយការណ៍ជូន

ចៅសង្កាត់ ឬ ក្រុមប្រឹក្សា ឃុំ សង្កាត់ អោយបានជ្រាបអំពីលទ្ធផល ឬបញ្ហាសំខាន់ៗដែលខ្លួនបានទៅចូលរួម ។

[27]ដកស្រង់ចេញពីសៀវភៅ ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ ឆ្នាំ២០១៧ ទំព័រ២០

- **របាយការណ៍**៖ គឺជាសេចក្តីរាយការអំពីសកម្មភាពដំណើរការ និងលទ្ធផលការងាររបស់ ឃុំ សង្កាត់ ឬ បុគ្គលិកណាម្នាក់ឬមួយក្រុមដែលរដ្ឋបាល ឃុំ សង្កាត់ បានបំពេញ ឬបានចាត់តាំងឱ្យទៅបំពេញ ដើម្បីរាយការណ៍ជូនថ្នាក់ដឹកនាំ និងអង្គភាពពាក់ព័ន្ធ ។
- **កំណត់ហេតុ**៖ គឺជាការកត់ត្រាស្រង់យកមតិយោបល់សេចក្តីសម្រេច និងការឯកភាពលើសកម្មភាពដែលត្រូវអនុវត្តន៍ពីគ្រប់សមាជិកអង្គប្រជុំ និងការសម្រេចរបស់អង្គប្រជុំ ឬជាការកត់ត្រារាល់ហេតុការណ៍ណាមួយដែលបានកើតឡើងជាក់ស្តែង ដើម្បីរក្សាទុកជាសក្ខីភាពនៅពេលដែលមានតម្រូវការ ។
- **លិខិតផ្ទេរសិទ្ធិ** ៖ គឺជាលិខិតរបស់មេឃុំ ចៅសង្កាត់ប្រកាសជាលាយលក្ខណ៍អក្សរប្រគល់សិទ្ធិឱ្យជំទប់ចៅសង្កាត់រងតាមឋានានុក្រម ដើម្បីធ្វើចៅសង្កាត់ស្តីទីក្នុងអំឡុងពេលដែលចៅសង្កាត់អវត្តមាន។
- **ដីការអម** គឺជាឯកសាររដ្ឋបាលដែលឃុំ សង្កាត់រៀបចំឡើងផ្ញើអមភ្ជាប់ជាមួយសំណុំលិខិតដែលត្រូវផ្ញើចេញទៅអោយអង្គភាព ក្រសួង ស្ថាប័នណាមួយដោយមានកត់ត្រាឈ្មោះ និងចំនួនលិខិត (ឯកសារ ) លើដីការអមនោះ។ ឃុំ សង្កាត់ប្រើដីការអម ដើម្បីចៀសវាងការបាត់បង់ឯកសារដែលរដ្ឋបាលឃុំ សង្កាត់ផ្ញើចេញ ។

### ១.២.៣.៣ ការគ្រប់គ្រងបុគ្គលិក ឯកសារ និងសម្ភារៈបរិក្ខាររបស់ ឃុំ សង្កាត់

#### ក. ការគ្រប់គ្រងបុគ្គលិកឃុំ សង្កាត់

រដ្ឋបាលឃុំ សង្កាត់មានបុគ្គលិកពីរប្រភេទ គឺស្មៀនដែលរាជរដ្ឋាភិបាលបានបញ្ជូនឱ្យមកធ្វើការក្នុងឃុំ សង្កាត់ និងបុគ្គលិករបស់ឃុំ សង្កាត់ផ្ទាល់។ ស្មៀនឃុំគ្មានសិទ្ធិគ្រប់គ្រងលើបុគ្គលិកផ្ទាល់របស់ ក្រុមប្រឹក្សាឃុំ សង្កាត់ទេ។ ករណីដែលក្រុមប្រឹក្សាឃុំ សង្កាត់ និងស្មៀនមានភាពមិនចុះសម្រុងគ្នាក្រុមប្រឹក្សាឃុំ សង្កាត់មានសិទ្ធិស្នើសុំផ្លាស់ប្តូរស្មៀន ហើយក្រសួងមហាផ្ទៃត្រូវតែឆ្លើយតបជាវិជ្ជមានចំពោះការស្នើសុំនេះ។ ដូច្នេះការចាត់ចែងរបៀបនេះនាំឱ្យមានតុល្យភាព អំណាចរវាងក្រុមប្រឹក្សាឃុំ សង្កាត់ និងស្មៀនក្នុងការងាររដ្ឋបាលប្រចាំថ្ងៃ និងការធ្វើសេចក្តីសម្រេចនានា។ ក្របខណ្ឌច្បាប់មិនបានចែងលំអិតអំពីប្រព័ន្ធគ្រប់គ្រងបុគ្គលិករបស់ក្រុមប្រឹក្សាឃុំ សង្កាត់ទេច្បាប់គ្រាន់តែបញ្ជាក់ថាក្រុមប្រឹក្សាឃុំ សង្កាត់អាចជួលបុគ្គលិករបស់ខ្លួនផ្ទាល់ស្ថិតក្រោមការចាត់ចែងសព្វថ្ងៃនេះក្រុមប្រឹក្សាឃុំ សង្កាត់អាចជួលគណនេយ្យករអោយជួយគ្រប់គ្រងចំណូលដែលសង្កាត់ដែលរកបាន។

**ខ.ការគ្រប់គ្រងឯកសារ**

ការគ្រប់គ្រងឯកសារ គឺជាការរៀបចំទុកដាក់ថែរក្សាឯកសារទាំងឡាយណា តាមប្រព័ន្ធមួយដែលមានសណ្តាប់ធ្នាប់ និងសុវត្ថិភាព ។ ការគ្រប់គ្រងឯកសាររបស់ឃុំ សង្កាត់ផ្តល់ផលប្រយោជន៍មួយចំនួនដូចជា៖

- បង្កលក្ខណៈងាយស្រួលក្នុងការស្វែងរកព័ត៌មាន និងទិន្នន័យសម្រាប់ដឹកនាំនៅក្នុងការពិភាក្សា និងការធ្វើសេចក្តីសម្រេច។
- ជួយបន្តនិរន្តរភាពព័ត៌មាននៅពេលមានអ្នកមកកាន់ការងារថ្មី និងអ្នកផ្លាស់ចេញដោយផ្តល់នូវភស្តុតាងជាក់លាក់ពីកិច្ចការ ឬព្រឹត្តការណ៍ដែលកើតរួចមកហើយបង្កើនប្រសិទ្ធភាព និងសន្សំពេលវេលាដល់ការងាររដ្ឋបាលឃុំ សង្កាត់។

**គ.ការគ្រប់គ្រងសម្ភារៈបរិក្ខារ ឃុំ សង្កាត់**

គ្រប់សម្ភារៈបរិក្ខាររបស់ឃុំ សង្កាត់ត្រូវចុះបញ្ជីអោយបានត្រឹមត្រូវ។ ហើយបញ្ជីគ្រប់គ្រងបរិក្ខារនេះត្រូវរក្សាទុកអោយបានល្អប្រកបដោយសុវត្ថិភាព និងធ្វើបច្ចុប្បន្នជាប្រចាំ ។ គ្រប់សម្ភារៈបរិក្ខាររបស់ឃុំ សង្កាត់ដែលកាត់ចេញពីបញ្ជីត្រូវធ្វើឡើងស្របតាមនីតិវិធី និងត្រូវសម្រេចដោយកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ។

**១.២.៣.៤ ការរៀបចំកិច្ចប្រជុំក្រុមប្រឹក្សា ឃុំ សង្កាត់**

ក្រុមប្រឹក្សា ឃុំ សង្កាត់ ត្រូវធ្វើការប្រជុំយ៉ាងតិចចំនួនមួយដងក្នុងមួយខែហើយការប្រជុំក្រុមប្រឹក្សា ឃុំ សង្កាត់ ត្រូវធ្វើឡើងជាសាធារណៈ និងមានលក្ខណៈប្រជាធិបតេយ្យ។ ក្រៅពីកិច្ចប្រជុំជាសាធារណៈនេះក្រុមប្រឹក្សា ឃុំ សង្កាត់ក៏អាចប្រជុំជាសម្ងាត់បានដែរ។

**ក. ប្រភេទនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សា**

កិច្ចប្រជុំក្រុមប្រឹក្សាមាន ០២ ប្រភេទគឺ ៖

- **កិច្ចប្រជុំសាមញ្ញ** ៖ ជាកិច្ចប្រជុំដែលរៀបចំឡើងជាទៀងទាត់យ៉ាងហោចណាស់ម្តងក្នុង មួយខែ។
- **កិច្ចប្រជុំពិសេស** ៖ ជាកិច្ចប្រជុំដែលរៀបចំឡើងសម្រាប់ពិភាក្សាការងារពិសេស ឬការងារបន្ទាន់ក្នុងករណីចាំបាច់ណាមួយ។ កិច្ចប្រជុំទាំងពីរប្រភេទនេះអាចរៀបចំជាសាធារណៈ និងជាសម្ងាត់។ កិច្ចប្រជុំជាសម្ងាត់ជាកិច្ចប្រជុំដែលរៀបចំឡើងសម្រាប់ពិភាក្សាលើបញ្ហាមួយចំនួនដូចជា៖ ការដាក់វិន័យ ឬបញ្ឈប់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ បញ្ហាសន្តិសុខក្នុងឃុំ សង្កាត់ការរៀបចំសំណុំរឿង ដើម្បីតវ៉ា ឬការពារក្តីអ្វីមួយ និងការដោះស្រាយបញ្ហាដែលពាក់ព័ន្ធនឹងកិត្តិយសបុគ្គលជាដើម។

### ខ. នីតិវិធីនៃការរៀបចំកិច្ចប្រជុំ

☞ **ការត្រៀមរៀបចំកិច្ចប្រជុំ លិខិតអញ្ជើញ៖** មេឃុំ ឬចៅសង្កាត់ត្រូវតែធានាថាលិខិតអញ្ជើញត្រូវបានរៀបចំនឹងផ្ញើជូនដល់អ្នកដែលត្រូវចូលរួមប្រជុំគ្រប់គ្នាទាំងអស់មុនពេលប្រជុំ។ នៅក្នុងលិខិតអញ្ជើញត្រូវតែបញ្ជាក់ឱ្យបានច្បាស់អំពីពេលវេលា ទីកន្លែង និងបញ្ហាសំខាន់ៗដែលត្រូវពិភាក្សា ឬជម្រាបនៅពេលប្រជុំ។

☞ **ការបង្កើតរបៀបវារៈប្រជុំ៖** គ្រប់ការប្រជុំទាំងអស់ ត្រូវតែមានរបៀបវារៈហើយត្រូវផ្ញើជូនដល់អ្នកចូលរួមជាមុន ។ ជាការប្រសើរអ្នកចូលរួមគួរមានឱកាសចូលរួមក្នុងការរៀបចំរបៀបវារៈ។

ចំណុចមួយចំនួនដែលយើងគួរតែលើកមកក្នុងការបង្កើតរបៀបវារៈរួមមានដូចជា៖

- ការងារដែលត្រូវពិភាក្សា និងសម្រេច
- ព័ត៌មានដែលត្រូវជំរាប
- ពេលវេលាសម្រាប់កិច្ចប្រជុំ ។

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ច្រើនជាងមួយភាគបីអាចបន្ថែមប្រធានបទផ្សេងទៀត ដែលស្ថិតនៅក្នុងចំណោមអំណាច និងមុខងាររបស់ខ្លួនដើម្បីដាក់បញ្ចូលទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់។

### គ. ការប្រព្រឹត្តទៅនៃកិច្ចប្រជុំ

• សមាជិករបស់អង្គប្រជុំសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចូលរួមរាល់កិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់នឹងអាចអវត្តមានបានលុះត្រាតែមានការអនុញ្ញាតជាមុន។

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់មានសិទ្ធិបញ្ចេញមតិនឹងនិយាយដោយគ្មានការភ័យខ្លាច ការរំខាន ឬការបំភិតបំភ័យឡើយ។ ប្រធានក្រុមប្រឹក្សា ឃុំ សង្កាត់ ឬប្រធានក្រុមប្រឹក្សា ឃុំ សង្កាត់ ស្តីទីត្រូវដឹកនាំរាល់កិច្ចប្រជុំ។ ស្មៀនឃុំ សង្កាត់ នឹងបុគ្គលិកដទៃទៀតរបស់ឃុំ សង្កាត់មានសិទ្ធិចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សានេះ។ ប្រជាពលរដ្ឋមានសិទ្ធិចូលរួមកិច្ចប្រជុំក្រុមប្រឹក្សា ឃុំ សង្កាត់ លើកលែងតែកិច្ចប្រជុំដែលធ្វើជាសម្ងាត់។ ស្មៀនឃុំ សង្កាត់នឹងប្រជាពលរដ្ឋមិនត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងការសម្រេចចិត្ត និងការបោះឆ្នោតក្នុងអង្គប្រជុំឡើយ។

នីត្យានុកូលភាពនៃកិច្ចប្រជុំក្រុមប្រឹក្សា ឃុំ សង្កាត់ កិច្ចប្រជុំក្រុមប្រឹក្សា ឃុំ សង្កាត់ ប្រព្រឹត្តទៅស្របច្បាប់ត្រូវ មានសមាជិកក្រុមប្រឹក្សា ឃុំ សង្កាត់ លើសពីពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូលចូលរួមក្នុងកិច្ចប្រជុំនោះ។

| ចំនួនសមាជិកក្រុមប្រឹក្សា ឃុំ សង្កាត់ | ចំនួនសមាជិកក្រុមប្រឹក្សា ឃុំ សង្កាត់ ចូលរួមយ៉ាងតិច |
|---|---|
| ៥ រូប | ៣ រូប |
| ៧ រូប | ៤ រូប |
| ៩ រូប | ៥ រូប |
| ១១ រូប | ៦ រូប |

កិច្ចប្រជុំក្រុមប្រឹក្សា ឃុំ សង្កាត់ ត្រូវប្រព្រឹត្តទៅតាមលំដាប់លំដោយដូចខាងក្រោម ៖

- បញ្ជាក់អះអាងថាកិច្ចប្រជុំប្រព្រឹត្តទៅដោយស្របច្បាប់ពិនិត្យ និងអនុម័តតាមរបៀបវារៈនៃកិច្ចប្រជុំ
- ពិនិត្យនិងអនុម័ត កំណត់ហេតុនៅក្នុងកិច្ចប្រជុំ លើកមុនប្រធានក្រុមប្រឹក្សាត្រូវចុះហត្ថលេខាលើកំណត់ហេតុនោះ។
- ពិភាក្សាតាមរបៀបវារៈនីមួយៗដូចជា ពិនិត្យឯកសារនឹងលិខិតផ្សេង ដែលបានដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងសម្រេច។
- ព្រមទាំងបញ្ហាផ្សេងៗ។

**ការដឹកនាំកិច្ចប្រជុំ៖** ប្រធានក្រុមប្រឹក្សាត្រូវធានាថាកិច្ចប្រជុំ ប្រព្រឹត្តទៅមានលក្ខណៈ ប្រជាធិបតេយ្យ មានសណ្តាប់ធ្នាប់ល្អ និងគ្មានការរំខាន។ អ្នកដឹកនាំកិច្ចប្រជុំល្អត្រូវបំពេញកិច្ចការមួយចំនួនដូចខាងក្រោម ៖

- ធានាថាអ្នកចូលរួមគ្រប់រូបមានសិទ្ធិបញ្ចេញមតិ ហើយមតិរបស់ពួកគេត្រូវបានគេពិចារណា។
- ធានាថាស្ត្រី និងបុរសមានឱកាសស្មើគ្នាក្នុងការបញ្ចេញមតិ។
- មានលទ្ធភាពធ្វើការប្រាស្រ័យទាក់ទងគ្នាដោយច្បាស់លាស់ នឹងយ៉ាងប៉ិនប្រសប់។
- សម្របសម្រួលការពិភាក្សា ដោយលើកយកបញ្ហានៅក្នុងរបៀបវារៈមកពិនិត្យម្តងមួយ ហើយពិភាក្សាបញ្ហានោះយ៉ាងល្អិតល្អន់។
- បោះឆ្នោតលើបញ្ហាណាដែលសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់មិនឯកភាពគ្នា។
- ប្រើប្រាស់ពេលវេលាដែលមានឱ្យបានល្អ ដើម្បីកុំឱ្យកិច្ចប្រជុំពេលវេលានៃការប្រជុំចំណាយពេលវេលាច្រើនជាងការចាំបាច់។

- ធានាថាប្រជាពលរដ្ឋ ដែលបានអញ្ជើញមកចូលរួមនៅក្នុងការពិភាក្សាលើបញ្ហាដាក់លាក់មួយ និងមានឱកាសសួរសំណួរ។ ចំនួនប្រជាពលរដ្ឋដែលអាចដាក់ស្នើបញ្ចូលបញ្ហាទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំក្រុមប្រឹក្សា ឃុំ សង្កាត់បានមានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។
- ការធ្វើសេចក្តីសម្រេចចិត្ត សមាជិកក្រុមប្រឹក្សាគ្រប់រូបមានសិទ្ធិបោះឆ្នោត នៅក្នុងគ្រប់កិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់។ ការបោះឆ្នោតត្រូវធ្វើឡើងដោយការលើកដៃ។ សំឡេងគាំទ្រ និងសំឡេងមិនគាំទ្រត្រូវប្រកាសឱ្យដឹងភ្លាម ហើយកត់ត្រាទុកនៅក្នុងកំណត់ហេតុប្រជុំ។ ស្មៀនឃុំ សង្កាត់ និងបុគ្គលិកផ្សេងទៀត ដែលចូលរួមប្រជុំមិនអាចបោះឆ្នោតបានទេ។ សេចក្តីសម្រេចនៃអង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់អាចចាត់ទុកជាបានការ លុះត្រាតែសេចក្តីសម្រេចនោះត្រូវបានអនុម័តដោយសំឡេងលើសពីពាក់កណ្តាលសមាជិកក្រុមប្រឹក្សាទាំងមូល។ ចំពោះ សេចក្តីសម្រេចលើកិច្ចការផ្សេងៗពីនេះអាចចាត់ទុកជាបានការលុះត្រាតែមានសំឡេងគាំទ្រភាគច្រើននៃចំនួនសមាជិកក្រុមប្រឹក្សាដែលមានវត្តមាន។

**ឃ. កិច្ចការក្រោយពេលប្រជុំ**

កំណត់ហេតុជាលាយលក្ខណ៍អក្សរស្មៀនឃុំ សង្កាត់ ជាអ្នកទទួលខុសត្រូវលើការសរសេរកំណត់ហេតុអង្គប្រជុំដោយពិគ្រោះយោបល់ជាមួយប្រធានក្រុមប្រឹក្សា ឃុំ សង្កាត់ ។ សមាជិកក្រុមប្រឹក្សា ឃុំ សង្កាត់ គ្រប់រូបនឹងត្រូវទទួលបានកំណត់ហេតុ ដែលបានចុះហត្ថលេខាដោយប្រធានអង្គប្រជុំចំនួនមួយច្បាប់ម្នាក់ សម្រាប់កិច្ចប្រជុំលើកក្រោយៗទៀត។ កំណត់ហេតុអង្គប្រជុំត្រូវយកចិត្តទុកដាក់លើចំណុចមួយចំនួនដូចជា ៖ កាលបរិច្ឆេទពេលវេលា ទីកន្លែងប្រជុំសមាសភាពអ្នកចូលរួមរបៀបវារៈនៃអង្គប្រជុំសេចក្តីសម្រេចព្រមទាំងបញ្ហានានា ដែលបានលើកឡើងនៅក្នុងអង្គប្រជុំ និងពេលវេលាបិទអង្គប្រជុំ ។

- **ការផ្សព្វផ្សាយពីលទ្ធផលនៃកិច្ចប្រជុំដល់សាធារណជន**

សាធារណជនត្រូវទទួលបានព័ត៌មាន ស្តីពីសេចក្តីសម្រេចដែលក្រុមប្រឹក្សាឃុំ សង្កាត់បានសម្រេច។ រាល់សេចក្តីសម្រេចទាំងអស់ ត្រូវបិទផ្សាយនៅលើក្តារខៀនទេព័ត៌មានសង្កាត់មិនឱ្យហួសពី ៥៨ ម៉ោងបន្ទាប់ពីកិច្ចប្រជុំ។ ស្មៀនឃុំ សង្កាត់ត្រូវរៀបចំសង្ខេបលទ្ធផលនៃកិច្ចប្រជុំសម្រាប់ផ្សព្វផ្សាយដល់សាធារណជន។ ហើយដាក់ជូនមេឃុំ ចៅសង្កាត់ត្រួតពិនិត្យសម្រេច។

- **ការអនុវត្តសេចក្តីសម្រេចរបស់កិច្ចប្រជុំ**

សេចក្តីសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានអនុវត្តនៅក្នុងរង្វង់ ដែនដីឃុំសង្កាត់របស់ខ្លួនបន្ទាប់ពីកិច្ចប្រជុំចប់ភ្លាម។

## ១.៣ ដំណើរការគ្រប់គ្រងរដ្ឋបាលរបស់សង្កាត់ក្បាលកោះ

### ១.៣.១ ការរៀបចំ និង ការប្រព្រឹត្តទៅរបស់រដ្ឋបាលសង្កាត់ក្បាលកោះ

#### ១.៣.១.១ សមាសភាពក្រុមប្រឹក្សាសង្កាត់ក្បាលកោះ

ដោយផ្អែកលើលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារបស់សង្កាត់ក្បាលកោះ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មានសមាសភាពនៃក្រុមប្រឹក្សាសង្កាត់មានរាយនាមដូចតទៅៈ

- លោក **យី សុង** ប្រធានក្រុមប្រឹក្សាសង្កាត់ (ចៅសង្កាត់)
- លោកស្រី **កុយ ស៊ីថា** សមាជិកក្រុមប្រឹក្សាសង្កាត់ (ចៅសង្កាត់រងទី១)
- លោក **យី ខុន** សមាជិកក្រុមប្រឹក្សាសង្កាត់ (ចៅសង្កាត់រងទី២)
- លោក **ឆន សុខវ៉េង** សមាជិកក្រុមប្រឹក្សាសង្កាត់
- លោក **ឆាយ ចាន់** សមាជិកក្រុមប្រឹក្សាសង្កាត់
- លោកស្រី **កែ សុគន្ធា** សមាជិកក្រុមប្រឹក្សាសង្កាត់
- លោក **ម៉ុន មុត** សមាជិកក្រុមប្រឹក្សាសង្កាត់
- លោកស្រី **យ៉ន ឡៃ** សមាជិកក្រុមប្រឹក្សាសង្កាត់
- លោក **ស៊ុន រដ្ឋា** សមាជិកក្រុមប្រឹក្សាសង្កាត់
- លោកស្រី **សំ គីមហួយ** សមាជិកក្រុមប្រឹក្សាសង្កាត់
- លោក **វ៉េង វណ្ណារិទ្ធ** សមាជិកក្រុមប្រឹក្សាសង្កាត់

#### ១.៣.១.២ គណៈកម្មាធិការនានារបស់ ឃុំ សង្កាត់

##### ក. គណៈកម្មាធិការកសាងផែនការ និងថវិកា

គណៈកម្មាធិការកសាងផែនការ និងថវិកា ឃុំ សង្កាត់គឺមានសមាសភាពប្រធានក្រុមប្រឹក្សា ឃុំ សង្កាត់ ជាប្រធានសមាជិកក្រុមប្រឹក្សា សង្កាត់ មួយចំនួនជាសមាជិកចាស់ព្រឹទ្ធាចារ្យ នាយកសាលា ប្រធានមណ្ឌលសុខភាព នាយកប៉ុស្តិ៍នគរបាលរដ្ឋបាល និងលោកមេភូមិគ្រប់ភូមិ។ គណៈកម្មាធិការនេះមានតួនាទី ភារកិច្ចជួយចៅសង្កាត់ក្នុងការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ដោយអនុវត្តតាមបែបបទនីតិវិធី ដូចមានកំណត់ក្នុងសេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ ឃុំ សង្កាត់ និងសេចក្តីណែនាំស្តីពីការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល ឃុំ សង្កាត់។[28]

### ខ. គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ

គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារគឺជាគណៈកម្មាធិការមួយដែលជួយដោះស្រាយបញ្ហាស្ត្រី និងកុមារ ។ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារមានភារកិច្ចដូចជា៖

- ជួយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការប្រមូលវិភាគព័ត៌មាន ទិន្នន័យពាក់ពន្ធ័និងបញ្ហា តម្រូវការរបស់នារី និងកុមារ ដើម្បីដាក់បញ្ចូលក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ឃុំ សង្កាត់
- ទាក់ទាញការគាំទ្រ ដើម្បីធានាឱ្យអ្នកពាក់ព័ន្ធនានា ពិសេសស្ត្រី ជនពិការ យុវវ័យ និងជនរងគ្រោះនានាបានចូលរួមក្នុងការធ្វើសេចក្ដីសម្រេចចិត្តលើការអភិវឌ្ឍមូលដ្ឋាន។
- ចូលរួមផ្ដល់ព័ត៌មាន និងជំរុញឱ្យមានការយកចិត្តទុកដាក់លើបញ្ហាស្ត្រី កុមារ និងជនរងគ្រោះនានាដែលមាន ក្នុងដែនសមត្ថកិច្ចរបស់ខ្លួននៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់
- សហការបំពេញការងារតាមសំណូមពរពីគណៈកម្មាធិការកសាងផែនការ និងថវិកា ដើម្បីកសាងផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ឃុំ សង្កាត់។[29]

### គ. គណៈកម្មការលទ្ធកម្ម

គណៈកម្មាធិការលទ្ធកម្មសង្កាត់ក្បាលកោះមានសមាសភាពចំនួន ៤រូប ដឹកនាំដោយប្រធាន១រូប ជាចៅសង្កាត់ និងមានសមាជិកចំនួន ៣រូបទៀតក្នុងនោះមានសមាជិកក្រុមប្រឹក្សាសង្កាត់ចំនួន ២រូបនិងមានស្មៀនសង្កាត់ ១រូប ជាលេខាកត់ត្រា។ គណៈកម្មការលទ្ធកម្មសង្កាត់ក្បាលកោះមានភារកិច្ចដូចខាងក្រោម៖

- ធានាឱ្យលទ្ធកម្មការងារសាងសង់ ការផ្គត់ផ្គង់សម្ភារៈ និងការផ្ដល់សេវាប្រព្រឹត្តទៅប្រកបដោយតម្លាភាពសន្សំសំចៃអ្នកផ្គត់ផ្គង់ត្រូវបានផ្ដល់ឱកាសស្មើគ្នា ក្នុងការចូលរួមប្រកួតប្រជែងផ្គត់ផ្គង់សម្ភារៈ និងផ្ដល់សេវាក្រោមលក្ខខណ្ឌតែមួយ។
- ធានាឱ្យលទ្ធផលនៃការងារលទ្ធកម្មត្រូវប្រកាសជាសាធារណៈ។

### ឃ. គណៈកម្មការគ្រប់គ្រងគម្រោង

គណៈកម្មការគ្រប់គ្រងគម្រោងមានសមាសភាពចំនួន១១រូប ដឹកនាំដោយប្រធាន ១ រូប ជាមេឃុំនឹងជាអនុប្រធាន ១ រូប ជាជំទប់ទី១ រួមទាំងសមាជិកចំនួន ៩រូបទៀតក្នុងនោះមានដូចជា សមាជិក ក្រុមប្រឹក្សាឃុំសង្កាត់ចំនួន ៥រូប មេភូមិចំនួន ៣រូប និងស្មៀនសង្កាត់ក្បាលកោះជាលេខាធិការ។គណៈកម្មការនេះមានតួនាទីនិងភាកិច្ចដូចជា៖

---

[28] ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ

[29] ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ

- **ក្នុងការរៀបចំគម្រោង**

- ពិនិត្យ និងអនុម័តផែនការសិក្សាគម្រោង
- គ្រប់គ្រងចាត់ចែងដំណើរការសិក្សា និងការរៀបចំគម្រោង
- ពិនិត្យ និងអនុម័តសំណើរគម្រោង ។

- **ក្នុងការអនុវត្តគម្រោង**

- គ្រប់គ្រង ចាត់ចែងដំណើរការអនុវត្តន៍គម្រោង
- រៀបចំកិច្ចកិច្ចប្រជុំចាប់ផ្តើមនឹងបញ្ចប់នៃការងារ ឬផ្គត់ផ្គង់ទំនិញនិងរៀបចំប្រជុំពិនិត្យអនុម័តការទូទាត់គម្រោង
- តាមដានត្រួតពិនិត្យការអនុវត្តគម្រោង
- រៀបចំកិច្ចប្រជុំនានានៅក្នុងអំឡុងពេលអនុវត្តន៍គម្រោងដើម្បីពិនិត្យ និងវាយតម្លៃការអនុវត្តគម្រោង ។

### ខ. កិច្ចការប្រជុំគណៈកម្មាធិការ

ជាគោលការណ៍កិច្ចប្រជុំគណៈកម្មាធិការនានា របស់ក្រុមប្រឹក្សា សង្កាត់ ត្រូវអនុវត្តដូចកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ដែរ ប៉ុន្តែមានចំណុចពិសេសមួយចំនួនដូចខាងក្រោម ៖

- **របៀបវារៈសម្រាប់កិច្ចប្រជុំគណៈកម្មាធិការផ្តល់យោបល់ ៖** របៀបវារៈនៅក្នុងកិច្ចប្រជុំគណៈកម្មាធិការផ្តល់យោបល់គួររៀបចំដោយស្មៀនដោយមានការពិគ្រោះជាមួយចៅសង្កាត់នឹងប្រធានគណៈកម្មាធិការ។ ប្រសិនបើសមាជិកគណៈកម្មាធិការច្រើនជាងមួយភាគបី មានបំណងពិភាក្សាលើបញ្ហាដែលស្ថិតនៅក្នុងការងាររបស់គណៈកម្មាធិការបញ្ហានោះត្រូវដាក់ចូលក្នុងរបៀបវារៈ។
- **សេចក្តីសម្រេចរបស់គណៈកម្មាធិការ ៖** គណៈកម្មាធិការត្រូវធ្វើសេចក្តីសម្រេច ដោយមានការព្រមព្រៀងឯកភាពគ្នាតាមរយៈការលើកដៃចំពោះការធ្វើសេចក្តីសម្រេច។ ប្រសិនបើពុំមានការព្រមព្រៀងឯកភាពគ្នាទេគណៈកម្មាធិការត្រូវធ្វើការបោះឆ្នោត។ គណៈកម្មាធិការត្រូវធ្វើការរាយការណ៍អំពីសេចក្តីសម្រេចរបស់ខ្លួនជូនក្រុមប្រឹក្សាសង្កាត់ ឬ ចៅសង្កាត់ដូចដែលបានបញ្ជាក់នៅក្នុងតួនាទីនឹងភារកិច្ចរបស់ខ្លួន។

## ១.៣.២ ការអភិវឌ្ឍរបស់សង្កាត់ក្បាលកោះ

### ១.៣.២.១ ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

ផែនការអភិវឌ្ឍ ឃុំ សង្កាត់ គឺ មានអាណត្តិរយៈពេលប្រាំឆ្នាំដូចអាណត្តិរបស់ក្រុមប្រឹក្សាដែរ។ ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ដែលត្រូវបានប្រើប្រាស់សម្រាប់កំណត់អំពី បញ្ហាតម្រូវការ និងយុទ្ធសាស្ត្រនានា ដើម្បីការដោះស្រាយរាល់បញ្ហាទាំងនោះ ដើម្បីឆ្លើយតបទៅនឹងបញ្ហាជាអាទិភាពរបស់ប្រជាពលរដ្ឋឱ្យមានប្រសិទ្ធភាព។

### ក. ការរៀបចំផែនការអភិវឌ្ឍន៍

ក្រុមប្រឹក្សាឃុំ សង្កាត់ជារដ្ឋបាលដែលនៅជាប់ដាច់ឆ្ងាយពីរដ្ឋបាលកណ្តាល ប៉ុន្តែជារដ្ឋបាលដែលនៅជិតប្រជាពលរដ្ឋជាងរដ្ឋបាលដទៃទៀត ហើយក៏ដឹងច្បាស់អំពីតម្រូវការរបស់ប្រជាពលរដ្ឋ ក៏ដូចជាស្ថានភាពនៅមូលដ្ឋានរបស់ឃុំ សង្កាត់នីមួយៗផងដែរ ។ ដូច្នេះ ការអភិវឌ្ឍក្នុងមូលដ្ឋានរបស់ឃុំ សង្កាត់នីមួយៗត្រូវពឹងផ្អែកលើវិធានការ និងការរៀបចំគម្រោងនានារបស់សង្កាត់នីមួយៗស្របតាមលទ្ធភាពផ្ទាល់របស់ឃុំ សង្កាត់នោះ។ ការរៀបចំអនុម័ត និងអនុវត្តន៍ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ គឺជាភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយមានគោលបំណងនៃការបង្កើតផែនការអភិវឌ្ឍន៍នេះ ដើម្បីកំណត់នូវទស្សនៈវិស័យកម្មវិធី និងកិច្ចអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួនហើយត្រូវតែស្របទៅនឹងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ចរបស់ខ្លួន។[30]

ផែនការអភិវឌ្ឍន៍ គឺពិតជាមានសារៈសំខាន់ណាស់សម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ដែលចាំបាច់ត្រូវតែមានរៀបចំការអនុម័ត ហើយធ្វើការកែសម្រួលនូវទិន្នន័យថ្មីៗដែលមានការប្រែប្រួលជារៀងរាល់ឆ្នាំនៅពេលស្ថិតិក្នុងអាណត្តិ ឬក្នុងឆ្នាំទីមួយនៃអាណត្តិក្រុមប្រឹក្សាទើបនឹងជាប់ឆ្នោត។[31] ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ត្រូវតែរៀបចំជាលាយលក្ខណ៍អក្សរ ដោយមានផែនទី ស្ថិតិ និងសំណុំឯកសារពាក់ព័ន្ធផ្សេងៗទៀតភ្ជាប់មកជាមួយ។ ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ក៏ត្រូវកំណត់ដែលនូវវិធីសាស្ត្រ និងមធ្យោបាយនានាដើម្បីបង្កលទ្ធភាពឱ្យមានការចូលរួមពីប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួនក្នុងកិច្ចដំណើរការទាំងមូល។[32]

ក្នុងករណីផែនការអភិវឌ្ឍន៍ ឃុំ សង្កាត់ ណាមួយធ្វើឡើងមិនស្របតាមច្បាប់នោះទេ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងធ្វើការឱ្យក្រុមប្រឹក្សា ឃុំ សង្កាត់ កែតម្រូវឱ្យបានសមស្របក្នុងកំឡុងពេលយ៉ាងយូរ ៤៥ ថ្ងៃបន្ទាប់ពីទទួលច្បាប់ ចម្លងនៃផែនការនោះ។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការកែសម្រួលផែនការអភិវឌ្ឍន៍ ឃុំ សង្កាត់របស់ខ្លួនឱ្យបាន សមស្របតាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។[33]

[30] មាត្រា៦០ នៃច្បាប់ស្តីពីគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់,ឆ្នាំ២០០១

[31] មាត្រា៦២ នៃច្បាប់ស្តីពីគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់,ឆ្នាំ២០០១

[32] មាត្រា៦៤ នៃច្បាប់ស្តីពីគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់,ឆ្នាំ២០០១

[33] មាត្រា៦៥ នៃច្បាប់ស្តីពីគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់,ឆ្នាំ២០០១

## ខ. វដ្តនៃផែនការអភិវឌ្ឍន៍

វដ្តនៃផែនការអភិវឌ្ឍន៍ឃុំមាន ៥ជំហានគឺៈ ទី១-សេចក្តីព្រាងក្របខ័ណ្ឌអភិវឌ្ឍន៍ និងថវិកា ទី២-កិច្ចប្រជុំពិគ្រោះយោបល់ស្តីពីការអភិវឌ្ឍសង្កាត់ ទី៣-សេចក្តីព្រាងផែនការអភិវឌ្ឍន៍សង្កាត់ ទី៤-ការអនុម័តផែនការអភិវឌ្ឍន៍សង្កាត់ និងទី៥-ការវាយតម្លៃអំពីការអនុវត្តផែនការអភិវឌ្ឍន៍សង្កាត់។

- **ជំហានទី១ៈ សេចក្តីព្រាងក្របខ័ណ្ឌអភិវឌ្ឍន៍ និងថវិកា**

ជាដំបូងគណៈកម្មាធិការកសាងផែនការ និងថវិកាជួបប្រជុំនៅថ្នាក់សង្កាត់ដើម្បីធ្វើការវិភាគទិន្នន័យភូមិ ទិន្នន័យសង្កាត់ ឯកសារព័ត៌មាន ស្ថានភាពសង្កាត់ និងទិន្នន័យ ព័ត៌មាន ឬប្រើឧបករណ៍វិភាគផ្សេងៗ ក្នុងការកំណត់អំពីបញ្ហាមូលហេតុនៃបញ្ហា និងដំណោះស្រាយនានាសម្រាប់ពិភាក្សាជាមួយប្រជាពលរដ្ឋ បន្ទាប់មកគណៈកម្មាធិការធ្វើការរៀបចំប្រជុំនៅតាមភូមិ ដើម្បីពិភាក្សានឹងធ្វើឱ្យសុពលភាពទៅលើបញ្ហាមូលហេតុ និងដំណោះស្រាយទាំងឡាយដែលកំណត់នៅថ្នាក់សង្កាត់ ដើម្បីពិភាក្សាកំណត់បញ្ហា ឬតម្រូវការនឹងដំណោះស្រាយនានាបន្ថែមៗបន្ទាប់ពីនោះ គណៈកម្មាធិការធ្វើការជួបប្រជុំនៅថ្នាក់សង្កាត់ម្តងទៀត ដើម្បីបូកសរុបបញ្ហាមូលហេតុ និងដំណោះស្រាយដែលបានមកពីបណ្តាភូមិនានា និងពិភាក្សាកំណត់សេចក្តីត្រូវការអភិវឌ្ឍគោលដៅអភិវឌ្ឍន៍យុទ្ធសាស្ត្រអភិវឌ្ឍសកម្មភាពជាអាទិភាពទំហំគម្រោង ទីតាំងគម្រោង និងតម្លៃប៉ាន់ស្មានគម្រោង។

- **ជំហានទី២ៈ កិច្ចប្រជុំពិគ្រោះយោបល់ស្តីពីការអភិវឌ្ឍឃុំ សង្កាត់**

កិច្ចប្រជុំពិគ្រោះយោបល់ស្តីពីអំពីការអភិវឌ្ឍសង្កាត់ ត្រូវបានរៀបចំឡើងដើម្បីប្រជុំជាមួយប្រជាពលរដ្ឋក្នុងសង្កាត់ និងអ្នកពាក់ព័ន្ធនានាផ្តល់មតិយោបល់ទៅលើសេចក្តីព្រាងក្របខណ្ឌអភិវឌ្ឍន៍ និងថវិការបស់សង្កាត់។

- **ជំហានទី៣ៈ សេចក្តីព្រាងផែនការអភិវឌ្ឍន៍**

គណៈកម្មាធិការកសាងផែនការ និងថវិការៀបចំសេចក្តីព្រាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ហើយដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងឯកភាព។ បន្ទាប់ពីទទួលបានការឯកភាព ចៅសង្កាត់ផ្ញើសេចក្តីព្រាងផែនការអភិវឌ្ឍន៍សង្កាត់ជូនអភិបាលខណ្ឌច្បារអំពៅ តាមរយៈអង្គភាពរដ្ឋបាលមូលដ្ឋានខណ្ឌច្បារអំពៅដើម្បីពិនិត្យ និងផ្តល់យោបល់។

- **ជំហានទី៤ៈការអនុម័តផែនការអភិវឌ្ឍន៍ឃុំ សង្កាត់**

គណៈកម្មាធិការកសាងផែនការនឹងថវិកា និងស្មៀនសង្កាត់ ពិនិត្យពិចារណាកែសម្រួលសេចក្តីព្រាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ទៅតាមមតិយោបល់របស់អភិបាលខណ្ឌច្បារអំពៅ។ ក្រោយមកទៀតក្រុមប្រឹក្សាសង្កាត់ធ្វើការពិនិត្យ និងអនុម័តសេចក្តីព្រាងផែនការអភិវឌ្ឍន៍សង្កាត់។ឯកសារផែនការអភិវឌ្ឍន៍សង្កាត់ដែលបានអនុម័តត្រូវផ្សព្វផ្សាយជាសាធារណៈ និងប្រើប្រាស់ជាមូលដ្ឋានសម្រាប់កសាងកម្មវិធីវិនិយោគសង្កាត់ប្រចាំឆ្នាំ។

- **ជំហានទី៥៖ ការវាយតម្លៃអំពីការអនុវត្តផែនការអភិវឌ្ឍន៍**

គណៈកម្មាធិការកសាងផែនការ និងថវិកា ពិនិត្យនឹងវាយតម្លៃទៅលើប្រសិទ្ធភាពនៃការអនុវត្តផែនការអភិវឌ្ឍន៍សង្កាត់នឹងដកស្រង់បទពិសោធន៍នានា សម្រាប់ជាមូលដ្ឋានក្នុងការគ្រប់គ្រងការអនុវត្ត និងការរៀបចំផែនការពេលក្រោយ។

### គ. ការអនុវត្តផែនការអភិវឌ្ឍន៍

នៅពេលអនុវត្តផែនការអភិវឌ្ឍន៍ ក្រុមប្រឹក្សា ឃុំ សង្កាត់ ត្រូវបានធានាថាអ្នកពាក់ព័ន្ធទាំងអស់ពិសេសអ្នកទទួលផលពីគម្រោងបានចូលរួមយ៉ាងពេញលេញក្នុងការរៀបចំគម្រោង និងការត្រួតពិនិត្យការអនុវត្តគម្រោងដែលមានក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ ឃុំ សង្កាត់។ ចៅសង្កាត់ ត្រូវធ្វើលទ្ធកម្មការងារ សាងសង់សម្ភារៈឬទំនិញ និងសេវាកម្មដើម្បីអនុវត្តន៍គម្រោងទាំងអស់ និងសកម្មភាពនានាឱ្យស្របតាមនីតិវិធីដែលបានកំណត់។ មុនធ្វើលទ្ធកម្មការងារសាងសង់សម្ភារៈ ឬទំនិញ និងសេវាកម្មសម្រាប់អនុវត្តន៍ក្នុងគម្រោងណាមួយចៅសង្កាត់ត្រូវស្វែងរកការបញ្ជាក់ ផ្នែកបច្ចេកទេសពីមន្ទីរជំនាញ ឬអង្គភាពពាក់ព័ន្ធជុំវិញខេត្ត និងតាមរយៈអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត។ ការវាយតម្លៃគ្រប់ជ្រុងជ្រោយទៅលើលទ្ធផល ផលប៉ះពាល់ពីការអនុវត្តផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ត្រូវធ្វើឡើងក្នុងរយៈពេល ៦ខែចុងក្រោយនៃអាណត្តិក្រុមប្រឹក្សា។

### ឃ. ការត្រួតពិនិត្យ និងការវាយតម្លៃ

បន្ទាប់ពីការរៀបចំផែនការអភិវឌ្ឍន៍ ឃុំ សង្កាត់ រួចក្រុមប្រឹក្សាត្រូវធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃទៅលើសកម្មភាពនៃការអនុវត្តផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគគម្រោងនិងការផ្ដល់សេវាសាធារណៈនានារបស់សង្កាត់ប្រកបដោយតម្លាភាពជាមួយនឹងការទទួលខុសត្រូវខ្ពស់របស់អ្នកផ្ដល់សេវា។ ដោយស្របទៅតាមស្ថានភាពជាក់ស្ដែង ក្រុមប្រឹក្សាសង្កាត់ក្បាលកោះ អាចជ្រើសរើសយកសមាសភាពផ្សេងទៀតមកអនុវត្តន៍ផែនការកម្មវិធី និងគម្រោងនានារបស់សង្កាត់ ប៉ុន្តែក្រុមប្រឹក្សាឃុំ សង្កាត់ នៅតែទទួលខុសត្រូវក្នុងការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃចំពោះការអនុវត្តការងាររបស់សមាសភាព ។

ម្យ៉ាងទៀត ដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្តផែនការរបស់ឃុំ សង្កាត់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវណែនាំដល់ក្រុមប្រឹក្សា ឃុំ សង្កាត់ អំពីវិធីសាស្ត្រផ្សេងៗក្នុងការអនុវត្តផែនការ និងត្រួតពិនិត្យវាយតម្លៃរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ចំពោះការប្រើប្រាស់មូលនិធិសម្រាប់ផែនការអភិវឌ្ឍន៍។[34]

### ១.៣.២.២ កម្មវិធីវិនិយោគ

#### ក. ក្របខ័ណ្ឌវិនិយោគ

ក្របខ័ណ្ឌវិនិយោគ គឺជាផ្នែកមួយដ៏សំខាន់របស់កម្មវិធីវិនិយោគសង្កាត់ក្បាលកោះ។ ក្រុមប្រឹក្សាសង្កាត់ក្បាលកោះដែលមានគណៈកម្មាធិការកសាងផែនការ និងថវិកាសង្កាត់ជាជំនួយការបានយកចិត្តទុកដាក់គិតគូរ និងរៀបចំអំពីគោលបំណងសំខាន់ៗ ដើម្បីធ្វើការអភិវឌ្ឍមូលដ្ឋាននាពេលខាងមុខដោយទៅលើផែនការអភិវឌ្ឍន៍រយៈពេល ៣ ឆ្នាំ (២០១៨-២០២០) ជាឯកសារគោល និងជាត្រីវិស័យសម្រាប់ឱ្យក្រុមប្រឹក្សាសង្កាត់ អនុវត្តតាមរយៈការរៀបចំ និងការអនុវត្តកម្មវិធីវិនិយោគប្រចាំឆ្នាំនីមួយៗរបស់សង្កាត់។ នៅពេលពិនិត្យលើបញ្ហា និងតម្រូវការជាមួយប្រជាពលរដ្ឋឡើងវិញ ការរៀបចំគម្រោងវិនិយោគប្រចាំឆ្នាំរបស់សង្កាត់ត្រូវឆ្លងកាត់ការពិភាក្សាគ្នាឱ្យបានល្អិតល្អន់ ដើម្បីជ្រើសរើស និងចាត់អាទិភាពគម្រោងសម្រាប់យកទៅអនុវត្តឱ្យចំគោលដៅតាមការជាក់ស្តែងក្នុងមូលដ្ឋានថាតើ អ្វីដែលជាបញ្ហាប្រឈម ហើយចាំបាច់ត្រូវការដោះស្រាយមុនឱ្យស្របទៅនឹងប្រភពធនធានដែលសង្កាត់មាន និងទុនពីខាងក្រៅដែលបានមកពីការជួយឧបត្ថម្ភពីសំណាក់ មន្ទីរជំនាញ អង្គការមិនមែនរដ្ឋាភិបាល សប្បុរសជន និងដៃគូអភិវឌ្ឍន៍នានា ជួយគាំទ្រដល់គម្រោងកម្មវិធីវិនិយោគនេះនៅពេលសមាហរណកម្មផែនការសង្កាត់នៅ ថ្នាក់ខណ្ឌ និងគម្រោងខ្លះទៀតជួយគាំទ្រនៅក្រោយពេលសមាហរណកម្មជាមួយគ្នានេះដែរសង្កាត់ត្រូវកោះប្រជុំពេញអង្គក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីសម្រេចជ្រើសរើសគម្រោងដែលនៅសេសសល់គ្មានការសន្យាគាំទ្រសម្រាប់ ប្រើប្រាស់មូលនិធិសង្កាត់ ទុនចូលរួមពីប្រជាពលរដ្ឋ និងថវិកាផ្សេងៗទៀតរបស់សង្កាត់ដែលទទួលបានពីមជ្ឈដ្ឋានខាងក្រៅ ត្រូវបញ្ចូលក្នុងតារាងថវិកាវិនិយោគ តាមប្រភពតារាងគម្រោងវិនិយោគដែលមានការសន្យាគាំទ្រ និងតារាងគម្រោងវិនិយោគដែលមិនទាន់មានការសន្យាគាំទ្រ។

#### ខ. វដ្តនៃកម្មវិធីវិនិយោគ

វដ្តនៃកម្មវិធីវិនិយោគឃុំសង្កាត់មាន៥ជំហានគឺ ទី១.ការពិនិត្យបញ្ហាឬតម្រូវការជាមួយប្រជាពលរដ្ឋឡើងវិញ ទី២.ការរៀបចំគម្រោងថវិកាវិនិយោគរបស់ ឃុំ សង្កាត់ ទី៣.សិក្ខាសិលាសមាហរណកម្មផែនការថ្នាក់ស្រុក ទី៤. ការ អនុម័តកម្មវិធីវិនិយោគ ឃុំ សង្កាត់ និងទី៥.ការតាមដានត្រួតពនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគ ឃុំ សង្កាត់។

[34] មាត្រា៦៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, ឆ្នាំ២០០១

**ជំហានទី១៖ ការពិនិត្យបញ្ហា ឬតម្រូវការជាមួយប្រជាពលរដ្ឋឡើងវិញ**

គណៈកម្មាធិការកសាងផែនការ និងថវិកា ជួបប្រជុំនៅនៅថ្នាក់ ឃុំ សង្កាត់ ដើម្បីពិភាក្សាពិនិត្យបញ្ហា ឬតម្រូវការមូលហេតុនៃបញ្ហា និងរកដំណោះស្រាយឡើងវិញ ដោយធ្វើការឆ្លុះបញ្ចាំងជាមួយទិន្នន័យភូមិ ទិន្នន័យសង្កាត់ ឯកសារព័ត៌មានស្ថានភាពសង្កាត់ និងទិន្នន័យ ឬព័ត៌មានផ្សេងៗ ហើយកំណត់អំពីបញ្ហា មូលហេតុនៃបញ្ហា និង ដំណោះស្រាយនានាសម្រាប់ពិភាក្សាជាមួយប្រជាពលរដ្ឋ។ គណៈកម្មាធិការត្រូវធ្វើការរៀបចំប្រជុំនៅតាមភូមិដើម្បីពិភាក្សា និងធ្វើសុពលភាពមូលហេតុនៃបញ្ហា និងដំណោះស្រាយទាំងឡាយដែលបានកំណត់នៅថ្នាក់សង្កាត់ ដើម្បីពិភាក្សាសម្រាប់កំណត់នូវបញ្ហា ឬតម្រូវការ និងដំណោះស្រាយនានាបន្ថែមទៀត។ ក្រោយមកគណៈកម្មាធិការធ្វើការជួបប្រជុំម្តងទៀតនៅថ្នាក់សង្កាត់ ដើម្បីបូកសរុបមូលហេតុនៃបញ្ហា និងដំណោះស្រាយដែលបានមកពីបណ្តាលភូមិនានា ។

**ជំហានទី២៖ ការរៀបចំគម្រោងថវិកាវិនិយោគឃុំ សង្កាត់**

គណៈកម្មាធិការកសាងផែនការ និងថវិកាធ្វើការឆ្លុះបញ្ចាំងលទ្ធផលនៃជំហានទី១ ជាមួយគម្រោងតាមបណ្តាលឆ្នាំនីមួយៗនៃផែនការអភិវឌ្ឍន៍នៃឃុំ សង្កាត់ ដើម្បីកំណត់នូវគម្រោងកម្មវិធីវិនិយោគប្រចាំឆ្នាំដែលត្រូវយកទៅបង្ហាញនិងគៀរគរធនធាននៅសិក្ខាសិលាសមាហរណកម្មផែនការថ្នាក់ស្រុក ។

**ជំហានទី៣៖ សិក្ខាសិលាសមាហរណកម្មផែនការថ្នាក់ស្រុក**

សិក្ខាសិលាសមាហរណកម្មផែនការនេះ ត្រូវបានរៀបចំឡើង ដើម្បីផ្តល់ឱកាសអោយមានការផ្សារភ្ជាប់ជាមួយកម្មវិធីវិនិយោគសង្កាត់ជាមួយនឹងផែនការរបស់មន្ទីរជំនាញ អង្គការក្រៅរដ្ឋាភិបាល សង្គមស៊ីវិល និងដៃគូរអភិវឌ្ឍន៍នានា ហើយធ្វើការគៀរគរសម្របសម្រួលធនធានពីប្រភពផ្សេងៗសម្រាប់គាំទ្រដល់គម្រោងវិនិយោគសង្កាត់ជាពិសេសជួយតម្រង់ទិសសកម្មភាពរបស់មូលដ្ឋានសង្កាត់ឱ្យស្របតាមគោលនយោបាយអភិវឌ្ឍន៍ជាតិ និងខេត្ត ។

**ជំហានទី៤៖ ការអនុម័តកម្មវិធីវិនិយោគឃុំ សង្កាត់**

គណៈកម្មាធិការកសាងផែនការ និងថវិកាបានរៀបចំនូវតារាងថវិកាវិនិយោគ តាមប្រភពតារាងគម្រោងវិនិយោគដែលមានការសន្យាគាំទ្រ និងតារាងគម្រោងវិនិយោគដែលមិនទាន់មានការសន្យាគាំទ្រ ជាពិសេសជ្រើសរើសនូវគម្រោងដែលមិនទាន់មានការសន្យាគាំទ្រសម្រាប់ប្រើប្រាស់មូលនិធិសង្កាត់។ ក្រោយពីប្រមូលមតិយោបល់រួច គណៈកម្មាធិការត្រូវរៀបចំសេចក្តីព្រាងកម្មវិធីវិនិយោគ សង្កាត់ហើយដាក់ជូនក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីពិនិត្យ និងអនុម័ត ។ ឯកសារកម្មវិធីវិនិយោគដែលអនុម័តរួច ត្រូវប្រកាសផ្សព្វផ្សាយដាក់ឱ្យប្រើប្រាស់ជាផ្លូវការ និងបង្កភាពងាយស្រួលដល់អ្នកដែលពាក់ព័ន្ធដើម្បីធ្វើការសិក្សាស្វែងយល់ ។

**ជំហានទី៥៖ ការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគ ឃុំ សង្កាត់**

ជំហានចុងក្រោយគណៈកម្មាធិការត្រូវតាមដាន ត្រួតពិនិត្យការរីកចម្រើន និងប្រសិទ្ធភាពនៃការអនុវត្តគម្រោង ឬសកម្មភាពនានាដែលមាននៅក្នុងកម្មវិធីវិនិយោគរបស់ ឃុំ សង្កាត់ ដើម្បីធានាការអនុវត្តគម្រោង ឬសកម្មភាពទាំងឡាយឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា។ មិនត្រឹមតែប៉ុណ្ណោះគណៈកម្មាធិការត្រូវពិនិត្យ និងវាយតម្លៃលើប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីវិនិយោគ ឃុំ សង្កាត់ ហើយដកស្រង់បទពិសោធន៍នានាសម្រាប់ជាមូលដ្ឋាននៅក្នុងការគ្រប់គ្រងការអនុវត្ត និងការរៀបចំកម្មវិធីវិនិយោគឆ្នាំក្រោយ ។

### គ. គម្រោងនៃការវិនិយោគ

នៅឆ្នាំ ២០១៨ ថវិការបស់សង្កាត់ក្បាលកោះមានប្រភពទុនក្នុងសង្កាត់ដែលបានមកពីចំណូលផ្ទាល់របស់សង្កាត់មានចំនួន ១៨៨,៧០០ លានរៀល រីឯទុនក្រៅសង្កាត់បានមកពីមន្ទីរសុខាភិបាលមានចំនួន ៦,០០០លាន រៀល ទុនពីមន្ទីរកិច្ចការនារីមានចំនួន ៤,៥០០លានរៀល ទុនពីមន្ទីរបរិស្ថានមានចំនួន ៥០០ លានរៀល ទុនពីមន្ទីរឧស្សាហកម្ម និងសិប្បកម្មមានចំនួន ៤,៥០០លានរៀល ទុនពីមន្ទីរសង្គមកិច្ចមានចំនួន ២,៥០០០លានរៀន ទុនពីមន្ទីរអប់រំមានចំនួន៥០០លានរៀល ទុនពីមន្ទីរកសិកម្មមានចំនួន៥០០លានរៀល ទុនពីរដ្ឋបាលខណ្ឌច្បារអំពៅមាន ចំនួន ១៦,០០០លានរៀល ។[35] សរុបទុនពីការគាំទ្របណ្ដាលមន្ទីរអង្គភាពមានចំនួន ២២៤,២០០លានរៀល ។ ទុនពីអង្គការ អ.អ.ស.ស. មានចំនួន ៥០០ លានរៀល ទុនពីអង្គការ CODO មានចំនួន ២,០០០លានរៀល ទុនពីអង្គការមិត្តសំឡាញ់មានចំនួន ២,០០០លានរៀល ទុនពីទស្សនៈពិភពលោកមានចំនួន ៤,០០០ លានរៀល និងទុនពីអង្គការSCC មានចំនួន ៥០០លានរៀល ។ សរុបទុនទទួលបានការគាំទ្រពីអង្គការសង្គមស៊ីវិល ដៃអភិវឌ្ឍន៍ និងអ្នក ពាក់ព័ន្ធមានចំនួនសរុប៩,០០០លានរៀល។ សរុបមកថវិកាវិនិយោគតាមប្រភពទាំងអស់របស់សង្កាត់មានចំនួន ២៣៣,២០០លានរៀល។ មូលនិធិអភិវឌ្ឍន៍សង្កាត់ចំនួន២៣៣,២០០លានរៀល ទើបគម្រោងវិនិយោគជាច្រើនត្រូវបានដំណើរការដោយបែងចែកជាគម្រោងវិយោគដែលមានការសន្យាគាំទ្រ និងគម្រោងវិនិយោគដែលពុំមានការសន្យាគាំទ្រ។ គម្រោងវិនិយោគដែលមានការសន្យាគាំទ្រភាគច្រើនអនុវត្តន៍ទៅលើផ្នែកសេដ្ឋកិច្ច ផ្នែកសង្គមកិច្ច ផ្នែកធនធានធម្មជាតិ និងបរិស្ថាន និងបន្សាំនឹងប្រែប្រួលអាកាសធាតុ ផ្នែករដ្ឋបាល និងសន្តិសុខសណ្ដាប់ធ្នាប់សាធារណៈតែប៉ុណ្ណោះ។ គម្រោងវិនិយោគដែលពុំទាន់មានការគាំទ្រមានដូចជាការ ជួសជុលផ្លូវចាក់បេតុង ផ្លូវបេតុងគ្មានសរសៃដែក ។

### ១.៣.៣ ការគ្រប់គ្រងហិរញ្ញវត្ថុរបស់ ឃុំ សង្កាត់

សង្កាត់ក្បាលកោះ ជានីតិបុគ្គលសាធារណៈដែលមាន ធនធាន ថវិកាសម្រាប់ដំណើរការសកម្មភាពរបស់ខ្លួន។ តាមច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តម្រូវឱ្យឃុំ សង្កាត់នីមួយៗមានធនធានហិរញ្ញវត្ថុ

ថវិកា និងទ្រព្យសម្បត្តិផ្ទាល់ខ្លួន។[36] ដូច្នេះ រដ្ឋបាលសង្កាត់ក្បាលកោះមានសិទ្ធិអំណាចគ្រប់គ្រងហិរញ្ញវត្ថុរបស់ខ្លួន និងមានប្រភពចំណូល និងចំណាយរបស់ខ្លួនដែរ។

### ១.៣.៣.១. ការរៀបចំ និងអនុម័តថវិកា

គម្រោងថវិការបស់សង្កាត់ត្រូវរៀបចំឡើងក្រោមការទទួលខុសត្រូវរបស់ចៅសង្កាត់ និងដោយមានជំនួយពីគណៈកម្មាធិការកសាងផែនការ និងថវិការួចទើបបញ្ជូនទៅក្រុមប្រឹក្សាសង្កាត់ដើម្បីពិនិត្យ និងអនុម័ត។ ជារៀងរាល់ឆ្នាំ ដំណើរការរៀបចំថវិការបស់សង្កាត់ក្បាលកោះ ត្រូវបានកំណត់គោលដៅឱ្យមានការចូលរួមពីសំណាក់ប្រជាពលរដ្ឋ ដើម្បីជួយផ្តល់ជាមតិយោបល់ ព្រមទាំងផ្តិតមេដៃបញ្ជាក់ពីការចូលរួមរបស់ខ្លួន។ ប៉ុន្តែជារឿយៗក្រោយពេលប្រកាសផ្សាយឱ្យមានការចូលរួមពីសំណាក់ប្រជាពលរដ្ឋ ហើយប្រជាពលរដ្ឋហាក់ដូចជាមិនចាប់អារម្មណ៍ និងពុំសូវឱ្យតម្លៃពីការចូលរួមរបស់ខ្លួនឡើយ។ ម្យ៉ាងដោយហេតុថាប្រជាពលរដ្ឋផ្តល់ភាពចាំបាច់លើការប្រកបរបរប្រចាំថ្ងៃជាជាងការចូលរួមនេះ ចំណែកឯខ្លះទៀតយល់ថាការចូលរួម លុះត្រាតែបានអំណោយទើបសំខាន់។

នៅដំណាក់កាលបន្ទាប់ពីការអនុម័តគម្រោងថវិកាថ្នាក់សង្កាត់រួចហើយ ចៅសង្កាត់ក្បាលកោះបញ្ជូនគម្រោងថវិកា ទៅកាន់អភិបាលខណ្ឌច្បារអំពៅ។ ក្រោយពីមានការឯកភាពគ្នាលើគម្រោងថវិកានេះ ហើយអភិបាលខណ្ឌច្បារអំពៅ បញ្ជូលគម្រោងថវិកាមកកាន់ចៅសង្កាត់ក្បាលកោះវិញនូវសេចក្តីជូនដំណឹងដែលជាលាយលក្ខណ៍អក្សរ ដើម្បីបញ្ជាក់ពីការទទួលស្គាល់លើគម្រោងថវិកាដែលសេចក្តីជូនដំណឹងនេះក៏មានការចម្លងជូន និងភ្ជាប់ជាមួយគម្រោងថវិកាទៅឱ្យមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរតនាគារភ្នំពេញដែរ។[37]

---

[35] សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល២០១៨ ២០២០ សង្កាត់ក្បាលកោះ

[36] មាត្រា៧៣ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, ឆ្នាំ២០០១

[37] មាត្រា៧៤ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, ឆ្នាំ២០០១

### ១.៣.៣.២. ចំណូល និងចំណាយរបស់ ឃុំ សង្កាត់

#### ក.ប្រភពចំណូលឃុំ សង្កាត់

ប្រភពចំណូលរបស់ សង្កាត់មានប្រភពចំណូលចំនួនបីគឺ ចំណូលផ្ទាល់ ចំណូលពីមូលនិធិ ឃុំ សង្កាត់ និង ចំណូលពីការអនុវត្តពីមុខងារ ។

- **ចំណូលផ្ទាល់៖** ឃុំ សង្កាត់ មានសិទ្ធិក្នុងការប្រមូលចំណូលផ្ទាល់ ដែលបានមកពីចំណូលសារពើពន្ធ និង ចំណូលមិនមែនសារពើពន្ធក្នុងមូលដ្ឋានឃុំសង្កាត់របស់ខ្លួន។ ការអនុវត្តកិច្ចនេះរងចាំច្បាប់ ដោយឡែកទើបអនុវត្តន៍បាន។[38]
- **ចំណូលពីមូលនិធិ ឃុំ សង្កាត់ ៖** ចំណូលពីមូលនិធិ ឃុំ សង្កាត់ គឺជាចំណូលដែលបានមកពីការផ្ទេរធនធានពីមូលនិធិឃុំ សង្កាត់ទៅឱ្យឃុំ សង្កាត់នីមួយៗដែលក្នុងនោះរួមមាន ចំណូលសម្រាប់ចំណាយរដ្ឋបាល និង ចំណាយអភិវឌ្ឍន៍ឃុំ សង្កាត់។[39]
- **ចំណូលពីការអនុវត្តមុខងារជាភ្នាក់ងារ៖** ចំណូលពីការអនុវត្តមុខងារជាភ្នាក់ងារ គឺជាចំណូលដែលបានមកពីការបំពេញការងារដោយ ឃុំ សង្កាត់ ជំនួសមុខអោយក្រសួង ស្ថាប័ន ឬអង្គភាពនានារបស់រដ្ឋទៅតាមការព្រមព្រៀងគ្នា។ ក្រៅពីចំណូលទាំងបីខាងលើឃុំ សង្កាត់ មានចំណូលផ្សេងៗទៀតដូចជា ចំណូលពីការរួម ចំណែកពីប្រជាពលរដ្ឋមូលរដ្ឋ ចំណូលពីអង្គការមិនមែនរដ្ឋាភិបាល និងកម្មវិធីនានា។ ចំពោះមុខច្បាប់នៅក្នុងប្រភពចំណូលថវិកានេះ ឃុំ សង្កាត់ ត្រូវទទួលខុសត្រូវការគ្រប់គ្រងធនធានហិរញ្ញវត្ថុ ថវិកា និងទ្រព្យសម្បត្តិ ដើម្បីធានាការប្រើប្រាស់ធនធានអោយបានត្រឹមត្រូវ តម្លាភាពសន្សំសំចៃ និងមានប្រសិទ្ធិភាពខ្ពស់ ។

#### ខ. ចំណាយរបស់ឃុំ សង្កាត់

ឃុំ សង្កាត់មានចំណាយពីរគឺ ចំណាយចរន្ត និងចំណាយមូលធន។

- **ចំណាយចរន្ត៖** ចំណាយចរន្តមានប្រាំពីរប្រភេទគឺ ចំណាយបៀវត្ស និងប្រាក់បំណាច ចំណាយរដ្ឋបាលទូទៅ ចំណាយសេវាសាធារណៈ ចំណាយសម្រាប់មុខងារជាភ្នាក់ងារ ចំណាយអន្តរាគមន៍ផ្នែកសេដ្ឋកិច្ច និងចំណាយមិនបានគ្រោងទុក ។
- **ចំណាយមូលធន៖** មានពីរប្រភេទគឺ ចំណាយរដ្ឋបាល និងចំណាយអភិវឌ្ឍន៍។ ចំណាយរដ្ឋបាល គឺជាចំណាយប្រតិបត្តិការ និងវិនិយោគដោយរដ្ឋបាលឃុំ សង្កាត់ក្នុងការអនុវត្តន៍ភារកិច្ចរួមមានប្រាក់បំណាច សម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់បៀវត្សមន្ត្រីឃុំប្រាក់សម្រាប់ការទិញ ឬជួសជុល និងសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ទិញគ្រឿងសង្ហារឹម សម្ភារៈ មធ្យោបាយរដ្ឋបាល ការជួសជុល និង ថែទាំសម្ភារៈ ថ្លៃប្រើទឹកភ្លើង ទិញ ឬជួសជុលយានជំនិះ និងការចំណាយផ្សេងៗ ។ ចំណែកឯចំណាយអភិវឌ្ឍន៍វិញ គឺជាការចំណាយទៅលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន និងការផ្តល់សេវាសង្គមកិច្ចដែលក្នុង

នោះរួមមានការអង្កេតគំនូរប្លង់ការសាងសង់ ជួសជុល ការថែទាំផ្លូវ ផ្សារ មណ្ឌលសុខភាព សាលារៀន មជ្ឈមណ្ឌលសហគមន៍ សំណង់ ប្រព័ន្ធធារាសាស្ត្រ ប្រព័ន្ធផ្គត់ផ្គង់ទឹក ថាមពល ហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចមន្ត្រីបុគ្គលិកកិច្ចការខាងលើ កម្មវិធីអភិវឌ្ឍន៍សហគមន៍ បរិស្ថាន និងធនធានធម្មជាតិ ។

### ១.៣.៣.៣. ប្រព័ន្ធទូទាត់ គណនេយ្យភាព និងលទ្ធកម្មឃុំ សង្កាត់

#### ក.គោលការណ៍ទូទៅ

ឃុំ សង្កាត់ ត្រូវបង្កើតគណនីប្រាក់បញ្ញើនៅរតនាគារខេត្តក្រុង។[40] ហើយចៅសង្កាត់ជាអាណាប័កនឹងមានសិទ្ធិពេញលេញលើការប្រមូល ឬសន្យាចំណាយនឹងបញ្ជាចំណាយ ដោយផ្អែកលើថវិកាដែលបានអនុម័ត។ មេឃុំ ចៅសង្កាត់អាចផ្ទេរសិទ្ធិក្នុងការសម្រេចលើថវិកាទៅអោយជំទប់ ឬចៅសង្កាត់រងរបស់រដ្ឋបាលឃុំ សង្កាត់។ ការផ្ទេរសិទ្ធិជាអាណាប័កនេះត្រូវធ្វើសកម្មភាពដោយស្ថិតនៅក្នុងការទទួលខុសត្រូវ និងត្រួតពិនិត្យរបស់មេឃុំ ចៅសង្កាត់។ មេឃុំ ចៅសង្កាត់ និងអ្នកទទួលសិទ្ធិត្រូវតម្កល់គំរូហត្ថលេខាជាផ្លូវការដល់គណនេយ្យករមុខការ។[41] ហើយអ្នកទទួលសិទ្ធិ និងបុគ្គលិករដ្ឋបាលឃុំ សង្កាត់ជាទូទៅមិនត្រូវអនុញ្ញាតអោយកាន់កាប់មូលនិធិ ឬធ្វើការទូទាត់ចំណាយ លើកលែងតែក្នុងករណីទូទាត់ឧទ្បាបុរេប្រទាន និងចំណូលដែលប្រមូលបានដោយភ្នាក់ងារប្រមូលចំណូល។ លើសពីនេះទៅទៀត សិទ្ធិបញ្ជាចំណាយ និងការទូទាត់មិនត្រូវប្រគល់អោយមនុស្សតែម្នាក់បានឡើយហើយរតនាគារខេត្តក្រុងត្រូវបំពេញមុខងារជាគណនេយ្យករសង្កាត់។

#### ខ.ប្រព័ន្ធទូទាត់

ការទូទាត់ផ្ទាល់គឺទូទាត់ តាមរយៈរតនាគារខេត្តក្រុង ហើយការទូទាត់តាមរយៈឧទ្បាបុរេប្រទានត្រូវប្រើសម្រាប់តែចំណាយចរន្ត (លើកលែងប្រាក់បៀវត្សប្រាក់បំណាច់ )និងចំណាយវិនិយោគរដ្ឋបាល។ ហើយការចំណាយមួយលើកៗចេញពីឧទ្បាបុរេប្រទាន ត្រូវមានចំនួនទឹកប្រាក់នៅក្រោមកម្រិតមួយជាកំណត់តាមនីតិវិធីឧទ្បាបុរេប្រទាន។[42]

---

[38] មាត្រា៧៨ ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, ឆ្នាំ២០០១

[39] អនុក្រឹត្យលេខ ២៦ ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុឃុំ សង្កាត់ , មាត្រា២៩

[40] អនុក្រឹត្យលេខ ២៦ ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុឃុំ សង្កាត់ , មាត្រា២៧

[41] អនុក្រឹត្យលេខ ២៦ អន.ក្រ.បក ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុឃុំ សង្កាត់ , មាត្រា៣១

[42] អនុក្រឹត្យលេខ ២៦ អន.ក្រ.បក ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុឃុំ សង្កាត់ , មាត្រា២៤

### គ .ប្រព័ន្ធគណនេយ្យ

**គណនេយ្យហិរញ្ញវត្ថុ៖** គឺជាកិច្ចបញ្ជីការ រាល់ចំណូលចំណាយនៅក្នុងប្រព័ន្ធគណនេយ្យ។ ហើយអ្នកដែលមានភារកិច្ចអនុវត្តន៍គណនេយ្យហិរញ្ញវត្ថុ គឺគណនេយ្យករនៅរតនាគាររាជធានី ខេត្ត ។

**គណនេយ្យថវិកា៖** គឺជាការតាមដាន និងរាយការណ៍អំពីការអនុវត្តចំណូល ចំណាយ និងថវិកាដែលមានអនុម័ត ។ ហើយអ្នកដែលមានភារកិច្ចទទួលខុសក្នុងការអនុវត្តគណនេយ្យថវិកា គឺមេឃុំ ចៅ សង្កាត់ [43]។

### ឃ. លទ្ធកម្មឃុំ សង្កាត់

លទ្ធកម្មឃុំ សង្កាត់ គឺជាដំណើរការលទ្ធកម្មចាប់ពីពេលរៀបចំឯកសារដេញថ្លៃរហូតដល់ពេលទទួលបានការងារសាងសង់ ឬជាការរកបាននូវទំនិញ និងសេវាពាក់ព័ន្ធតាមរយៈវិធីសាស្ត្រលទ្ធកម្មសាធារណៈ។

គោលការណ៍សំខាន់ៗនៃកិច្ចលទ្ធកម្មមានដូចជា៖

- លទ្ធកម្មការងារសាងសង់ ការផ្គត់ផ្គង់សម្ភារៈ និងការផ្តល់សេវាកម្ម ត្រូវអនុវត្តក្នុងលក្ខណៈមួយដែលមានតម្លាភាព និង សន្សំសំចៃបំផុតប្រកបដោយប្រសិទ្ធភាព
- អ្នកទទួលការ អ្នកផ្តល់សេវា និង អ្នកផ្គត់ផ្គង់ត្រូវបានផ្តល់ឱកាសស្មើៗគ្នា ដើម្បីចូលរួមនៅក្នុងដំណើរការដេញថ្លៃក្រោមលក្ខខណ្ឌត្រឹមត្រូវ និងស្មើភាព
- លទ្ធផលនៃការដេញថ្លៃត្រូវផ្សព្វផ្សាយជាសាធារណៈ។

លើសពីនេះទៅទៀត មេឃុំ ចៅសង្កាត់ជាប្រធាននៃគណៈកម្មការលទ្ធកម្ម ហើយសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ ២ រូប ជាសមាជិក និង ស្មៀនឃុំសង្កាត់ជាលេខាធិការ។ ហើយការដេញថ្លៃនេះមាត្រា៣១ អនុក្រឹត្យលេខ ២៦ អនក្រ.បក ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ឃុំ សង្កាត់។

# ជំពូកទី២
# ការវិភាគទិន្នន័យនៃការស្រាវជ្រាវ

## ២.១ សមិទ្ធផលដែលសម្រេចបានក្នុងការអនុវត្តសង្កាត់ក្បាលកោះ

យោងតាមសៀវភៅបីឆ្នាំរំកិល (ឆ្នាំ២០១៨ ដល់ ២០២០) នៅក្នុងសង្កាត់ក្បាលកោះ បានអភិវឌ្ឍន៍កសាងសមិទ្ធផលនានាជាច្រើននៅក្នុងមូលដ្ឋានសង្កាត់របស់ខ្លួនសម្រាប់បំពេញតម្រូវការរបស់ប្រជាពលរដ្ឋ កាត់បន្ថយភាពក្រីក្ររស់នៅប្រកបដោយ តម្លាភាព សមភាព រវាងគ្នានឹងគ្នា។ ហើយនៅក្នុងសង្កាត់ក្បាលកោះនេះមានសមិទ្ធផលទទួលបានដូចជា តបណ្តាញអគ្គិសនី និង ទឹក ជួសជុលចាក់ផ្លូវបេតុងគ្មានសរសៃដែកប្រវែង ៦៥ ម៉ែត្រ ទទឹង៤ ម៉ែត្រ(ទីតាំងព្រែកធំ២), ប្រវែង ១៤៦ម៉ែត្រ ទទឹង ៤ម៉ែត្រ, ប្រវែង ១៧៦ម៉ែត្រ ទទឹង៤ ម៉ែត្រ និង ប្រវែង ៧៣ ម៉ែត្រ ទទឹង ៣ម៉ែត្រ(ព្រែកធំ១) និងមានការដាក់លូមូលដោះទឹកទំហំ ០,៦០ម៉ែត្រ ដែលមានប្រវែង ១៣៥ម៉ែត្រ (ទីតាំងព្រែកធំ១)។ ការអនុវត្តការងារកន្លងមករបស់សង្កាត់ក្បាលកោះ បានទទួលសមិទ្ធផលជាច្រើនដូចជា ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋយ៉ាងចិត្តទុក ។

### ២.១.១ ស្ថានភាពសេដ្ឋកិច្ច និងសង្គមកិច្ច

- **ផ្នែកសេដ្ឋកិច្ច**

+**ស្ថានភាពមុខរបរ ៖** គ្រួសារមានមុខរបរធ្វើកសិកម្ម ជាចំបងសំដៅលើគ្រួសារធ្វើស្រែ ដាំដំណាំ ដាំបន្លែ ចិញ្ចឹមសត្វ មានមុខរបរពីអនុផលព្រៃឈើស្មើនឹង ០,៣៣% គ្រួសារដែលមានមុខរបរសិប្បកម្មជាចំបងសំដៅលើគ្រួសារដែលធ្វើការផលិតទ្វារ បង្អួច ពោះវៀនកង់ ម៉ូតូ គ្រឿងឧបភោគបរិភោគ និងសិប្បកម្មផ្សេងៗស្មើនឹង ០,០៨% គ្រួសារប្រកបមុខរបរសេវាកម្មជាចំបងរួមមានមុខរបរធ្វើជំនួញ ជាងជួសជុល មុខរបរដឹកជញ្ជូន និង សេវាកម្មផ្សេងៗ មានចំនួន ៧,៩២% គ្រួសារប្រកបមុខរបរមិនច្បាស់លាស់ (ចំរុះក្រៅពីមុខរបរចំបងខាងលើចំនួន១៨,៣២%) ដែលជាសក្តានុពលយ៉ាងសំខាន់ក្នុងការទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងសង្កាត់ទាំងមូល ។

+ **ការងារសាធារណការៈ** ក្នុងសង្កាត់មានផ្លូវខ្វាត់ខ្វែងគ្រប់ប្រភេទដូចជាផ្លូវបេតុង ផ្លូវដីស ព្រមទាំងមានភ្លើងបំភ្លឺផ្លូវសាធារណៈមួយចំនួនធំដែលបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋ និង ភ្ញៀវទេសចរណ៍ក្នុងការធ្វើដំណើរនិងប្រកបមុខរបរបានទាំងពេលយប់ទាំងពេលថ្ងៃ។ ផ្លូវ និង ភ្លើងបំភ្លឺទាំងនេះស្ថាបនាឡើងដោយថវិកាវិភាជន៍របស់រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុដែលផ្តល់សំរាប់គម្រោងកម្មវិធីគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(គ.ជ.អ.ប) សាលារាជធានីភ្នំពេញ សប្បុរសជនអង្គការដៃគូនានា និងមានការចូលរួមចំណែកពីប្រជាពលរដ្ឋផងដែរ ។

+**ការងារកសិកម្មៈ** ដោយសារតែសង្កាត់ស្ថិតក្នុងតំបន់កំពុងអភិវឌ្ឍន៍ ដូច្នេះការងារកសិកម្មនៅមានសកម្មភាពបន្តិចបន្តួច ។

+**ការងារពាណិជ្ជកម្ម និងអាជីវកម្មៈ** នៅក្នុងសង្កាត់មានអាជីវកម្មខ្នាតតូច ១២៥ ទីតាំងដែលបានចុះបញ្ជីពាណិជ្ជកម្មដែលចែកចេញជាផ្នែកទំនិញ ឧបភោគបរិភោគ អាជីកម្មហូបចុក និងអាជីវកម្មផ្សេងៗដែលជាប្រភពសក្តានុពលផ្នែកអាជីវកម្មពាណិជ្ជកម្ម សម្រាប់ទ្រទ្រង់ជីវភាពមួយផ្នែកធំរបស់ប្រជាអាជីវកម្មភាគច្រើនមានលក្ខណៈជាគ្រួសារពលរដ្ឋ។

+**ការងារឧស្សាហកម្ម និងសិប្បកម្មៈ** នៅក្នុងសង្កាត់មានសិប្បកម្មផលិតក្រម៉ា និងគ្រឿងប្រើប្រាស់ជាច្រើនមុខទៀត។ ផលិតផលទាំងនេះមានគុណភាព និងមួយចំនួនទៀតក៏បាននាំទៅលក់នៅតាមបណ្តាខេត្តក្រុងទូទាំងប្រទេស។

+**ការងារទេសចរណ៍ៈ** អាជីវកម្ម សេវាកម្មក្នុងវិស័យទេសចរណ៍មានការកើនបន្តិចជាពិសេស ម្ចាស់អាជីវកម្មមួយចំនួនមានការយល់ដឹង និងពង្រឹងគុណភាពសេវាកម្មបានផ្តល់នូវទំនុកចិត្តដល់ភ្ញៀវ ដើម្បីបានចូលក្នុងការប្រឡងប្រណាំង ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ ដែលជាផ្នែកមួយស្របយកចំណូលខ្ពស់ក្នុងចំណោមផ្នែកសំខាន់ៗទាំង៤ ។

+**ការងារប្រមូលទិន្នន័យ ការរៀបចំប្រមូលទិន្នន័យភូមិៈ** សង្កាត់គឺជាស្ថិតិនៃព័ត៌មានពីវិស័យនានាដែល មាននៅភូមិសង្កាត់ជារៀងរាល់ឆ្នាំគ្រប់ភូមិទាំង៨ និងថ្នាក់សង្កាត់ត្រូវបានចងក្រងរៀបចំប្រមូលទិន្នន័យភូមិ សង្កាត់ បានត្រឹមត្រូវមានសុក្រឹត្យភាពទៅតាមការណែនាំរបស់មន្ទីរផែនការរាជធានីភ្នំពេញ និងចងក្រងបានជាសៀវភៅ ទិន្នន័យភូមិ ទិន្នន័យសង្កាត់ សំរាប់ជាមូលដ្ឋានក្នុងការរៀបចំផែនការហើយនិងប្រជុំការអភិវឌ្ឍនឹងកម្មវិធីវិនិយោគ ៣ឆ្នាំរំកិល និងឈានទៅធ្វើសមាហរណកម្មផែនការសង្កាត់នៅថ្នាក់ ខណ្ឌ ជារៀងរាល់ឆ្នាំ ។

- **ផ្នែកសង្គមកិច្ច**

+ **ការងារអប់រំយុវជន និងកីឡា ៖** នៅក្នុងសង្កាត់មានសាលាបឋមសិក្សា ៤ កន្លែងអនុវិទ្យាល័យ ០១ កន្លែង និងមានសាលាឯកជនជាច្រើនកន្លែងទៀតដែលបង្កលក្ខណៈយ៉ាងងាយស្រួលដល់ការសិក្សាក្នុងរបស់សិស្សានុសិស្សឱ្យទទួលបានសេវាអប់រំប្រកបដោយសមធម៌ អាជ្ញាធរគ្រប់លំដាប់ថ្នាក់មន្ត្រីអប់រំគ្រប់កំរិតបានខិតខំប្រឹងប្រែឱ្យអស់កំលាំងកាយចិត្ត ដើម្បីឆ្លើយតបទៅនឹងគោលនយោបាយ (អប់រំសំរាប់ទាំងអស់គ្នា) ឱ្យបានសម្រេចប្រកបដោយ គុណភាព និងប្រសិទ្ធភាពនៅឆ្នាំ២០២២ ។

+**ការងារសុខាភិបាល ៖** នៅក្នុងសង្កាត់មានមណ្ឌលសុខភាព១កន្លែង និងមានគ្លីនិកឯកជនឱសថស្ថានរងបន្ទប់ពិគ្រោះព្យាបាលអ្នកជម្ងឺរួមមានទាំង វេជ្ជបណ្ឌិត ទន្តបណ្ឌិត គ្រូពេទ្យឱសថការី គិលានុបដ្ឋាយិកា

ពេទ្យឆ្មប ដៃគូអភិវឌ្ឍន៍នានា និងទទួលបានសេវាកម្មជាតិលើកកម្ពស់សុខភាពរៀងរាល់ឆ្នាំបានផ្តល់ជាប័ណ្ណមូលនិធិសមធម៌ ។

+**ការងារសង្គមកិច្ច អតីតយុទ្ធជន និងយុវនិតិសម្បទាៈ** ក្នុងសង្កាត់មានសមាគមមនុស្សចាស់១ និងអង្គការ មួយចំនួនដែលបានគ្រប់គ្រង់ស្ថិតិច្បាស់លាស់។ មានប្រជាពលរដ្ឋរស់នៅសំណង់មិនរៀបរយមួយចំនួនដែលប្រមូលផ្តុំទៅដោយអ្នកមានជីវភាពក្រីក្រ ខ្វះចំណេះដឹងធ្វើឱ្យការរស់នៅរបស់ពួកគាត់ជួយការលំបាកមុខរបររកកំរៃមិនតុល្យភាពនឹងចំណាយសំរាប់ផ្គត់ផ្គង់ជីវភាពរស់នៅប្រចាំថ្ងៃ ។ សង្កាត់ បានខិតខំទំនាក់ទំនងជាមួយដៃគូអភិឌ្ឍន៍នានា ដើម្បីជួយផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈ ផ្តល់តនទាណសាច់ប្រាក់ និងផ្តល់មូលនិធិមួយចំនួនឱ្យពួកគាត់ខ្ចីដោយ បង់រំលោះសំរាប់ពង្រីកមុខរបរ និងកាត់បន្ថយភាពក្រីក្រ ។

+ **ការងារយេនឌ័រ ៖** ក្នុងបរិបទស្ថិជាឆ្អឹងខ្នងនៃការអភិវឌ្ឍន៍ភាពរីកចំរើនរបស់សង្គមជាតិបច្ចុប្បន្ន តួនាទីស្ត្រី លើផ្នែកគោលនយោបាយស្មើមុខស្មើភាពរវាងបុរស និងស្ត្រីហើយត្រូវបានប្រមុខរាជរដ្ឋាភិបាលកម្ពុជា បាននឹងកំពុងប្រតិបត្តិយ៉ាងគាប់ប្រសើរក្នុងមជ្ឈដ្ឋានទូទៅនៃសង្គមកម្ពុជា ។ស្ត្រីកម្ពុជាក្នុងដំណាក់កាលថ្មី បានខិតខំពង្រឹងទាំង ចំណេះដឹង ទាំងសមត្ថភាព ក្លាយជាធនធានរបស់សង្គមយ៉ាងរឹងមាំ និងជាចលករដ៏សំខាន់នៅក្នុងបុព្វហេតុការងារអភិវឌ្ឍន៍ និងការលើកកម្ពស់សីលធម៌ ។

+ **ការងារធម្មការនិងសាសនា** ៖ សង្កាត់មានវត្ត៧ កន្លែង និងវិហារសាសនាផ្សេងៗអាចបំពេញតម្រូវការជូនប្រជាពលរដ្ឋគោរពប្រតិបត្តិបាន។ ដោយតាមការពិនិត្យកន្លងមកឃើញថា គ្រឹស្តសាសនាច្រើនពុំមានការទំនាក់ ទំនងជាមួយអាជ្ញាធរមូលដ្ឋាន ធ្វើឱ្យការគ្រប់គ្រង់ពុំបានច្បាស់លាស់ និងច្រើនកាន់ធ្វើអ្វីដែលច្បាប់ហាមឃាត់ បណ្តាលឱ្យប៉ះពាល់ដល់សោភ័ណ្ឌភាព សាធារណៈដោយមានបិទឱ្យគោលលិទ្ធិសាសនា តាមដើមឈើរបងសាធារណៈ។ ល ។

+**ការងារវប្បធម៌ និងវិចិត្រសិល្បៈ** ៖ ត្រូវបានទទួលការគាំទ្រ និងយកចិត្តទុកដាក់ជាប្រចាំពីថ្នាក់ដឹកនាំដោយមានការចូលរួមសហការល្អប្រសើរពីរដ្ឋបាលខណ្ឌច្បារអំពៅនឹងសាលារាជធានីភ្នំពេញ។ ហើយជាវិស័យមួយដែលមានតួនាទី និងសារៈសំខាន់ក្នុងការរួមចំណែកដល់ការផ្សព្វផ្សាយនូវវប្បធម៌ជាតិ ប្រែក្លាយវប្បធម៌ជាគ្រឹះដើម្បីអភិវឌ្ឍន៍សង្គម តាមរយៈការទាញចំណូលលើវិស័យវប្បធម៌ ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ។ ដំណាក់កាលសកលភាវូបនីយកម្មវប្បធម៌ កត្តាចម្បងត្រូវអភិរក្សដោយឈ្លាសវៃក្នុងវិស័យវប្បធម៌ ហើយដើម្បីឈានឆ្ពោះការអភិវឌ្ឍប្រកបដោយចរីភាព។ ការលំហូរចូលគ្រប់ទម្រង់នៃវប្បធម៌បរទេស អាចមានផលប៉ះពាល់ក្នុងការរក្សាអត្តសញ្ញាណជាតិសំខាន់ៗក្នុងស្រទាប់យុវវ័យច្រើនតំណ។ ភាពភ្លើតភ្លើនដែលកំពុងឈានទៅក្នុងហាយនៈភាពតាមរយៈវប្បធម៌បរទេស គប្បីលើកកម្ពស់ប្រពៃណីទំនៀមទំលាប់ឱ្យកាន់តែប្រសើរឡើងថែមទៀតអំពីវប្បធម៌ជាតិ ក្នុងដំណាក់កាលសកល ភាវូបនីយកម្មនាពេលបច្ចុប្បន្ន។ ចំពោះមុខការអនុវត្ត មុខងារគតិយុត្តិ

ជាកត្តាចម្បងសំខាន់បំផុតដើម្បីពង្រឹង និង អភិរក្សវប្បធម៌អត្តសញ្ញាណជាតិខ្មែរ។ ជាមួយគ្នានេះដែរក៏នៅមានការធ្វើចរាចរដោយលួចលាក់នូវ CD/VCD/DVD គ្មានទិដ្ឋាការត្រឹមត្រូវ ។

### ២.១.២. ផ្នែកធនធានធម្មជាតិ បរិស្ថាន និងបន្សាំនិងការប្រែប្រួលអាកាសធាតុ

- **ការគ្រប់គ្រងដីធ្លី និងសំណង់ ៖**

ដោយសង្កាត់ក្បាលកោះ អាចបង្កភាពងាយស្រួលក្នុងការគ្រប់គ្រងដីធ្លី និងសំណង់បានល្អ ។ យើងមាន លិខិតបទដ្ឋានជាច្រើន ពាក់ព័ន្ធនឹងការគ្រប់គ្រងសំណង់ ដីធ្លី ផ្ទះសំបែងនិងបានបែងចែកសិទ្ធិ អំណាចនៃការអនុញ្ញាតច្បាប់ឱ្យ សាងសង់ ជួសជុលទៅតាមការណែនាំ ។ ទោះជាយ៉ាងណាក៏ដោយទំនាស់ ផ្ទះសំបែងក៏នៅតែមានកើតឡើងជុំវិញ ការសាងសង់ជួសជុលផ្ទះមានប្រជាជនមួយចំនួនតូចនៅមិនទាន់យល់ច្បាស់ពីច្បាប់ភូមិបាលបានយកចិញ្ចើមផ្លូវសាធារណៈទៅជួលឱ្យគេលក់ដូរដែលផ្ទុយពីច្បាប់ស្តីពីភូមិបាល។

- **ការងារគ្រប់គ្រងកាកសំណល់រឹងរាវះ**

ដោយសារសង្កាត់ ស្ថិតនៅជាប់មាត់ទន្លេមេគង្គហេតុនេះផលប៉ះពាល់ អាចកើតមានឡើងដល់បរិស្ថានគឺការបង្ហូរកាកសំណល់ រឹង រាវ មានជាតិគីមីចូលទៅ ក្នុងទន្លេដែលមានជាតិពុលពីមួយឆ្នាំទៅមួយឆ្នាំ ប៉ះពាល់សុខភាពប្រជាពលរដ្ឋដែលទាមទារ ការអប់រំ ផ្សព្វផ្សាយឱ្យបានទូលំទូលាយថែមទៀត ជាពិសេសបញ្ហាសំរាមដែលកកស្ទះមុខលំនៅដ្ឋានរបស់ប្រជាពលរដ្ឋ និងរាយប៉ាយរថយន្តចូលមិនរួចផ្លូវតូចចង្អៀត មិនទាន់យល់ដឹងពីវិធីញែកសំរាមនៅមានការចោលសំរាមផ្តេសផ្តាស ហើយម្យ៉ាងក្រុមហ៊ុនមិនសូវយកចិត្តទុកដាក់ប្រមូលបានទាន់ពេលវេលាកំណត់។

- **ការងារលូបង្ហូរទឹកស្អុយះ** ចំពោះប្រព័ន្ធលូបង្ហូរទឹកស្អុយ ថ្វីត្បិតតែមិនទាន់បានស្ថាបនាតែនឹងខិតខំគៀងគរប្រភពថវិកា ដើម្បីកសាងថ្មីឱ្យឆ្លើយតបទៅនឹងតម្រូវការ និងស្ថានភាពជាក់ស្តែងនៃកំណើនប្រជាពលរដ្ឋក្នុងមូលដ្ឋានដែលក្នុងនោះត្រូវទាមទារការស្ថាបនាប្រព័ន្ធលូថ្មីៗ ។
- **ការងារគ្រប់គ្រងគ្រោះមហន្តរាយះ** សង្កាត់មានគណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់សង្កាត់ដែលដឹកនាំអំពីការ បង្ការទប់ស្កាត់គ្រោះ អគ្គីភ័យនិងគ្រោះទឹកជំនន់។ សង្កាត់បានធ្វើការណែនាំដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋានឱ្យយល់ដឹង និងចេះប្រុងប្រយត្ន័ជាប្រចាំ ។ ដោយមានការសហការពីអង្គការដៃគូនានាបានជួយឧបត្ថម្ភ និងគាំទ្រជួយបណ្តុះបណ្តាលដល់ថ្នាក់ភូមិ និងប្រជាពលរដ្ឋ។ ទោះបីមានការខិតខំយ៉ាងដូចនេះក្តីសង្កាត់ក៏នៅជួបប្រទះនូវ គ្រោះអគ្គីភ័យ និងគ្រោះទឹកជំនន់បណ្តាលឱ្យឆេះផ្ទះ និងបាក់ច្រាំងទន្លេរៀងរាល់ឆ្នាំ ដែលបង្កនូវផលប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងខូចខាតហេដ្ឋារចនាសម្ព័ន្ធមួយចំនួន។

### ២.១.៣ ផ្នែករដ្ឋបាល និងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ

សង្កាត់បានអនុវត្តការងារក្រោមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់ ក្នុងនោះដែលសង្កាត់ក៏មាន នៅគណៈបញ្ជាការឯកភាពសង្កាត់ដែលបាននឹងកំពុងអនុវត្តនូវគោលនយោបាយ ភូមិ សង្កាត់ មានសុវត្ថិភាព ធានាបាននូវលក្ខណៈសម្បត្តិ ៥ យ៉ាងគ្មានសកម្មភាព លួច ឆក់ ប្លន់ គ្រប់ប្រភេទ គ្មានការផលិតចែកចាយ និង ប្រើប្រាស់គ្រឿងញៀនខុសច្បាប់ គ្មានអំពើរពេស្យាចារ ការជួញដូរស្ត្រី និងកុមារ គ្មានអំពើហឹង្សាក្នុងគ្រួសារ គ្មាន ក្មេងទំនើង គ្មានការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ គ្មានការប្រើប្រាស់សារធាតុជាតិផ្ទុះខុសច្បាប់ និង បទល្មើសគ្រប់ប្រភេទ ។ សង្កាត់កំពុងគ្រប់គ្រងអនុវត្តការងាររបស់ខ្លួនជាប្រចាំ ។

#### ក.ការងាររដ្ឋបាលដែនដី និងអភិបាលកិច្ចះ

ដើម្បីធានាការគ្រប់គ្រង និងបំរើសេវាសាធារណៈ ការថែរក្សាសន្តិសុខសណ្តាប់ធ្នាប់សុវត្ថិភាពសង្គមជូន ដល់ប្រជាជនឱ្យបានល្អប្រសើរក្នុងមូលដ្ឋាន និងយោងលើច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ដែល ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រ .ក.ម/០៣០១/១៥ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០០១ ជាត្រីវិស័យ ក្នុងការបំពេញភារៈកិច្ច។ ក្រុមប្រឹក្សាសង្កាត់ក្បាលកោះ បានយកចិត្តទុកដាក់បម្រើប្រជាជនប្រកបដោយប្រសិទ្ធិ ភាព និងទាន់ពេលវេលានូវរាល់ឯកសារដែលជាតម្រូវការប្រើប្រាស់របស់ប្រជាជន ។

#### ខ.ការពង្រឹងសមត្ថភាពះ

ក្រុមប្រឹក្សាសង្កាត់ តែងតែទទួលបាននូវការបណ្តុះបណ្តាលជាច្រើន ដើម្បីតម្រង់ទិសក្រុមប្រឹក្សាសង្កាត់ ឱ្យអនុវត្តបានត្រឹមត្រូវទៅតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

គណៈកម្មាធិការ គណៈកម្មការជនបង្គោលនានា ត្រូវបានរៀបចំឡើងដើម្បីជួយដល់ក្រុមប្រឹក្សាសង្កាត់ ព្រមទាំងបានផ្សព្វផ្សាយពីតួនាទីភារៈកិច្ចរបស់ខ្លួនបានយល់ដឹងត្រឹមត្រូវ ។

ស្មៀន និងមន្ត្រីជំនួយការ ត្រូវបានទទួលនូវការបណ្តុះបណ្តាលជាច្រើនពីសាលារាជធានីសាលាខណ្ឌ និងក្រុមប្រឹក្សាសង្កាត់ពីការងាររដ្ឋបាល និងទម្រង់ឯកសាររដ្ឋបាលទៅតាមសារាចរណែនាំរបស់ក្រសួងមហាផ្ទៃ ស្តីពីកិច្ចការរដ្ឋបាលឃុំ សង្កាត់ ។

មេភូមិនិងជំនួយការមេភូមិក៏ត្រូវបានរៀបចំទៅតាមច្បាប់ និងនីតិវិធីនៃការជ្រើសរើសភូមិរបស់ក្រសួង មហាផ្ទៃនិងបានបំពេញតួនាទី ភារៈកិច្ចទៅតាមច្បាប់បានល្អប្រសើរ ។

#### គ ការងារសន្តិសុខ ៖

អនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាលជាពិសេស គឺការអនុវត្តន៍គោលនយោបាយភូមិឃុំមាន សុវត្ថិភាពនឹងឆ្លងតាមការរៀបចំវេទិការសាធារណៈពិគ្រោះយោបល់ ប្រចាំខែធ្វើឱ្យប្រជាជនមានការចូលរួមយ៉ាង សស្រាក់សស្រាំ និងផ្តល់កិច្ចសហការណ៍ផ្តល់ដំណឹង ផ្តល់ពីកង្វល់ជូនដល់គណៈបញ្ជាការឯកភាពសង្កាត់លើ

ខ្លឹមសារ គោលនយោបាយទាំង ៩ចំណុចរបស់រាជរដ្ឋាភិបាល ។ អំពើល្មើសច្បាប់ទាំងឡាយត្រូវបានបង្ក្រាប បង្ការទប់ស្កាត់បានទាន់ពេលវេលា និងកាត់បន្ថយបានជាអតិបរិមា ។

**ឃ.ការងារសណ្តាប់ធ្នាប់សាធារណៈ ៖**

ការរៀបចំសណ្តាប់ធ្នាប់សាធារណៈ ក៏បានអនុវត្តន៍ជាប្រចាំដើរទន្ទឹម និងការអប់រំ ណែនាំ និងវិធានការណ៍រដ្ឋបាលមួយចំនួន។

## ២.២ បញ្ហាប្រឈម

### ២.២.១ ផ្នែកធនធានហិរញ្ញវត្ថុ

ក្រុមប្រឹក្សាឃុំ សង្កាត់ទទួលបានចំណូលតែពីប្រភពមូលនិធិឃុំ សង្កាត់មានមកពីប្រភពទុនចូលរួមរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន និងប្រភពដៃគូរអភិវឌ្ឍតាមរយៈគម្រោងកម្មវិធីនានាប៉ុណ្ណោះ។ ចំណូលផ្ទាល់ដែលរួមមានប្រភពចំណូលសារពើពន្ធ ប្រភពចំណូលមិនមែនសារពើពន្ធ និងកម្រៃសេវាផ្សេងៗនៅមិនទាន់មានការសិក្សា និងពិចារណានៅឡើយ។ ទំហំធនធានហិរញ្ញវត្ថុសម្រាប់អភិវឌ្ឍមូលដ្ឋានមិនទាន់ឆ្លើយតបទៅនឹងទំហំតម្រូវការអភិវឌ្ឍន៏ជាក់ស្តែងនៅឡើយទេ។ ការឆ្លើយតបរបស់ក្រុមប្រឹក្សា ឃុំសង្កាត់ចំពោះតម្រូវការអាទិភាព និងបន្ទាន់របស់ពលរដ្ឋនៅមានកម្រិតទាប។ បញ្ហាទាំងអស់នេះមានការស្មុគស្មាញ ដែលទាមទារឱ្យមានការសិក្សាស៊ីជម្រៅ និងមានការឯកភាពគ្នាក្នុងចំណោមអ្នកពាក់ព័ន្ធទាំងអស់នៅក្នុងរាជរដ្ឋាភិបាល។ អវត្តមានប្រភពចំណូលផ្ទាល់របស់ឃុំ សង្កាត់វានឹងធ្វើឱ្យប៉ះពាល់ដល់ប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលឃុំ សង្កាត់ដែលជាគ្រឹះនៃប្រជាធិបតេយ្យ។

### ២.២.២ ភាពក្រីក្រ

ភាពក្រីក្រក្នុងមូលដ្ឋាននៅមានកម្រិត ដោយសារលទ្ធភាពនៃការវិយោគថវិកាសម្រាប់អភិវឌ្ឍឃុំ សង្កាត់នៅមានកម្រិត។ ហើយភាពក្រីក្រនេះដែលកើតមានឡើងនៅពេលដែលមនុស្សម្នាក់ ឬគ្រួសារមិនអាចរកធនធានដែលត្រូវការដើម្បីបំពេញតាមតម្រូវការជាមូលដ្ឋានរបស់ពួកគេ។ ជាក់ស្តែងប្រជាជនមានជីវភាពក្រីក្រអាចបណ្តាលមកពីភាពគ្មានការងារធ្វើ ការបាត់បង់ការងារភ្លាមៗអសមត្ថភាពការងារ ឬរបួស និងជំងឺ ដែលធ្វើឱ្យប៉ះពាល់ក្នុងសេដ្ឋកិច្ច ប្រចាំថ្ងៃរបស់ពួកគេ។

### ២.២.៣ ផ្នែកគមនាគមន៍

ការងារគមនាគមន៍សង្កាត់ក៏នៅមានផ្លូវដីស ផ្លូវទល់ ផ្លូវតូចចង្អៀតជាច្រើនទៀត និងផ្លូវដែលបានស្ថាបនារួចហើយមានការខូចខាតទៅវិញ ដោយសារនៅរដូវវស្សាមាន ទឹកភ្លៀង និងទឹកជំនន់លិច។ ផ្លូវខ្លះខ្វះប្រព័ន្ធលូ ផ្លូវចាស់ទ្រុឌទ្រោម ការស្ថាបនាផ្លូវកន្លងមកនៅខ្វះបច្ចេកទេស និងនៅមានការសង់លំនៅដ្ឋានរំលោភលើចំណីផ្លូវ

ហើយមានការដាក់លក់ដូរលើចិញ្ចើមផ្លូវ។ លើសពីនេះនៅមានផ្លូវជាច្រើនខ្សែទៀតដែលមិនទាន់មានភ្លើងបំភ្លឺសាធារណៈដែលទាមទារការចូលរួមពីប្រជាពលរដ្ឋនៅតាមផ្លូវនោះ។

**២.២.៤ ផ្នែកពាណិជ្ជកម្ម និងអាជីវកម្ម**

តាមការអង្កេតជាក់ស្តែងមូលដ្ឋានពាណិជ្ជកម្ម អាជីវកម្មភាគច្រើនមានលក្ខណៈជាគ្រួសារដែលទទួលបានផលចំណូលតិចតួច។

**២.២.៥. ផ្នែកឧស្សាហកម្ម និងសិប្បកម្ម**

ដោយនៅមានសិប្បកម្មមួយចំនួនដែលបានផលិតឡើងរបស់ប្រជាពលរដ្ឋ ខ្វះគុណភាពមិនសមស្របតាមស្តង់ដារ និងការធ្វើអាជីកម្មមួយចំនួនមិនទាន់ច្បាប់អនុញ្ញាតត្រឹមត្រូវ តាមការអង្កេតកន្លងមកបញ្ហាប្រឈមខាងលើ ដោយសារក្នុងផលិតកម្មមានបច្ចេកទេសទាបឧបករណ៍សម្ភារៈប្រើប្រាស់មិនទាន់គ្រប់គ្រាន់ និងទំនើបពិសេសការយល់ដឹងរបស់ម្ចាស់សិប្បកម្មនៅមានកំរិត និងមិនគោរពទៅតាមច្បាប់ស្តីពីការគ្រប់គ្រងសិប្បកម្ម។

**២.២.៦ ផ្នែកទេសចរណ៍**

នៅមានទីតាំងមួយចំនួនប្រកបអាជីវកម្មដោយគ្មានអាជ្ញាប័ណ្ណ ភាគច្រើនអាជីវកម្មភោជនីយដ្ឋានគ្មានសោភ័ណ្ឌភាព គ្មានចំណតយានយន្តតូច បានបង្កផលប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងមួយចំនួនទៀតមិនសូវយកចិត្តទុកដាក់លើការ ការពារសន្តិសុខ សុវត្ថិភាពដល់ភ្ញៀវ និងការកត់ត្រាអត្តសញ្ញាណភ្ញៀវ។

**២.២.៧ ផ្នែកអប់រំ និងយេនឌ័រ**

**ក.ផ្នែកអប់រំ**

ផ្អែកតាមលទ្ធផលជាក់ស្តែងក្នុងឆ្នាំ ២០១៧ បានបង្ហាញថា៖

កុមារក្នុងវ័យមត្តេយ្យ(៣ទៅ៥ឆ្នាំ)បានចូលរៀន ២៦,៣៥%កុមារដល់វ័យ (អាយុ៦ ឆ្នាំ) បានចូលរៀន ៩៥% កុមារក្នុងវ័យបឋមសិក្សា (៦ដល់១១ឆ្នាំ) បានចូលរៀន ៩៥% កុមារអាយុ ១២ ដល់១៤ឆ្នាំ បានចូលរៀន ៩៣% ពិតមែនតែលទ្ធផលជាក់ស្តែងខាងលើបានបង្ហាញនូវការ រីកចំរើនលើសបណ្តាលឆ្នាំកន្លងទៅ ប៉ុន្តែមិនទាន់ឆ្លើយតបទៅនឹងចំណុចដៅរបស់ថ្នាក់ជាតិនៅឡើយទេ។ ដោយនៅមានបញ្ហាប្រឈមមួយចំនួន ដែលជាឧបសគ្គក្នុងការអនុវត្តដូចជា៖ កម្រិតជីវភាពប្រជាពលរដ្ឋ មួយចំនួនជួបការលំបាក តម្រូវការកំលាំងកូនជួយការងារក្នុងផ្ទះ ជួយប្រកបរបរទ្រទ្រង់ជីវភាពគ្រួសារ (លក់កាសែត , ដើរលក់របស់របរតាមហាង , ដើររើសកាកសំណល់) (០ដល់១៧ ឆ្នាំ) តាមកម្រិតអាយុនៅមិន ទាន់ច្បាស់លាស់អនរក្ខជនមានស្ថិតិតែរកមនុស្សមិនឃើញ ។ ក្នុងសង្កាត់មានតែសាលាបឋមសិក្សា ០៤ កន្លែងមិនទាន់សមាមាត្រនឹងចំនួនសិស្ស សម្ភារៈបរិក្ខាចាំបាច់( អាគារ ទីធ្លា បង្គន់ កន្លែងលាងដៃ តុ កៅអី) មិនទាន់គ្រប់គ្រាន់។ បញ្ហាប្រឈមទាំងអស់នេះហើយដែលបន្តស្ថិតនៅជាការលំបាកក្នុងការអនុវត្តនូវគោលនយោបាយរបស់ថ្នាក់ជាតិ៣ចំណុចសំខាន់ៗគឺ៖១-ការប្រមូលកុមារចូលរៀនប្រកបដោយ

សមធម៌ ២-ការពង្រឹងគុណភាព និងប្រសិទ្ធភាពអប់រំ ៣-ការអភិវឌ្ឍន៍សមត្ថភាព និងស្ថាប័នដែលទាមទារប្រមូលគ្រប់ ធនធាន ទាំងធនធានមនុស្ស ថវិកា សម្ភារៈទើបអាចដោះស្រាយបញ្ហាបានដោយជោគជ័យ។

**ខ. ផ្នែកយេនឌ័រ**

ទន្ទឹមនេះក៏មានស្ត្រីមួយចំនួននៅតែប្រឈមទៅនឹងអំពើហិង្សាក្នុងគ្រួសារ ការជួញដូរស្ត្រី ការរំលោភផ្លូវភេទ ការសេពគ្រឿងស្រវឹង ការប្រព្រឹត្តល្បែងស៊ីសង បានផ្តើមចេញពីការមិនគោរពសិទ្ធិកាតព្វកិច្ចក្នុងរង្វង់គ្រួសារ ចាញ់ការបោកបញ្ឆោតពីសំណាក់ជនខិលខូច អស្ថេរភាពជីវភាពរស់នៅប្រចាំថ្ងៃ ការទទួលយកនូវវប្បធម៌ពាលាអាវ៉ាសែ ដែលសហគមន៍ និងស្ត្រីទាំងអស់គប្បីខិតខំបង្កើនការយកចិត្តទុកដាក់ខ្ពស់ ។

**២.២.៨ ផ្នែកសុខាភិបាល និងបរិស្ថាន**

**ក. ផ្នែកសុខាភិបាល**

ដោយមានប្រជាពលរដ្ឋមួយចំនួនតូចមិនយកកូនចៅទៅ ចាក់ថ្នាំបង្ការ និងមិនយកចិត្តទុកដាក់ថែទាំសុខភាព និងបង្កជម្ងឺឆ្លងផ្សេងៗ។ ស្ត្រីមួយចំនួនតូចមិនទៅទទួលយក សេវាសុខភាពបន្តពូជដោយនៅមានការអៀនខ្មាសពិសេសតាមសហគមន៍ ក្រីក្រនិង សំណង់មិនរៀបរយ ។ បន្ទប់ពិគ្រោះព្យាបាលជម្ងឺ និងឱសថស្ថានមួយចំនួនគ្មានច្បាប់អនុញ្ញាតត្រឹមត្រូវ និងនៅមានចរាចរឱសថក្លែងក្លាយ ឱសថហួសកាលកំណត់ប្រើប្រាស់តាមបណ្តាឱ្យឱសថស្ថានរងមួយចំនួនតូច ។

**ខ. ផ្នែកបរិស្ថាន**

ដោយសារ សង្កាត់ស្ថិតនៅជាប់មាត់ទន្លេមេគង្គហេតុនេះហើយវាបណ្តាលឱ្យមានផលប៉ះពាល់ដល់ សុខភាពបរិស្ថានដូចជា ការបង្ហូរកាកសំណល់ រឹង រាវ ការបង្ហូរលូទឹកស្អុយ គ្រោះមហន្តរាយផ្សេងៗ ដែលធ្វើឱ្យប៉ះពាល់ដល់ប្រជាពលរដ្ឋរស់នៅទីនោះ ។

**២.២.៩ ផ្នែករដ្ឋបាល សន្តិសុខ និងសណ្តាប់ធ្នាប់**

ដោយបញ្ហាប្រឈមនៅតែកើតមានដែលតម្រូវឱ្យសង្កាត់យកចិត្តទុកដាក់ និងដោះស្រាយជាបណ្តើរៗដូចជា៖ ការលួចឆក់ប្លន់ ការគំរាមកំហែង ការប្រើប្រាស់គ្រឿងញៀន ការផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរជូនប្រជាពលរដ្ឋការគ្រប់គ្រងអ្នកស្នាក់នៅបណ្តោះអាសន្ន អំពើហិង្សាក្នុងគ្រួសារ ក្មេងទំនើង ល្បែងស៊ីសង សន្តិសុខសណ្តាប់ធ្នាប់សាធារណៈសមត្ថភាពមន្ត្រីរាជការសម្រាប់ការចុះបញ្ជីអត្រានុកូលដ្ឋាន និងការផ្តល់សេវាផ្សេងៗដើម្បីធានានូវសន្តិសុខ សុវត្ថិភាពសង្គមឆ្លើយតបនូវអភិបាលកិច្ចល្អ ។

## ២.៣ ដំណោះស្រាយ

### ២.៣.១ ការកាត់បន្ថយភាពក្រីក្រ និងជំរុញឱ្យមានការអភិវឌ្ឍតាមមូលដ្ឋាន

ការកាត់បន្ថយភាពក្រីក្រជាផ្នែកមួយដ៏សំខាន់ដែលរដ្ឋាភិបាលបានយកចិត្តទុកដាក់ក្នុងការជំរុញឱ្យមានការបង្កើនមូលនិធិវិនិយោគតាម ឃុំសង្កាត់បន្ថែមទៀតដើម្បីឱ្យមូលនិធិអភិវឌ្ឍន៍ មូលដ្ឋានតាមប្រព័ន្ធវិមជ្ឈការ និង វិសហមជ្ឈការនេះមានឥទ្ធិពលពេញលេញ នៅក្នុងទប់ស្កាត់ភាពក្រក្រីក្នុងមូលដ្ឋាន។ ដើម្បីឱ្យឃុំ សង្កាត់ការអភិវឌ្ឍប្រកបដោយប្រសិទ្ធភាពនៅក្នុងគម្រោងអភិវឌ្ឍន៍ ការកាត់បន្ថយភាពក្រីក្រនៅតាមមូលដ្ឋានចាំបាច់ត្រូវពង្រឹងប្រព័ន្ធគ្រប់គ្រងតាមបែបវិមជ្ឈការ និងវិសហមជ្ឈការដែលបានកំពុងអនុវត្តកន្លងមកជាពិសេសនៅក្នុងការជំរុញឱ្យមានការចូលរួមពីពលរដ្ឋមូលដ្ឋាន ការធានាឱ្យមានតម្លាភាព និងគណនេយ្យភាពក្នុងការគ្រប់គ្រងការអភិវឌ្ឍរបស់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ការកាត់បន្ថយភាពក្រីក្រដូចជា ជំរុញឱ្យមានការងារធ្វើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅក្នុងដំណើរការកសាងផែនការ ដែលមានការចូលរួមក្នុងការកំណត់តម្រូវ ការអភិវឌ្ឍនៅមូលដ្ឋានការចូលរួមគាំទ្រទៅលើគម្រោងអភិវឌ្ឍន៍របស់ឃុំ សង្កាត់ដោយសប្បុរសជន និងអង្គការដែលមិនមែនរាជរដ្ឋាភិបាលនានាជាច្រើន។

ដូចនេះ ការកាត់បន្ថយភាពក្រីក្រចាំបាច់ត្រូវចូលរួមដោយការអនុវត្តគម្រោងអភិវឌ្ឍន៍ឃុំ សង្កាត់នានាដែលជាទូទៅគម្រោងទាំងអស់នោះមានជាគម្រោងវិនិយោគខ្នាតតូចៗគម្រោងវិនិយោគនានា ដែលជាគម្រោងហេដ្ឋារចនាសម្ព័ន្ធគម្រោងលើកកម្ពស់ជីវភាពរស់នៅ ឬគម្រោងបង្កើនប្រាក់ចំណូល និងគម្រោងសេវានានាក្នុងគោលបំណងដោះស្រាយតម្រូវការជាបន្ទាន់នៅមូលដ្ឋាន និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅមូលដ្ឋានឱ្យកាន់តែមានភាពល្អប្រសើរឡើងៗ និងភាពរីកចម្រើន។

### ២.៣.២កែលម្អប្រព័ន្ធទូរគមនាគមន៍

ដោយមានការមើលឃើញថា ប្រព័ន្ធទូរគមនាគមន៍នៅតែជាកត្តាមួយដ៏សំខាន់បំផុតសម្រាប់ជាផ្លូវដែលឱ្យប្រជាពលរដ្ឋធ្វើដំណើរដើម្បីឱ្យប្រកបដោយសុវត្ថិភាព។ ដូច្នេះហើយខាងសង្កាត់ ក៏បានសម្រេចចិត្តជួសជុលចាក់ផ្លូវបេតុងគ្មានសរសៃដែកប្រវែង ៦៥ម៉ែត្រ ទទឹង៤ ម៉ែត្រ(ទីតាំងព្រែកធំ២), ប្រវែង ១៤៦ម៉ែត្រ ទទឹង ៤ម៉ែត្រ, ប្រវែង ១៧៦ម៉ែត្រ ទទឹង៤ ម៉ែត្រ និងប្រវែង៧៣ ម៉ែត្រ ទទឹង ៣ម៉ែត្រ(ព្រែកធំ១) និងមានការដាក់លូមូលដោះទឹកទំហំ ០,៦ម៉ែត្រ ដែលមានប្រវែង១៣៥ម៉ែត្រ (ទីតាំងព្រែកធំ១) ដែលចូលទៅក្នុងកម្មវិធីវិនិយោគរបស់ឃុំ សង្កាត់ព្រមទាំងទំនាក់ទំនងជាមួយ សប្បុរសជននានា និងអង្គការក្រៅរាជរដ្ឋាភិបាល ជួយសម្រួលដល់ការដឹកទំនិញនិងសកម្មភាពសេដ្ឋកិច្ចប្រជាពលរដ្ឋនៅក្នុងសង្កាត់ក្បាលកោះ។ កត្តាទាំងអស់នេះ ហើយទើបអាចដោះស្រាយនូវបញ្ហាដែលប្រជាពលរដ្ឋក្នុងតំបន់ជួបប្រទះនៅសង្កាត់នោះ។

### ២.៣.៣ ពង្រឹងផ្នែកពាណិជ្ជកម្ម និងអាជីវកម្ម

ដោយសារអាជីវករនៅមានកម្រិត មិនមានជំនាញប្រកបមុខរបរច្បាស់លាស់ទើបធ្វើឱ្យទទួលបានចំណូលតិច។ ដូច្នេះខាងសង្កាត់ត្រូវរៀបចំ វគ្គបណ្តុះបណ្តាលជំនាញ វិជ្ជាជីវៈមុខរបរប្រចាំថ្ងៃ របស់ប្រជាពលរដ្ឋ ដើម្បីកាត់បន្ថយនូវបញ្ហាដូចជាភាពក្រីក្រ ដែលកំពុងតែកើតឡើងប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

### ២.៣.៤ ផ្នែកឧស្សាហកម្ម និងសិប្បកម្ម

ដើម្បីដោះស្រាយនូវបញ្ហាដែលជួបប្រទះខាងលើ និងដើម្បីអភិវឌ្ឍន៍វិស័យនេះឱ្យកាន់រីកចំរើនជាងមុន នោះចៅសង្កាត់ក្បាលកោះត្រូវមានការរៀបចំដូចជា ការពន្យល់ប្រជាពលរដ្ឋឱ្យបានច្រើនទាក់ទិននិងច្បាប់ស្តីពីការគ្រប់គ្រងឧស្សាហកម្ម និងសិប្បកម្ម ហើយគ្រប់ប្រជាពលរដ្ឋទាំងអស់មុននិងបើកធ្វើឧស្សាហ៍កម្ម ឬសិប្បកម្មអ្វីមួយត្រូវមានសមត្ថភាព ជំនាញច្បាស់លាស់ មានសម្ភារៈ បច្ចេកទេសគ្រប់គ្រាន់ និងត្រូវមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ចរបស់ឃុំ សង្កាត់ ។ បន្ថែមជាងនេះសង្កាត់ត្រូវធ្វើការឱ្យសកម្មពាក់ព័ន្ធការចុះទៅពន្យល់អប់រំ ផ្សព្វផ្សាយច្បាប់សំខាន់ៗដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋាននោះដើម្បីឱ្យពួកគាត់កាន់តែមានយល់ដឹងខ្ពស់ និងអនុវត្តទៅបានជោគជ័យ។

### ២.៣.៥ ផ្នែកទេសចរណ៍

ដើម្បីឱ្យមានការរីកចំរើនផ្នែកទេសចរណ៍នៅក្នុងសង្កាត់ក្បាលកោះ ចៅសង្កាត់ត្រូវមានវិធានការក្នុងការរៀបចំឱ្យមានសោភ័ណ្ឌភាពក្នុងសង្កាត់ទាំងមូលដូចជា ការដាំស្មួនច្បារនៅតាមដងផ្លូវដាក់ភ្លើងនៅតំបន់ភូមិ ឃុំ សង្កាត់ទាំងអស់ឱ្យភ្លឺស្អាតនៅពេលយប់ កុំមានជនអនាមិកមកបង្ករឿងធ្វើខូចឈ្មោះសង្កាត់ ត្រូវរៀបចំឱ្យកន្លែងចតឡានប្រកបសណ្តាប់ធ្នាប់ ធានាសុវត្ថិភាពដល់ភ្ញៀវពេលមកដំណើរកំសាន្ត ។

### ២.៣.៦ ការលើកកម្ពស់គុណភាពអប់រំ និងសមភាពយេនឌ័រ

#### ក. លើកម្ពស់គុណភាពការអប់រំ

កុមារនៅសង្កាត់ក្បាលកោះ ដែលគ្រប់អាយុ ហើយមិនបានចូលរៀន គឺសង្កាត់ត្រូវទៅពន្យល់ណែនាំដល់អាណាព្យាបាល ដើម្បីឱ្យគាត់នាំកូនមកចុះឈ្មោះចូលរៀនបានគ្រប់ៗគ្នានៅសាលារដ្ឋ ប្រសិនបើគាត់ពុំសូវមានលទ្ធភាពនាំកូនចូលរៀនសាលាឯកជន ហើយខាងសង្កាត់ត្រូវជំរុញការបង្កើតថ្នាក់អប់រំក្រៅប្រព័ន្ធបន្ថែមទៀត។

#### ខ.សមភាពយេនឌ័រ

ដើម្បីលើកកម្ពស់សិទ្ធិស្ត្រី និងកុមារឱ្យមានសមត្ថភាពរវាងភាពជាដៃគូ ខាងសង្កាត់ត្រូវមានការជំរុញគាំទ្រដូចជា៖

- អប់រំផ្សព្វផ្សាយពីសិទ្ធិតួនាទី បុរសនិងស្ត្រី
- ជំរុញលើកទឹកចិត្តស្ត្រីចូលរួមក្នុងការអភិវឌ្ឍន៍

- ផ្សព្វផ្សាយច្បាប់អំពើហឹង្សាក្នុងគ្រួសារ
- ផ្សព្វផ្សាយច្បាប់ប្រឆាំងការជួញដូរ រំលោភបំពានផ្លូវភេទទៅលើស្ត្រី និងកុមារ
- ផ្សព្វផ្សាយតួនាទីស្ត្រីក្នុងកិច្ចអភិវឌ្ឍន៍
- ផ្សព្វផ្សាយយេនឌ័រ និងសិទ្ធិកុមារ។

### ២.៣.៧ ផ្នែកសុខាភិបាល និងបរិស្ថាន

#### ក. ផ្នែកសេវាសុខាភិបាល

ដើម្បីជំរុញឱ្យសេវាសុខាភិបាលកាន់តែមានភាពល្អប្រសើរឡើងនៅក្នុងសង្កាត់ក្បាលកោះ គឺត្រូវផ្តើមចេញពីការជួយផ្គត់ផ្គង់សម្ភារៈ ថ្នាំពេទ្យឱ្យដល់មណ្ឌលសុខភាពពីសំណាក់មន្ទីសុខាភិបាល និងធ្វើការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋទូទៅឱ្យឈប់ធ្វើការសម្រាលកូនដោយឆ្មបបុរាណ ហើយធ្វើការពន្យល់ណែនាំ បណ្តុះបណ្តាលទៅក្រុមគ្រូពេទ្យឆ្មបដែលមានស្រាប់ជាប្រចាំឱ្យមានចំនេះដឹងបន្ថែមទៅលើជំនាញរបស់គាត់ ដើម្បីឱ្យគាត់ដឹងពីរបៀបប្រើប្រាស់នូវសម្ភារៈ ឧបករណ៍ប្រើប្រាស់ហើយងាយស្រួលក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋ។ មួយវិញទៀតត្រូវផ្សព្វផ្សាយឱ្យស្ត្រីបានយល់ដឹងអំពីសុខភាពអនាម័យ និងសញ្ញានានាដែលត្រូវប្រុងប្រយ័ត្ននៅពេលមានផ្ទៃពោះ និងនៅពេលសម្រាលកូន ហើយមានការទៅពិនិត្យសុខសុវត្ថិភាពកូនមុនពេលយ៉ាងតិចពីរដង និងពង្រឹងសេវាសម្រាលកូន នៅមណ្ឌលសុខភាព។ ជាងនេះទៅទៀតត្រូវអប់រំដល់ប្រជាពលរដ្ឋដូចជា អំពីការអនាម័យចំណីអាហារ គាំទ្រអាហារូបត្ថម្ភ អប់រំសុខភាពផ្លូវចិត្ត អប់រំទប់ស្កាត់ជំងឺអេដស៍ និងកាមរោគ ដោយការប្រើប្រាស់បង្គន់អនាម័យស្អាត និងផ្តល់ជាតិវីតាមីន និងចាក់វ៉ាក់សាំងការពារជម្ងឺដល់កុមារជាដើម ។

#### ខ. បរិស្ថាន

ដើម្បីឱ្យបរិស្ថាននៅសង្កាត់ក្បាលកោះ មានសោភ័ណ្ឌភាពល្អស្រស់ស្អាត ត្រូវមានការចូលរួមសហការពីប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋានទាំងអស់នៅទីនោះ ហើយអាជ្ញាធរសង្កាត់គួរតែផ្សព្វផ្សាយច្បាប់ស្តីបរិស្ថាន បើកវគ្គបណ្តុះបណ្តាលដល់ប្រជាពលរដ្ឋឱ្យយល់ដឹងអំពីការរស់នៅប្រកបដោយអនាម័យ ដូចពាក្យស្លោក ហូបស្អាត ផឹកស្អាត ការរស់នៅ ស្អាតព្រមទាំងរៀបចំកន្លែង ដាក់កាកសំណល់ឱ្យមានរបៀបរៀបរយ និងវិធីបង្កាជម្ងឺកូវីដ១៩ ដើម្បីឱ្យប្រជាពលរដ្ឋទទួលបាននូវសុខភាពល្អ ។

### ២.៣.៨ ការរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់

ដើម្បីរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈនៅសង្កាត់ក្បាលកោះ ឱ្យប្រកបដោយសុខសុវត្ថិភាពសម្រាប់ប្រជាពលរដ្ឋរស់នៅក្នុងសង្កាត់។ ហើយឃុំ សង្កាត់ត្រូវទប់ស្កាត់នូវរាល់បញ្ហាដែលអសន្តិសុខមួយចំនួនដូចជា លុបបំបាត់ការលេងល្បែងស៊ីសងគ្រប់ប្រភេទ ចុះធ្វើការផ្សព្វផ្សាយតាមបណ្តាលភូមិពីការជួញដូរផ្លូវភេទ និងមនុស្ស ប្រើប្រាស់គ្រឿងញៀនសហការជាមួយប្រជាពលរដ្ឋចំពោះជនដែលចូលថ្មីត្រូវផ្តល់ដំណឹងជូនដល់

អាជ្ញាធរមានសមត្ថកិច្ច ហើយអាជ្ញាធរត្រូវយកចិត្តទុកក្នុងការអនុវត្តយ៉ាងហ្មត់ចត់ «តាមគោលនយោបាយភូមិឃុំមានសុវត្ថិភាព» ដែលមានលក្ខណៈសម្បត្តិ ៩យ៉ាងដូចខាងក្រោមនេះ៖

- គ្មានសកម្មភាព លួច ឆក់ ប្លន់គ្រប់ប្រភេទ
- គ្មានការផលិត ការចែកចាយ និងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់
- គ្មានអំពើអាណាចារ្យ អំពើហឹង្សាក្នុងគ្រួសារ ការជួញដូរស្ត្រី និងកុមារ
- គ្មានក្មេងទំនើង
- គ្មានលេងល្បែងខុសច្បាប់គ្រប់ប្រភេទ ការប្រើប្រាស់អាវុធខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ
- គ្មានគ្រោះថ្នាក់ចរាចរណ៍
- គ្មានគ្រោះថ្នាក់ដោយសារអាវុធយុទ្ធភណ្ឌមិនទាន់ផ្ទុះ
- មានវិធានការទប់ស្កាត់ គ្រប់គ្រង និងឆ្លើយតបចំពោះគ្រោះមហន្តរាយប្រកបដោយប្រសិទ្ធភាព
- គ្មានការត្រួតពិនិត្យខុសច្បាប់ ។

### ២.៣.៩ ការបង្កើនប្រសិទ្ធភាពការងាររដ្ឋបាល និងអភិបាលកិច្ចល្អ

សង្កាត់បានផ្សព្វផ្សាយការងារអត្រានុកូលដ្ឋាន ការធ្វើសៀវភៅគ្រួសារ ការធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ លិខិតបទដ្ឋាននានា ជូនដល់ប្រជាពលរដ្ឋ។ ការសម្របសម្រួលទំនាស់ក្រុមប្រឹក្សាសង្កាត់សម្របសម្រួលដោយ គតិយុត្តិ គឺជាវិធានការការពារទុកជាមុនដ៏សមស្របបំផុតដែលសង្កាត់ប្រកាន់យក ដើម្បីការពារទំនាស់កុំឱ្យរីករាលដាលខ្លាំងឡើង និងទប់ស្កាត់ក្រុមក្មេងពាល ការប្រើប្រាស់គ្រឿងញៀន និងល្បែងស៊ីសងឱ្យមានការថយចុះជាបណ្តើរៗ។

### ២.៤ ទិសដៅអនាគត

ការងារតាមវិស័យនៅក្នុងសង្កាត់ក្បាលកោះ ផ្អែកទៅតាមផែនការអភិវឌ្ឍន៍ ឃុំ សង្កាត់ បានសម្រេចលទ្ធផលវិជ្ជមានមួយចំនួនសំខាន់ជាងគេគឺ ផ្លូវថ្នល់ សាលារៀន មន្ទីរពេទ្យ ក្រៅពីនោះរួមមានការចុះសំបុត្រអត្រានុកូលដ្ឋាន ការដោះស្រាយទំនាស់ក្នុងគ្រួសារ ការទទួលបានមូលនិធិពី សប្បុរសជន និងអង្គការសង្គម ស៊ីវិលកន្លងមកសម្រាប់ បម្រើលើវិស័យកសិកម្ម សុខាភិបាល និងអនាម័យជាដើម។ ប៉ុន្តែទន្ទឹមនឹងនោះការងារមួយចំនួនពុំទាន់បានសម្រេច ជាដុំកំភួននៅឡើយ ជាពិសេស បញ្ហាសុខាភិបាល បញ្ហាបរិស្ថាន បញ្ហាសន្តិសុខ និងបញ្ហាធនធានមនុស្សក្នុងទិសដៅជំរុញឱ្យការផ្តល់សេវាសាធារណៈរបស់សង្កាត់ រួមទាំងការអភិវឌ្ឍឱ្យមានភាពល្អប្រសើរទៅ ថ្ងៃអនាគតអាជ្ញាធរ សង្កាត់ ព្រមទាំងអាជ្ញាធររដ្ឋបាលថ្នាក់ជាតិ និងស្ថាប័នពាក់ព័ន្ធគួរពិចារណាទៅលើចំណុច៣ជាសំខាន់រួមមានទី១ ការបណ្តុះបណ្តាលធនធានមនុស្ស ទី២ ការបង្កើនថវិកាឃុំ សង្កាត់ និង ទី៣ ការបង្កើនភាពជាម្ចាស់ និងការទទួល ខុសត្រូវរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។

### ២.៤.១ ការបណ្តុះបណ្តាលធនធានមនុស្ស

ថ្វីត្បិតតែយើងត្រូវការការគ្រប់គ្រងនៅក្នុងមូលដ្ឋានដោយតំណាង ដែលកើតឡើងពីសំឡេងគាំទ្ររបស់ប្រជាពលរដ្ឋ ដើម្បីសបញ្ជាក់ពីលទ្ធិប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋានពិតមែន ប៉ុន្តែបុគ្គលដែលបានជ្រើសរើសទាំងនោះពុំទាន់មានសមត្ថភាពពេញលេញក្នុងការធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងដែនដីរបស់ខ្លួននៅឡើយ។ ជាក់ស្តែងអ្នកឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ច្បាប់ពុំចាំបាច់ទាមទារតម្រូវឱ្យជននោះមានចំណេះដឹងកម្រិត សញ្ញាបត្រខ្ពង់ខ្ពស់នោះទេ យ៉ាងហោចណាស់ត្រឹមអាចអាន និងសរសេរភាសាខ្មែរបានគ្រប់គ្រាន់ហើយ។ ដូច្នេះ ជាទិសដៅខ្លីទៅមុខរដ្ឋបាលថ្នាក់ជាតិដែលមានក្រសួងមហាផ្ទៃ ជាអ្នកដឹកនាំការងារនេះគួរតែបើកវគ្គបណ្តុះបណ្តាល សមត្ថភាពដល់ក្រុមប្រឹក្សា ឃុំ សង្កាត់ពាក់ព័ន្ធលើការប្រមូលចំណូល និងគ្រប់គ្រងចំណាយការរៀបចំបញ្ជីសារពើពន្ធ ការរៀបចំនូវគម្រោងថវិកាគម្រោងអភិវឌ្ឍន៍គម្រោងវិនិយោគប្រចាំឆ្នាំជាដើម។ល។ រីឯទិសដៅនៅក្នុងរយៈពេលវែងវិញ គឺធ្វើការកែប្រែច្បាប់ដោយកំណត់លក្ខខណ្ឌតម្រូវសម្រាប់ បេក្ខជនឈរឈ្មោះជាក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវមានសញ្ញាបត្រអាចត្រឹមមធ្យមសិក្សាទុតិយភូមិ ឬអាចទៅដល់ សញ្ញាបត្របរិញ្ញាបត្រដែលមានជំនាញពាក់ព័ន្ធនឹង រដ្ឋបាលសាធារណៈសេដ្ឋកិច្ច ឬការទូត។

### ២.៤.២ . ការបង្កើនភាពជាម្ចាស់ និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាឃុំ សង្កាត់

ការគ្រប់គ្រងរដ្ឋបាល ឃុំសង្កាត់ត្រូវបានអនុវត្តន៍ទៅតាមគោលនយោបាយវិមជ្ឈការ ដែលមានន័យថាឃុំសង្កាត់ទទួលបាននូវភាពជាម្ចាស់លើមុខងារ សិទ្ធិអំណាច និងធនធានពីថ្នាក់ជាតិ។ ប៉ុន្តែបើតាមភាពជាក់ស្តែងយើងសង្កេតឃើញថាភាពជាម្ចាស់ និងការទទួលខុសត្រូវទាំងនេះហាក់នៅមានកម្រិតនៅឡើយ ដោយហេតុថាឃុំ សង្កាត់មិនទាន់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលបន្ទុកលើការងាររបស់ខ្លួន បូករួមទាំងភាពស្ទាក់ស្ទើរនៃការធ្វើវិមជ្ឈការអំណាចពីថ្នាក់ជាតិផង។ ជាការពិតណាស់ ការបង្កើនភាពជាម្ចាស់ និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សា ឃុំ សង្កាត់ នឹងធ្វើឱ្យការផ្តល់សេវាសាធារណៈនៅថ្នាក់ឃុំ សង្កាត់កាន់តែមានភាពល្អប្រសើរ។ ដូច្នេះ សម្រាប់ជាមធ្យោបាយនាពេលអនាគតដ៏ប្រសើរក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចេះពង្រឹងសមត្ថភាពរបស់ខ្លួនតាមរយៈការសិក្សា ស្វែងយល់ពីច្បាប់ និងលិខិតបទដ្ឋាននានា ដើម្បីបង្ហាញពីសមត្ថភាពនៃការទទួលខុសត្រូវទាំងផ្នែករដ្ឋបាល និងផ្នែកព្រហ្មទណ្ឌលើការងាររបស់ខ្លួន។ ជាមួយគ្នានេះផងដែរគណៈកម្មាធិការជាតិគាំទ្រឃុំសង្កាត់ត្រូវជំរុញយន្តការនៃការបែងចែកភារកិច្ចជាក់លាក់រវាង រដ្ឋបាលថ្នាក់កណ្តាល ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ដើម្បីកំណត់ឱ្យបានកាន់តែច្បាស់អំពីភាពជាម្ចាស់របស់ក្រុមប្រឹក្សាឃុំ សង្កាត់។ ទន្ទឹមនឹងនេះផងដែរ ក្រសួងស្ថាប័ន នៅថ្នាក់ជាតិគួរធ្វើកិច្ចសហប្រតិបត្តិការជាមួយគណៈកម្មាធិការជាតិគាំទ្រ ឃុំសង្កាត់ក្នុងការផ្ទេរភារកិច្ច ក្នុងកម្រិតណាមួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់នៅវិស័យដែលមានភាពជាប់ពាក់ព័ន្ធ

ផ្ទាល់ជាមួយប្រជាពលរដ្ឋដូចជា វិស័យកសិកម្ម វិស័យអប់រំ វិស័យសុខាភិបាល និងវិស័យសង្គមកិច្ចជាដើម ដើម្បីឱ្យឃុំ សង្កាត់អាចផ្តល់នូវសេវាទាំងនោះប្រកប ដោយការទទួលខុសត្រូវនៅក្នុងមូលដ្ឋានរបស់ខ្លួន។

សរុបជារួមមក ទន្ទឹមនឹងការរីកចម្រើនរបស់សង្កាត់ក្បាលកោះ ការគ្រប់គ្រងរដ្ឋបាល និងការអភិវឌ្ឍសង្កាត់ នៅមានបញ្ហាប្រឈមជាច្រើននៅលើផ្នែកដ៏សំខាន់ៗក្នុងនោះរួមមានដូចជា ផ្នែកអប់រំ ផ្នែកយេនឌ័រ ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ផ្លូវគមនាគមន៍ ប្រព័ន្ធទឹកស្អាត វិស័យសុខាភិបាល បញ្ហាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងសកម្មភាពនានាក្នុងឃុំ សង្កាត់ នៅមានកម្រិតជាដើម ហើយទាំងអស់នេះសុទ្ធសឹងតែជាបញ្ហាដែលត្រូវទាមទារឱ្យមានដំណោះស្រាយបានសមស្រប ឬការចាត់វិធានក្នុងការដោះស្រាយជាបន្តបន្ទាប់សំដៅធ្វើយ៉ាងណា ដើម្បីកុំឱ្យបញ្ហាទាំងនោះរីករាលដាលក្លាយទៅជាឧបសគ្គរារាំងឃាំងឃាត់ទៅដល់ដំណើរការអភិវឌ្ឍសង្កាត់។ នៅក្នុងការដោះស្រាយបញ្ហា ចំពោះមុខពិតជាមានសារៈសំខាន់ណាស់ ប៉ុន្តែជាការចាំបាច់នោះ អាជ្ញាធរសង្កាត់គួរតែពិនិត្យមើលទៅលើលទ្ធភាព នៅក្នុងការរៀបចំផែនការការងារសម្រាប់អនុវត្តនៅក្នុងពេលខាងមុខ ដើម្បីធ្វើជាត្រីវិស័យចង្អុលទិសបង្ហាញផ្លូវឆ្ពោះទៅរកការរីកចម្រើនប្រកបដោយនិរន្តភាព។

### ២.៤.៣ ការបង្កើនថវិកាឃុំ សង្កាត់

យោងតាមអនុក្រឹត្យលេខ ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្តីពីការធ្វើវិមជ្ឈការអំណាចតួនាទី និងភារកិច្ចទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ត្រង់មាត្រា២០ បានចែងថា ឃុំ សង្កាត់ មានប្រភពធនធានមកពីភូមិទាំងអស់ នៅក្នុងឃុំ សង្កាត់របស់ខ្លួន ឃុំ សង្កាត់ផ្សេងៗរាជរដ្ឋាភិបាល និងក្រសួងស្ថាប័នពាក់ព័ន្ធនានា នៃរាជរដ្ឋាភិបាល អង្គការជាតិ និងអន្តរជាតិនានា ផ្នែកឯកជន និងសប្បុរសជននានាជាដើម។ ថ្វីត្បិតមើលទៅប្រភពធនធានរបស់ ឃុំ សង្កាត់ ហាក់ដូចជាច្រើន ប៉ុន្តែបើតាមជាក់ស្តែងចំណូលថវិការបស់ឃុំ សង្កាត់ជាទូទៅបានមកពីការឧបត្ថម្ភធនពី រាជរដ្ឋាភិបាល និងកម្រៃសេវារដ្ឋបាលផ្សេងៗដូចជា ការងារអត្រានុកូលដ្ឋាន និងការចេញលិខិតអនុញ្ញាតនានាដែលមិនមែនជាសមត្ថកិច្ចរបស់ស្ថាប័នណាមួយ។ បច្ចុប្បន្នថវិការបស់ឃុំ សង្កាត់អាចត្រឹមតែធានាបានពីប្រក្រតីភាពនៃដំណើរការរដ្ឋបាលរបស់ខ្លួនតែប៉ុណ្ណោះ។ ប៉ុន្តែនៅតែពុំទាន់អាចឆ្លើយតបចំពោះការអភិវឌ្ឍន៍នៅថ្នាក់មូលដ្ឋានឱ្យបានពេញលេញនៅឡើយទេ ព្រោះតម្រូវការអភិវឌ្ឍន៍របស់ប្រជាពលរដ្ឋពាក់ព័ន្ធនឹងការស្តារកសាងប្រឡាយទឹក និងជួសជុលផ្លូវ ស្ពាន ត្រូវចំណាយថវិកាខ្ពស់ហួសពីសមត្ថភាពដែលជាក់ស្តែងរបស់ឃុំ សង្កាត់ទៀត។ ដូច្នេះ ដើម្បីអាចធានាបានពីការអភិវឌ្ឍឱ្យបានពេញលេញនៅក្នុងមូលដ្ឋាន រាជរដ្ឋាភិបាលគួរពិនិត្យលទ្ធភាពនៅក្នុងការបង្កើនថវិកាបន្ថែមសម្រាប់ ឃុំ សង្កាត់ ទោះបីជាផ្តល់នៅក្នុងរូបភាពឧបត្ថម្ភ និងការផ្តល់ជំនួយលើគម្រោងនានា។

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវប្រធានបទខាងលើនេះរួចមកហើយ ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ជាការគ្រប់គ្រងរដ្ឋបាលមួយដែលស្ថិតនៅក្នុងប្រព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជារដ្ឋបាលមួយនៅជាប់ជាមួយមូលដ្ឋាន និងប្រជាពលរដ្ឋផ្ទាល់ផងដែរ ។ ក្នុងការគ្រប់គ្រប់រដ្ឋបាលសង្កាត់ក្បាលកោះមានភូមិចំនួន៨ ដែលមានការគ្រប់គ្រងពីចៅសង្កាត់ នឹងសមាជិកក្រុមប្រឹក្សា កិច្ចសហប្រតិបត្តិការ អាជ្ញាធររដ្ឋបាលសង្កាត់ បានខិតខំតស៊ូប្រឹងប្រែង បំពេញតួនាទីរបស់ខ្លួនប្រកបដោយឆន្ទៈទទួលខុសត្រូវខ្ពស់ក្នុងការធានារ៉ាប់រង ថែរក្សាការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សង្គមឱ្យមានស្ថេរភាព និង ការយកចិត្តទុកដាក់ចំពោះការអនុវត្តតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ដូចជា កម្មវិធីវិនិយោគ កម្មវិធីវិនិយោគ៣ឆ្នាំរំកិល ជាពិសេសជួយលើកកម្ពស់ក្នុងការផ្តល់សេវាសាធារណៈឱ្យបានល្អប្រសើរ និង សំដៅលើកកម្ពស់ការអភិវឌ្ឍមូលដ្ឋាន ដើម្បីការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។ រួមជាមួយការសហការចូលរួមចំណែកពីសំណាក់ប្រជាពលរដ្ឋ មន្ត្រី ក្រុមប្រឹក្សាឃុំ សង្កាត់ និងអង្គភាព ស្ថាប័នពាក់ ព័ន្ធនានា ដែលធ្វើឱ្យទទួលបាននូវសមិទ្ធផលនានាដូចជា៖ ផ្លូវថ្នល់ សាលារៀន មន្ទីរពេទ្យ និង ការចូលរួមឧបត្ថម្ភ គាំទ្រពីរដ្ឋាភិបាលក្នុងការជំរុញឱ្យប្រជាពលរដ្ឋយល់ដឹងកាន់តែច្បាស់អំពីច្បាប់ និង ប្រែក្លាយពួកគាត់ឱ្យក្លាយជាប្រជាពលរដ្ឋដែលគោរពច្បាប់ មានចំណេះដឹងកាន់តែច្រើន ដែលអាចជំរុញឱ្យមានការអភិវឌ្ឍសេដ្ឋកិច្ចឈានទៅ រកភាពជោគជ័យនានាពេលខាងមុខ។

ប៉ុន្តែ ទោះបីជាការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់ មានលក្ខណៈល្អប្រសើរ និងដំណើរការទៅមុខក៏ដោយនៅតែទាមទារឱ្យមានការយកចិត្តទុកដាក់គាំទ្រពីថ្នាក់ជាតិ ដើម្បីជួយបំពេញបន្ថែមនៅចំណុចខ្វះខាតជាច្រើនដែលមានដូចជា ពង្រឹងសមត្ថភាពបុគ្គលិកកង្វះធនធានមនុស្សចំណេះដឹងទៅលើប្រព័ន្ធបច្ចេកទេសនៅមានកម្រិតខ្វះប្រភពហិរញ្ញវត្ថុដែលជាកត្តាជះឥទ្ធិពលដល់ការអភិវឌ្ឍន៍ក្នុងសង្កាត់ និងចំនួនប្រជាពលរដ្ឋផងដែល។

សរុបសេចក្តីមក ការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់ នេះពិតជាមានសារៈសំខាន់ខ្លាំងណាស់ សម្រាប់ការបំពេញ កាតព្វកិច្ចក្នុងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព គុណភាព តម្លាភាពឱ្យទាន់ពេលវេលា មានភាពងាយស្រួល និងជាផ្នែកមួយនៃការអភិវឌ្ឍ រីកចម្រើនជឿនលឿននៃប្រទេសជាតិ។

# អនុសាសន៍

ក្រោយពីបានចុះស្រាវជ្រាវរដ្ឋបាលនៅសង្កាត់ក្បាលកោះ(២០១៨-២០២០)រួចមក បានបង្ហាញឱ្យឃើញថាការគ្រប់រដ្ឋបាលសង្កាត់គឺ ពិតជាចាំបាច់ណាស់សម្រាប់ការជួយសម្រួលការងារជូនប្រជាពលរដ្ឋក្នុងការធ្វើលិខិតស្នាម និងឯកសារផ្សេងៗដែលត្រូវការឱ្យមានលទ្ធភាព និងសម្ភារៈប្រើប្រាស់គ្រប់គ្រាន់ សម្រាប់ការអនុវត្តតួនាទីរបស់ខ្លួន និងសម្រេចជាលទ្ធផលល្អប្រសើរសម្រាប់សង្គមជាតិ។ យោងតាមការសិក្សានេះ យើងខ្ញុំសូមលើកឡើងនូវអនុសាសន៍មួយចំនួនក្នុងការជួយពង្រឹងនូវគោលការណ៍អភិបាលកិច្ចល្អក្នុងមូលដ្ឋាន ដូចជាៈ

១. ពង្រឹងនូវធនធានមនុស្ស និងសមត្ថភាពមន្ត្រីជំនាញនៅក្នុងមូលដ្ឋាន ឃុំ សង្កាត់។

២. គួរតែបន្តជម្រុញឱ្យប្រជាពលរដ្ឋក្នុងមូលដ្ឋានបានយល់ដឹងពីសិទ្ធិរបស់ខ្លួន។

៣. គៀងគរបង្កើនថវិកាបន្ថែម ដើម្បីធ្វើការអភិវឌ្ឍសង្កាត់មូលដ្ឋាន។

៤. បង្កើនការដោះស្រាយរាល់បញ្ហាជូនប្រជាពលរដ្ឋនៅពេលមានវិវាទ។

៥.សង្កាត់គួរតែបង្កើនសមត្ថភាពក្នុងការពិនិត្យ តាមដាន និងវាយតម្លៃសកម្មភាពការងារគ្រប់គ្រង ដើម្បីធានាកិច្ចអភិវឌ្ឍឱ្យមានប្រសិទ្ធិភាព និងប្រកបដោយចីរភាព។

៦.យកចិត្តទុកដាក់ផ្សព្វផ្សាយនូវព័ត៌មានផ្សេងៗ និង ផ្តល់ឱកាសដល់ប្រជាពលរដ្ឋ ជាពិសេសជនដែលងាយរងគ្រោះ ដូចជា ជនក្រីក្រ ស្ត្រីមេម៉ាយ និងជនពិការជាដើម។

៧. ផ្តល់ឱកាសដល់ប្រជាពលរដ្ឋនិយាយពីបញ្ហា និងតម្រូវការរបស់ពួកគេ។

# ឯកសារយោង

## ក.លិខិតបទដ្ឋានគតិយុត្តិ

១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

២. ច្បាប់ស្តីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់ ឆ្នាំ២០០១

៣. ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់ ឆ្នាំ២០០១

៤. ច្បាប់ស្តីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០០៦

៥. អនុក្រឹត្យលេខ ១៤៣ អនក្រ.បក ស្តីពីការប្តូរឃុំនៃរាជធានីភ្នំពេញទៅជាសង្កាត់

៦. អនុក្រឹត្យលេខ ១៦ អនក្រ .បក ស្តីពីមូលនិធិឃុំ សង្កាត់ ឆ្នាំ២០០២

៧. អនុក្រឹត្យលេខ ២២ អនក្រ.បក ស្តីពីការធ្វើវិមជ្ឈការអំណាច តួនាទី ភារកិច្ចទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ ២០០១

៨. អនុក្រឹត្យលេខ ២៦ អនក្រ.បក ស្តីពីប្រព័ន្ធហិរញ្ញវត្ថុឃុំ សង្កាត់ ឆ្នាំ២០០២

៩. ប្រកាសលេខ១៣២៩ ប្រ.ក ស្តីពីតួនាទី ភារកិច្ច និងសិទ្ធិរបស់ស្មៀនឃុំ សង្កាត់ ឆ្នាំ២០០១

## ខ. ផ្នែកទ្រឹស្តី

១០. សម្តេច ជួន ណាត វចនានុក្រមខ្មែរ ភាគ១ និង ២ បោះពុម្ពលើកទី៥ ឆ្នាំ១៩៦៧

១១. លោក ឆែនដ្លើរ (Chandler) និងលោក ប្លាណូ(Plano) វចនានុក្រមរដ្ឋបាលសាធារណៈ ១៩៩៨

១២. លោក កៅមុយថង រដ្ឋបាលសាធារណៈទំនើប បណ្ណាគារអង្គរ ឆ្នាំ២០០៧ ទំព័រ៩

១៣. លោក ឯក ឆេងហួត នីតិមូលដ្ឋានស្វយ័ត ឆ្នាំ២០០៣ ទំព័រ៨

១៤. សៀវភៅប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា របស់ក្រសួងមហាផ្ទៃ ឆ្នាំ២០១៩

១៥. សៀវភៅគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការ របស់ក្រសួងមហាផ្ទៃ ឆ្នាំ២០១៧

១៦. សៀវភៅនីតិរដ្ឋបាលទូទៅ រៀបរៀងដោយបណ្ឌិត សាយ បូរី ឆ្នាំ២០១២

## គ. ឯកសារផ្សេងៗ

១៧. សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល ២០១៨ ដល់ ២០២០ របស់សង្កាត់ក្បាលកោះ

# បញ្ជីឧបសម្ព័ន្ធ

១.ព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១

២.អនុក្រឹត្យលេខ ១៤៣ អនក្រ.បក ស្តីពីការប្តូរឃុំនៃរាជធានីភ្នំពេញទៅជាសង្កាត់

៣.សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល ២០១៨ ដល់ ២០២០ របស់សង្កាត់ក្បាលកោះ

៤. ផែនទីសង្កាត់ក្បាលកោះ

នស / រកម / ០៣០១ / ០៥

# ព្រះរាជក្រម

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាតិ វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែ មីនា ឆ្នាំ ១៩៩៩ដែលប្រកាសឱ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤នៃរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែង តាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម /០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំ ពីសម្តេចនាយករដ្ឋមន្ត្រី និង ពីសហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ។

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៥ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទំរង់ និង គតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី០១ខែ កុម្ភៈ ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើក ទី៤ នីតិកាលទី ១ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញ ប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមសេចក្តីសម្រេចលេខ ០៤១/ ០០៣ / ២០០១ កបធ.ច ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ : ៕

# ច្បាប់

# ស្តីពី

# ការគ្រប់គ្រងរដ្ឋបាល

# ឃុំ សង្កាត់

# ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលដៅកំណត់ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជាតាមនយោបាយវិមជ្ឈការ ។

**មាត្រា ២.-**

ឃុំ សង្កាត់ជានីតិបុគ្គល ។

**មាត្រា ៣.-**

ប្រព័ន្ធនៃអភិបាលកិច្ចមូលដ្ឋានត្រូវអនុវត្តនៅថ្នាក់ឃុំ សង្កាត់ ។

**មាត្រា ៤.-**

អំណាចដឹកនាំនិងគ្រប់គ្រងឃុំ សង្កាត់បានមកដោយការបោះឆ្នោតជាទូទៅ ជាសកល ដោយសេរី ត្រឹមត្រូវនិងយុត្តិធម៌ ដោយស្មើភាព ដោយចំពោះ ដោយសម្ងាត់ ក្នុងក្របខ័ណ្ឌនៃឃុំ សង្កាត់នីមួយៗ ។

**មាត្រា ៥.-**

ឃុំ សង្កាត់គ្រប់គ្រងកិច្ចការមូលដ្ឋានក្នុងដែនដីរបស់ខ្លួនដោយផ្អែកទៅតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសនិងលិខិតបទដ្ឋានពាក់ព័ន្ធ ។

អំណាចបញ្ញត្តិ អំណាចប្រតិបត្តិក្នុងការគ្រប់គ្រងមូលដ្ឋានត្រូវផ្តល់ឱ្យឃុំ សង្កាត់ ហើយអំណាចនេះត្រូវអនុវត្តស្របទៅតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធ ។

**មាត្រា ៦.-**

ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់និងការប្តូរឈ្មោះរបស់ឃុំ សង្កាត់ ក្នុងករណីមិនប៉ះពាល់ដល់ព្រំប្រទល់របស់ខេត្ត ក្រុងពាក់ព័ន្ធ ត្រូវសំរេចដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ក្នុងករណីដែលមានការប៉ះពាល់ដល់ព្រំប្រទល់របស់ខេត្ត ក្រុងពាក់ព័ន្ធ ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់និងការប្តូរឈ្មោះរបស់ឃុំ សង្កាត់ ត្រូវ៤៩.

សំរេចដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី ផ្អែកលើសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៧.-**

កាលបើមានផលវិបាកណាមួយកើតឡើង ក្រោយពេលដែលឃុំ សង្កាត់ ត្រូវបានបង្កើត លុបចោលឬកែសម្រួល រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញប្រកាសដើម្បីដោះស្រាយផលវិបាកនោះស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន ។

**មាត្រា ៨.-**

ឃុំ សង្កាត់ណាដែលមិនអាចដំណើរការរៀបចំបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់បានដោយករណីប្រធានសក្តិ រាជរដ្ឋាភិបាលត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភា។

បន្ទាប់ពីបានរាយការណ៍ជូនរដ្ឋសភារួចហើយ រាជរដ្ឋាភិបាលត្រូវចាត់ឱ្យក្រសួងមហាផ្ទៃរៀបចំគ្រប់គ្រងឃុំ សង្កាត់ទាំងនោះជាបណ្តោះអាសន្ន ហើយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ទាំងនោះនឹងត្រូវដំណើរការ នៅពេលស្ថានការណ៍ឃុំ សង្កាត់ទាំងនេះមានប្រក្រតីភាពឡើងវិញ ។

## ជំពូកទី ២
## ក្រុមប្រឹក្សាឃុំ សង្កាត់

**មាត្រា ៩.-**

ឃុំ សង្កាត់នីមួយៗត្រូវមានក្រុមប្រឹក្សាមួយហៅថាក្រុមប្រឹក្សាឃុំ សង្កាត់ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ជាអង្គការតំណាងប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួន និងមានបេសកកម្មបំរើផលប្រយោជន៍ទូទៅក្នុងឃុំ សង្កាត់របស់ខ្លួន ។

**មាត្រា ១០.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជ្រើសរើសឡើងតាមការបោះឆ្នោត ដោយប្រជាពលរដ្ឋនៃឃុំ សង្កាត់របស់ខ្លួនស្របទៅតាមនីតិវិធីដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។ល៕

**មាត្រា ១១.-**

ក្រុមប្រឹក្សាឃុំ សង្កាត់មានអាណត្តិ ៥ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលមានក្រុមប្រឹក្សាឃុំ សង្កាត់ថ្មីចូលកាន់តំណែង ។

ក្នុងតំណាក់កាលអន្តរកាលនេះ ក្រុមប្រឹក្សាឃុំ សង្កាត់ដែលផុតអាណត្តិមានភារកិច្ចសំរួលកិច្ចការប្រចាំថ្ងៃតែប៉ុណ្ណោះ ។

**មាត្រា ១២.-**

ក្រុមប្រឹក្សាឃុំ សង្កាត់មានសមាជិកចំនួនពី ៥ ទៅ ១១រូប ផ្អែកតាមប្រជាសាស្ត្រនិងភូមិសាស្ត្ររបស់ខ្លួន ។

ចំនួនជាក់ស្តែងនៃសមាជិកក្រុមប្រឹក្សាតាមឃុំ សង្កាត់នីមួយៗត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានកំណត់រួចហើយ អាចធ្វើការផ្លាស់ប្តូរបានដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាស្រ័យដោយការផ្លាស់ប្តូរនៃប្រជាសាស្ត្រនិងភូមិសាស្ត្រ ។

សមាជិកបន្ថែមនៃក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជ្រើសរើសតាមនីតិវិធីដូចសមាជិកដទៃទៀតដែរ ។

**មាត្រា ១៣.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវមានប្រធានម្នាក់ហៅថាប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ។

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់មានភារកិច្ច :

- ធ្វើជាអធិបតីក្នុងសម័យប្រជុំនានារបស់ក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន
- ធានាឱ្យមានកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ យ៉ាងតិចឱ្យបានមួយដងក្នុងមួយខែ
- ធានាឱ្យសម័យប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនដំណើរការបានត្រឹមត្រូវទៅតាមវិធាននិងបទបញ្ជាដូចបានចែងក្នុងបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាឃុំ សង្កាត់និងបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា២៣ នៃច្បាប់នេះ
- រក្សារបៀបរៀបរយនិងសណ្តាប់ធ្នាប់ក្នុងពេលប្រជុំ ។ល។

### មាត្រា ១៤.-

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានសិទ្ធិនិងមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបំពេញល័ក្ខខ័ណ្ឌសំខាន់ៗដូចខាងក្រោម :

- មានសញ្ជាតិខ្មែរពីកំណើត
-ចេះអាននិងសរសេរអក្សរខ្មែរ
- បានចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតក្នុងឃុំ សង្កាត់ដែលខ្លួនមានបំណងឈរឈ្មោះ
- មានអាយុយ៉ាងតិច ២៥ឆ្នាំ គិតមកទល់ថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- មានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមល័ក្ខខ័ណ្ឌដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

### មាត្រា ១៥.-

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានបោះឆ្នោតជ្រើសរើសឡើងទៅតាមប្រព័ន្ធសមាមាត្រ ។

### មាត្រា ១៦.-

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបាត់បង់សមាជិកភាពរបស់ខ្លួនទៅតាមករណីណាមួយក្នុងចំណោមករណីដូចខាងក្រោម :

- សាមីខ្លួនទទួលមរណភាព
- សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ពីក្រសួងស្ថាប័នមានសមត្ថកិច្ច
- សាមីខ្លួនសុំលាលែងជាលាយលក្ខណ៍អក្សរពីសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់
- សាមីខ្លួនត្រូវតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬមជ្ឈិមណាមួយ
- សមាជិកត្រូវបានបណ្តេញចេញដោយប្រព្រឹត្តផ្ទុយនឹងបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាឃុំ សង្កាត់ តាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ៨៤នៃច្បាប់នេះ ៕

- ក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូលត្រូវរំសាយ

- សាមីខ្លួនបាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន ។

កាលបើសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាមួយត្រូវបាត់បង់សមាជិកភាព ត្រូវជ្រើសរើសបេក្ខជនដែលមានឈ្មោះបន្ទាប់តាមលេខរៀងក្នុងបញ្ជីបេក្ខជនជាមួយមកជំនួសដោយមិនបាច់បោះឆ្នោតឡើងវិញឡើយ ។

**មាត្រា ១៧.-**

ត្រូវរៀបចំធ្វើការបោះឆ្នោតឡើងវិញក្នុងរយៈពេល ១២០ថ្ងៃយ៉ាងយូរ ដើម្បីធ្វើការជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងករណីណាមួយដូចខាងក្រោម :

- ឃុំ សង្កាត់ដែលបង្កើតថ្មីតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងមាត្រា ៦ នៃច្បាប់នេះ

- ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរំសាយចោលតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងមាត្រា ៥៧ និងមាត្រា ៥៨ នៃច្បាប់នេះ ។

ការបោះឆ្នោតឡើងវិញដូចមានចែងខាងលើនេះត្រូវបាត់ចែងធ្វើឡើង អនុលោមទៅតាមបែបបទនិងនីតិវិធីដែលបានចែងក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ដែលកើតឡើងដោយការបោះឆ្នោតឡើងវិញខាងលើនេះ មានអាណត្តិស្មើនឹងអាណត្តិដែលនៅសល់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

ការបោះឆ្នោតឡើងវិញមិនត្រូវអនុញ្ញាតឱ្យធ្វើឡើយ ប្រសិនបើអាណត្តិដែលនៅសល់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ មានរយៈពេលមិនលើសពី ១៨០ថ្ងៃ ។

ក្នុងរយៈពេលនេះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវតែងតាំងសមាសភាពនិងកំណត់អំពីសមត្ថកិច្ច របៀបរបបដឹកនាំគ្រប់គ្រងឃុំ សង្កាត់នោះ រហូតដល់មានការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិបន្ទាប់ ។

**មាត្រា ១៨.-**

ការកែប្រែព្រំប្រទល់របស់ឃុំ សង្កាត់ណាមួយអាចប្រព្រឹត្តបានតែក្នុងករណីដែលការកែប្រែនោះ ពុំបណ្តាលឱ្យផ្លាស់ប្តូរដល់ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានជាប់ឆ្នោត ។៚

ការបង្កើតឃុំ សង្កាត់ថ្មីណាមួយអាចប្រព្រឹត្តបានតែក្នុងករណីដែលការបង្កើតនោះពុំបណ្តាលឱ្យមានផ្លាស់ប្តូរដល់ចំនួនសមាជិកក្រុមប្រឹក្សានៃឃុំ សង្កាត់ដែលពាក់ព័ន្ធ ។

ក្នុងករណីឃុំ សង្កាត់ដែលត្រូវបង្កើតថ្មី ដែលត្រូវលុបចោល ដែលត្រូវកែប្រែព្រំប្រទល់ ហើយបណ្តាលឱ្យមានការផ្លាស់ប្តូរដល់ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានជាប់ឆ្នោត ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់ ត្រូវចូលជាធរមានសំរាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ នាអាណត្តិបន្ទាប់ ។

មាត្រា ១៩.-

ក្នុងអំឡុងពេល ១៥ថ្ងៃ ក្រោយពីការប្រកាសលទ្ធផលជាផ្លូវការនៃការបោះឆ្នោត ត្រូវចាត់ឱ្យមានការប្រជុំជាលើកដំបូងនៃក្រុមប្រឹក្សាឃុំ សង្កាត់ ក្រោមអធិបតីភាពមន្ត្រីម្នាក់ដែលចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីប្រកាសសុពលភាពសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់និងប្រកាសឈ្មោះប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ ជំទប់និងចៅសង្កាត់រង ។

មាត្រា ២០.-

មុនចាប់ផ្តើមការងារ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវរៀបចំនិងអនុម័តបទបញ្ជាផ្ទៃក្នុងដើម្បីកំណត់នូវវិធានទាំងឡាយសំរាប់អង្គប្រជុំនិងរបៀបរបបធ្វើការងាររបស់ខ្លួន ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញសេចក្តីណែនាំអំពីគោលការណ៍នានាសំរាប់ជាមូលដ្ឋានដល់ការរៀបចំបទបញ្ជាផ្ទៃក្នុងខាងលើនេះ ។

មាត្រា ២១.-

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការប្រជុំយ៉ាងតិចណាស់ចំនួនមួយដងក្នុងមួយខែ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវប្រជុំក្នុងសាលាឃុំ ឬសាលាសង្កាត់របស់ខ្លួន ឬក្នុងករណីចាំបាច់អធិបតីនៃអង្គប្រជុំអាចជ្រើសយកទីកន្លែងណាមួយក្នុងឃុំ សង្កាត់របស់ខ្លួនដើម្បីប្រជុំ ។ល។

**មាត្រា ២២.-**

ការប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ នឹងយកជាការបាន លុះត្រាតែមានចំនួនលើស ពីពាក់កណ្ដាលនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូលចូលរួម ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការបោះឆ្នោតអនុម័តដោយសម្លេងភាគច្រើនដាច់ខាតនៃសមាជិកក្រុមប្រឹក្សាទាំងមូល ដើម្បីសំរេចបញ្ហាណាមួយដូចខាងក្រោម :

- អនុម័តលើគំរោងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់
- អនុម័តលើគំរោងថវិកាឃុំ សង្កាត់
- កំណត់តម្លៃសារពើពន្ធមូលដ្ឋាន មិនមែនសារពើពន្ធមូលដ្ឋាននិងកំរៃសេវាផ្សេងៗ
- អនុម័តបទបញ្ញាផ្ទៃក្នុងនិងដីកាឃុំ សង្កាត់
- កិច្ចការផ្សេងៗទៀតដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ក្នុងពេលអនុម័ត ប្រសិនបើមានសំឡេងឆ្នោតស្មើគ្នា សម្លេងរបស់អធិបតីនៃអង្គប្រជុំមានឧត្តមានុភាព ។

**មាត្រា ២៣.-**

ការប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវធ្វើជាសាធារណៈនិងមានលក្ខណៈប្រជាធិបតេយ្យ ។

ក្រុមប្រឹក្សាឃុំ សង្កាត់អាចប្រជុំជាសម្ងាត់បាន ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញសេចក្ដីណែនាំអំពីរបៀបរបបប្រជុំខាងលើនេះ ។

**មាត្រា ២៤.-**

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មានសេរីភាពក្នុងការបញ្ចេញមតិក្នុងអង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ។

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់រូបណាក៏ដោយ មិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួនដោយហេតុពីបានសំដែងយោបល់ ឬបញ្ចេញមតិក្នុងអង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់បានឡើយ ។៚

# ជំពូកទី ៣
## រចនាសម្ព័ន្ធរដ្ឋបាលឃុំ សង្កាត់

**មាត្រា ២៥.-**

រដ្ឋបាលឃុំ សង្កាត់ត្រូវដឹកនាំគ្រប់គ្រងដោយក្រុមប្រឹក្សាឃុំ សង្កាត់ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវមានប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ។

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ជាមេឃុំ ចៅសង្កាត់ ។

**មាត្រា ២៦.-**

មេឃុំ ចៅសង្កាត់មានអ្នកជំនួយការដូចខាងក្រោម :

ចំពោះមេឃុំ អ្នកជំនួយការមានពីររូប :

-ជំទប់ទី ១ មួយរូប

-ជំទប់ទី ២ មួយរូប ។

ចំពោះចៅសង្កាត់ អ្នកជំនួយការមានពីររូប :

-ចៅសង្កាត់រងទី ១ មួយរូប

-ចៅសង្កាត់រងទី ២ មួយរូប ។

**មាត្រា ២៧.-**

មេឃុំ ចៅសង្កាត់មានសិទ្ធិចាត់តាំងគណៈកម្មាធិការនានាដើម្បីផ្តល់យោបល់ និងជួយកិច្ចការនានាតាមការចាំបាច់ ។

គណៈកម្មាធិការខាងលើនេះអាចយកសមាជិកណាម្នាក់ក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ឱ្យធ្វើជាប្រធានក៏បាន ឬអាចយកប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតណាម្នាក់ក្នុងឃុំ សង្កាត់របស់ខ្លួន ក្រៅពីសមាជិកក្រុមប្រឹក្សាឱ្យធ្វើជាប្រធានក៏បាន ។

**មាត្រា ២៨.-**

ឃុំ សង្កាត់ត្រូវមានបុគ្គលិកក្របខ័ណ្ឌរដ្ឋបាលនៃក្រសួងមហាផ្ទៃមួយរូបធ្វើជាស្មៀនឃុំ សង្កាត់ ។

ស្មៀនឃុំ សង្កាត់តែងតាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃដែលមានភារកិច្ចជួយកិច្ចការឃុំ សង្កាត់ និងធានានិរន្តរភាពកិច្ចការរដ្ឋបាលក្នុងឃុំ សង្កាត់ ។ល។

ស្មៀនឃុំ សង្កាត់ត្រូវផ្លាស់ប្តូរក្នុងករណីមានសំណើរបស់មេឃុំ ចៅសង្កាត់ អនុលោមតាមការសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ២៩.-**

ឃុំ សង្កាត់អាចជ្រើសរើសបុគ្គលិកក្រៅក្របខ័ណ្ឌរដ្ឋដើម្បីជួយកិច្ចការរបស់ខ្លួន តាមសេចក្តីត្រូវការនិងការចាំបាច់នៃការងារនិងតាមសេចក្តីសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងអាណត្តិ ហើយអាចបន្តការងារតាមការសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិបន្ទាប់ ។

**មាត្រា ៣០.-**

ក្នុងគោលដៅលើកកំពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវរៀបចំជ្រើសរើសឱ្យមានមេភូមិម្នាក់ សំរាប់ភូមិនីមួយៗ ចំណុះឃុំ សង្កាត់របស់ខ្លួន ។

មេភូមិត្រូវរៀបចំចាត់តាំងឱ្យមានអនុប្រធានមួយរូបនិងសមាជិកមួយរូបជាជំនួយការ ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញសេចក្តីណែនាំអំពីបែបបទនីតិវិធីនៃការជ្រើសរើសមេភូមិ ការចូលកាន់តំណែង ការផ្លាស់ប្តូរមេភូមិនិងការតែងតាំងជំនួយការមេភូមិ ។

**មាត្រា ៣១.-**

មេភូមិមានភារកិច្ច :

- អនុវត្តនូវភារកិច្ចដែលក្រុមប្រឹក្សាឃុំ សង្កាត់ ឬមេឃុំ ចៅសង្កាត់ប្រគល់ឱ្យដើម្បីធានាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមក្នុងភូមិ
- ផ្តល់យោបល់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់អំពីបញ្ហានានាដែលទាក់ទងដល់ផលប្រយោជន៍ក្នុងភូមិរបស់ខ្លួន
- ស្នើសុំយោបល់ទៅក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ដើម្បីចាត់ចែងនិងសម្របសម្រួលកិច្ចការនៅក្នុងភូមិរបស់ខ្លួន ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញសេចក្តីណែនាំបន្ថែមអំពីរបៀបរបបធ្វើការងារនិងភារកិច្ចរបស់ភូមិឱ្យបានសមស្រប ។ល។

**មាត្រា ៣២.–**

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ត្រូវជ្រើសរើសចេញពីបេក្ខជនលេខរៀងលើគេបង្អស់នៃបញ្ជីបេក្ខជនដែលបានទទួលសម្លេងឆ្នោតច្រើនជាងគេបង្អស់ ។

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់មានអាណត្តិស្មើនឹងអាណត្តិរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ៣៣.–**

ជំទប់ទី ១ ចៅសង្កាត់រងទី ១ ត្រូវជ្រើសរើសចេញពីបេក្ខជនដែលមានឈ្មោះលេខរៀងលើគេនៃបញ្ជីបេក្ខជនដែលបានទទួលសម្លេងឆ្នោតលំដាប់ទី ២ ។

ជំទប់ទី ២ ចៅសង្កាត់រងទី ២ ត្រូវជ្រើសរើសចេញពីបេក្ខជនដែលមានឈ្មោះលេខរៀងលើគេនៃបញ្ជីបេក្ខជនដែលបានទទួលសម្លេងឆ្នោតលំដាប់ទី ៣ ។

**មាត្រា ៣៤.–**

ក្នុងករណីដែលលទ្ធផលជាផ្លូវការនៃការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាបានផ្តល់សម្លេងគាំទ្រដល់បញ្ជីបេក្ខជនតែមួយដែលមានលក្ខណៈសម្បត្តិទទួលបានអាសនៈទាំងអស់ក្នុងក្រុមប្រឹក្សា ត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាពីក្នុងបញ្ជីតែមួយនោះឱ្យទទួលតំណែងជាមេឃុំ ឬចៅសង្កាត់ ជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ។

**មាត្រា ៣៥.–**

ក្នុងករណីដែលលទ្ធផលជាផ្លូវការនៃការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាបានផ្តល់សម្លេងគាំទ្រដល់បញ្ជីបេក្ខជនតែពីរដែលមានលក្ខណៈសម្បត្តិទទួលបានអាសនៈក្នុងក្រុមប្រឹក្សា ត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាជាបេក្ខជន ដែលមានឈ្មោះលេខរៀងបន្ទាប់ពីបេក្ខជនដែលមានឈ្មោះលេខរៀងលំដាប់លើគេបង្អស់នៃបញ្ជីដែលបានទទួលសម្លេងឆ្នោតគាំទ្រលំដាប់ទីមួយ ឱ្យទទួលតំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ និងជ្រើសរើសយកសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាបេក្ខជនដែលមានឈ្មោះលេខរៀងលើគេបង្អស់ នៃបញ្ជីដែលបានទទួលសម្លេងគាំទ្រលំដាប់ទី ២ ឱ្យទទួលតំណែងជាជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ។ល។

**មាត្រា ៣៦.-**

តំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ត្រូវបាត់បង់ក្នុងករណីសាមីខ្លួនបាត់បង់សមាជិកភាពក្រុមប្រឹក្សាឃុំ សង្កាត់តាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ មាត្រា ១៦នៃច្បាប់នេះ ។

**មាត្រា ៣៧.-**

មុខតំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ មុខតំណែងមេឃុំ ចៅសង្កាត់និងមុខតំណែងជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ កាលបើមុខតំណែងណាមួយត្រូវបាត់បង់ មុខតំណែងទាំងអស់ខាងលើរបស់ជននោះក៏ត្រូវបានបាត់បង់ព្រមពេលជាមួយគ្នាដែរ ។

ក្នុងករណីខាងលើនេះ ត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលមានឈ្មោះតាមលេខរៀងបន្ទាប់នៅក្នុងបញ្ជីរួមជាមួយអតីតប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ ដែលបានបាត់បង់ពីមុខតំណែងនោះ ឱ្យទទួលបន្តតំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់និងត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាថ្មី ជំនួសកន្លែងដែលទំនេរតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ១៦នៃច្បាប់នេះ ។

ក្នុងករណីដែលបញ្ជីបេក្ខជនត្រូវកាន់កាប់តំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់អស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ចេញពីក្នុងបញ្ជីបេក្ខជនជាមួយ ផ្អែកតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ១៦ នៃច្បាប់នេះនិងបាត់ឱ្យសមាជិកក្រុមប្រឹក្សារូបនេះទទួលបន្តតំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ជំនួសប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ដែលបានបាត់បង់ពីមុខតំណែង ។

ផ្អែកតាមល័ក្ខខ័ណ្ឌខាងលើនេះ ការបាត់បង់ពីមុខតំណែងនិងការទទួលតំណែងប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាមេឃុំ ចៅសង្កាត់ត្រូវធ្វើដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃក្នុងរយៈពេលយ៉ាងយូរ ១៤ថ្ងៃ ។

**មាត្រា ៣៨.-**

តំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ តំណែងជាជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ត្រូវបាត់បង់ពីមុខតំណែង ក្នុងករណីដែលសាមីខ្លួនបាត់បង់សមាជិកភាពក្រុមប្រឹក្សា ឃុំ សង្កាត់តាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ មាត្រា ១៦នៃច្បាប់នេះ ។ល។

ក្នុងករណីតំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ តំណែងជាជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ត្រូវបានបាត់បង់ មុនតំណែងជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់របស់ជននោះក៏ត្រូវបានបាត់បង់ព្រមពេលជាមួយគ្នាដែរ ។

ក្នុងករណីខាងលើនេះ ត្រូវជ្រើសរើសយកសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាបេក្ខជនដែលមានឈ្មោះតាមលេខរៀងបន្ទាប់នៃបញ្ជីបេក្ខជនរួមជាមួយជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ឱ្យទទួលតំណែងជំនួសជំទប់ ឬចៅសង្កាត់រងដែលបានបាត់បង់ពីមុខតំណែងនិងត្រូវជ្រើសរើសសមាជិកក្រុមប្រឹក្សាថ្មីជំនួសកន្លែងដែលទំនេរ តាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ១៦នៃច្បាប់នេះ ។

ក្នុងករណីបញ្ជីបេក្ខជនដែលត្រូវកាន់កាប់តំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ អស់សមាជិកក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជ្រើសរើសបេក្ខជនពីក្នុងបញ្ជីនោះបញ្ចូលជាសមាជិកក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ ទៅតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ១៦នៃច្បាប់នេះ និងប្រគល់ឱ្យសមាជិកក្រុមប្រឹក្សារូបនោះទទួលតំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ជំនួសតំណែងជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ដែលបានបាត់បង់ពីមុខតំណែង ។

ផ្អែកតាមល័ក្ខខ័ណ្ឌខាងលើនេះនិងល័ក្ខខ័ណ្ឌដែលបានចែងក្នុងមាត្រា ៣៣ នៃច្បាប់នេះ ការបាត់បង់មុខតំណែងនិងការទទួលតំណែងជាជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ត្រូវធ្វើដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃក្នុងរយៈពេលយ៉ាងយូរ ១៤ថ្ងៃ ។

**មាត្រា ៣៩.–**

មេឃុំ ចៅសង្កាត់បំពេញតួនាទីភារកិច្ចដូចខាងក្រោម :

- អនុវត្តសេចក្តីសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- អនុវត្តនូវបទប្បញ្ញត្តិនិងគោលការណ៍នានាដែលបានទទួលពីក្រុមប្រឹក្សាឃុំ សង្កាត់
- ធ្វើសេចក្តីរាយការណ៍អំពីសកម្មភាពការងារជូនក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនយ៉ាងតិចឱ្យបានមួយដងក្នុងមួយខែ
- ផ្តល់យោបល់ផ្សេងៗនិងជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការរៀបចំផែនការហិរញ្ញវត្ថុនិងក្នុងការចាត់ចែងអនុវត្តនូវតួនាទី មុខងារ សិទ្ធិអំណាចរបស់ក្រុម

ឃុំ.

ប្រឹក្សាឃុំ សង្កាត់ ព្រមទាំងកិច្ចការផ្សេងទៀតដែលក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនប្រគល់ឱ្យ ។

**មាត្រា ៤០.-**

ជំទប់ ឬចៅសង្កាត់រងជាជំនួយការរបស់មេឃុំ ចៅសង្កាត់ក្នុងការអនុវត្តភារកិច្ចដែលមេឃុំ ចៅសង្កាត់ប្រគល់ឱ្យនិងជំនួសមេឃុំ ចៅសង្កាត់ទៅតាមឋានានុក្រមនៃជំទប់ ចៅសង្កាត់រង នៅពេលដែលមេឃុំ ចៅសង្កាត់អវត្តមាន ។

ជំទប់ ឬចៅសង្កាត់រង ត្រូវធ្វើការបែងចែកភារកិច្ចដូចខាងក្រោម :

ជំទប់ទី ១ ឬចៅសង្កាត់រងទី ១ ទទួលជួយមេឃុំ ចៅសង្កាត់លើកិច្ចការសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

ជំទប់ទី ២ ឬចៅសង្កាត់រងទី ២ ទទួលជួយមេឃុំ ចៅសង្កាត់លើកិច្ចការរដ្ឋបាល សង្គមកិច្ច សេវាសាធារណៈនិងសណ្ដាប់ធ្នាប់សាធារណៈ ។

មេឃុំ ចៅសង្កាត់អាចប្រគល់ភារកិច្ចបន្ថែមពីលើភារកិច្ចដែលបានបែងចែកខាងលើនេះដល់ជំទប់ ឬចៅសង្កាត់រងរបស់ខ្លួន ។

## ជំពូកទី ៥

## តួនាទី មុខងារនិងអំណាចនៃរដ្ឋបាលឃុំ សង្កាត់

**មាត្រា ៤១.-**

រដ្ឋបាលឃុំ សង្កាត់មានតួនាទីជំរុញនិងគាំពារអភិបាលកិច្ចល្អ ដោយចាត់ចែងប្រើប្រាស់ធនធាននានាដែលមានប្រកបដោយចីរភាព សំរាប់បំពេញសេចក្ដីត្រូវការជាមូលដ្ឋានក្នុងឃុំ សង្កាត់របស់ខ្លួន បំរើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋនិងគោរពផលប្រយោជន៍របស់ជាតិស្របតាមនយោបាយទូទៅរបស់រដ្ឋ ។

**មាត្រា ៤២.-**

រដ្ឋបាលឃុំ សង្កាត់មានតួនាទីពីរប្រភេទគឺ :

- តួនាទីបំរើកិច្ចការមូលដ្ឋានសំរាប់បំរើផលប្រយោជន៍ឃុំ សង្កាត់និងប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួន ។
- តួនាទីជាភ្នាក់ងារតំណាងរដ្ឋ ក្រោមការចាត់តាំង ឬការប្រគល់អំណាចរបស់អាជ្ញាធររដ្ឋ ។ល។

**មាត្រា ៤៣.-**

ក្នុងតួនាទីបំពេញកិច្ចការមូលដ្ឋាន រដ្ឋបាលឃុំ សង្កាត់មានភារកិច្ច :

- ធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ

- រៀបចំចាត់ចែងសេវាសាធារណៈចាំបាច់និងមើលការខុសត្រូវឱ្យកិច្ចការទាំងនោះដំណើរការបានល្អ

- លើកទឹកចិត្តឱ្យមានការបង្កើនផាសុកភាពនិងសុខុមាលភាពរបស់ប្រជាពលរដ្ឋ

- ជំរុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចនិងលើកកំពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ

- ការពារ ថែរក្សាបរិស្ថាន ធនធានធម្មជាតិ វប្បធម៌ បេតិកភណ្ឌជាតិ

- សំរបសំរួលទស្សនៈរបស់ប្រជាពលរដ្ឋដើម្បីឱ្យមានការយោគយល់អធ្យាស្រ័យទៅវិញទៅមក

- បំពេញកិច្ចការជាទូទៅដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ។

**មាត្រា ៤៤.-**

ក្នុងតួនាទីជាភ្នាក់ងារតំណាងរដ្ឋ រដ្ឋបាលឃុំ សង្កាត់មានភារកិច្ចអនុវត្តទៅតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសនិងលិខិតបទដ្ឋានពាក់ព័ន្ធ ។

ក្នុងករណីនេះ អាជ្ញាធររដ្ឋអាចធ្វើប្រតិភូកម្មអំណាចដល់ឃុំ សង្កាត់ដោយភ្ជាប់ជាមួយនូវការបង្កើនសមត្ថភាពនិងផ្តត់ផ្គង់មធ្យោបាយ សម្ភារៈ ថវិកា សំរាប់អនុវត្ត ។

ប្រតិភូកម្មខាងលើនេះ ត្រូវផ្តល់ចំពោះតែសមូហភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់តែប៉ុណ្ណោះ ។

**មាត្រា ៤៥.-**

រដ្ឋបាលឃុំ សង្កាត់គ្មានអំណាចសំរេចលើវិស័យទាំងឡាយដូចខាងក្រោម :

- ព្រៃឈើ
- ប្រៃសណីយ៍និងទូរគមនាគមន៍
- ការពារប្រទេស ៘.

- សន្តិសុខជាតិ
- រូបិយវត្ថុ
- នយោបាយក្រៅប្រទេស
- គោលនយោបាយសារពើពន្ធ
- និងវិស័យផ្សេងទៀតដែលមានចែងក្នុងច្បាប់ លិខិតបទដ្ឋានពាក់ព័ន្ធ។

**មាត្រា ៤៦.-**

តួនាទី មុខងារនិងអំណាចរបស់ឃុំ សង្កាត់ ដូចមានចែងក្នុងមាត្រា ៤២, ៤៣ និងមាត្រា ៤៤នៃច្បាប់នេះ អនុវត្តបានតែក្នុងរង្វង់ដែនដីឃុំ សង្កាត់របស់ខ្លួនតែប៉ុណ្ណោះ ។

ក្នុងករណីមានបញ្ហាកើតឡើងទាក់ទងសមត្ថកិច្ចរវាងឃុំ សង្កាត់ពីរឬច្រើន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចាត់ការឱ្យមានការសិរុះសិរួលគ្នារវាងរដ្ឋបាលដែលពាក់ព័ន្ធទាំងនោះ ។

**មាត្រា ៤៧.-**

តួនាទី មុខងារនិងអំណាចរបស់រដ្ឋបាលឃុំ សង្កាត់ដូចមានចែងក្នុងមាត្រា ៤២, ៤៣, ៤៤ និងមាត្រា ៤៥នៃច្បាប់នេះ អាចកំណត់លំអិតជាក់ស្តែងបន្ថែមទៀតដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៤៨.-**

ឃុំ សង្កាត់មានអំណាចបញ្ញត្តិនិងអំណាចប្រតិបត្តិ ។

អំណាចបញ្ញត្តិរបស់ឃុំ សង្កាត់ត្រូវធ្វើឡើងតាមរយៈដីកាឃុំ សង្កាត់សំរាប់គ្រប់គ្រងកិច្ចការនានាក្នុងក្របខ័ណ្ឌ តួនាទី មុខងារនិងអំណាចរបស់ខ្លួន ។

ដីកាឃុំ សង្កាត់ត្រូវធ្វើឡើងតាមការសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយត្រូវចុះហត្ថលេខាដោយមេឃុំ ចៅសង្កាត់ ។

រដ្ឋបាលឃុំ សង្កាត់ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈនិងជាបន្ទាន់ក្នុងឃុំ សង្កាត់របស់ខ្លួននូវដីកាដែលបានសំរេចរួចហើយ ។៚

**មាត្រា ៤៩.-**

ដីកាឃុំ សង្កាត់មានប្រសិទ្ធភាពអនុវត្តតែក្នុងរង្វង់ដែនដីរបស់ខ្លួនប៉ុណ្ណោះ ។

ដីកាឃុំ សង្កាត់មិនត្រូវផ្ទុយនឹងសន្ធិសញ្ញា អនុសញ្ញាអន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ ស្មារតីរដ្ឋធម្មនុញ្ញ ផ្ទុយនឹងច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធបានឡើយ ។

ដីកាដែលដាក់ចេញដោយរដ្ឋបាលឃុំ សង្កាត់ ហើយផ្ទុយនឹងសន្ធិសញ្ញា អនុសញ្ញាអន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ ស្មារតីរដ្ឋធម្មនុញ្ញ ផ្ទុយនឹងច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសនិងលិខិតបទដ្ឋានពាក់ព័ន្ធត្រូវចាត់ទុកជាមោឃៈដាច់ខាត ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវជូនដំណឹងអំពីមោឃភាពនេះជាលាយលក្ខណ៍អក្សរដល់ឃុំ សង្កាត់សាមីនិងត្រូវផ្សព្វផ្សាយជាសាធារណៈ ។

**មាត្រា ៥០.-**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវណែនាំអំពីទំរង់និងបែបបទ ដើម្បីឱ្យឃុំ សង្កាត់រៀបចំដីកាស្របទៅតាមសភាពការណ៍ក្នុងឃុំ សង្កាត់របស់ខ្លួន ។

**មាត្រា ៥១.-**

ក្រុមប្រឹក្សាឃុំ សង្កាត់អាចធ្វើប្រតិភូកម្មអំណាចឱ្យដល់មេឃុំ ចៅសង្កាត់តាមសេចក្ដីណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លើកលែងតែបញ្ហាទាំងឡាយដូចខាងក្រោម :

- ការអនុម័តលើគំរោងថវិកាឃុំ សង្កាត់
- ការកំណត់តម្លៃសារពើពន្ធមូលដ្ឋាន មិនមែនសារពើពន្ធមូលដ្ឋាន និងកំរៃសេវាផ្សេងៗ
- ការបោះឆ្នោតអនុម័តបទបញ្ជាផ្ទៃក្នុងនិងដីកាឃុំ សង្កាត់
- ការអនុម័តលើគំរោងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់
- បញ្ហាដទៃទៀតដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

មេឃុំ ចៅសង្កាត់ដែលត្រូវបានក្រុមប្រឹក្សាឃុំ សង្កាត់ធ្វើប្រតិភូកម្មអំណាចឱ្យ ពុំអាចផ្ទេរអំណាចនេះបន្តទៅឱ្យបុគ្គលដទៃទៀតបានឡើយ ។ ៷.

**មាត្រា ៥២.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានធ្វើប្រតិភូកម្មអំណាចឱ្យដល់មេឃុំ ចៅសង្កាត់ នៅតែទទួលខុសត្រូវលើកិច្ចការដែលបានធ្វើប្រតិភូកម្មនោះ ។

ការដកហូតនូវអំណាចដែលបានធ្វើប្រតិភូកម្ម មិនធ្វើឱ្យប៉ះពាល់ដល់សុពលភាពនៃកិច្ចការដែលបានធ្វើរួចហើយនោះឡើយ ។

## ជំពូកទី ៥
## ការតាមដាន ការត្រួតពិនិត្យនិងការធ្វើអន្តរាគមន៍

**មាត្រា ៥៣.-**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវកំណត់ពីនីតិវិធីផ្សេងៗសំរាប់ធ្វើការតាមដាននិងត្រួតពិនិត្យអំពីសកម្មភាពទូទៅរបស់ឃុំ សង្កាត់ដើម្បី :

- ពិនិត្យមើលអំពីនីត្យានុកូលភាពនៃការគ្រប់គ្រងការងារ ការប្រើប្រាស់អំណាចនិងការបំពេញតួនាទី ភារកិច្ច របស់ឃុំ សង្កាត់នីមួយៗ
- ពិនិត្យមើលការវិវត្តន៍អំពីសមត្ថភាពរបស់ឃុំ សង្កាត់នានា
- ប៉ាន់ប្រមាណអំពីការធ្វើអន្តរាគមន៍និងការជួយឧបត្ថម្ភគាំទ្រចំពោះឃុំ សង្កាត់ដើម្បីពង្រឹងសមត្ថភាពគ្រប់គ្រងការងារ ការប្រើប្រាស់អំណាចនិងការបំពេញតួនាទីភារកិច្ច ។

ក្នុងការតាមដាន ការត្រួតពិនិត្យនិងការធ្វើការអន្តរាគមន៍ចំពោះឃុំ សង្កាត់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាចវិលែកអំណាចដល់មន្ត្រីជាតំណាងរាជរដ្ឋាភិបាលតាមថ្នាក់រដ្ឋបាលដែនដីខេត្ត ក្រុង ស្រុក ខ័ណ្ឌ ឱ្យជួយកិច្ចការនេះទៅតាមសំណូមពរការងារ ។

**មាត្រា ៥៤.-**

ឃុំ សង្កាត់ណាដែលមិនបានបំពេញភារកិច្ចដែលច្បាប់បានតម្រូវ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវធ្វើអន្តរាគមន៍ដើម្បីឱ្យមានការបំពេញភារកិច្ចដែលច្បាប់បានតម្រូវនោះជាបន្ទាន់ ។ល។

ភារកិច្ចដែលច្បាប់បានតម្រូវ គឺជាភារកិច្ចមួយដែលក្រុមប្រឹក្សាឃុំ សង្កាត់ មានកាតព្វកិច្ចបំពេញតាមល័ក្ខខ័ណ្ឌទាំងឡាយនៃច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស លិខិតបទដ្ឋានពាក់ព័ន្ធ ឬបទបញ្ជាផ្ទៃក្នុងនិងដីកាឃុំ សង្កាត់ ។

**មាត្រា ៥៥.-**

ការតាមដាន ត្រួតពិនិត្យនិងធ្វើអន្តរាគមន៍រួមមានការងារ :

- ស៊ើបអង្កេតនិងវាយតំលៃ
- ធ្វើសេចក្តីណែនាំជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាឃុំ សង្កាត់ ឱ្យបំពេញភារកិច្ចដែលច្បាប់បានតម្រូវ
- ធ្វើជំនួសក្នុងការបន្តបំពេញភារកិច្ចដែលច្បាប់បានតម្រូវ ។

**មាត្រា ៥៦.-**

ការធ្វើអន្តរាគមន៍ដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ មាត្រា ៥៤ នៃច្បាប់នេះត្រូវមានលក្ខណៈសមហេតុផលនិងស្របទៅតាមទំហំនៃកិច្ចការដែលក្រុមប្រឹក្សាឃុំ សង្កាត់ មិនបានបំពេញភារកិច្ចដែលច្បាប់បានតម្រូវ ដោយភ្ជាប់ជាមួយនូវការណែនាំនិងការគាំទ្រសំខាន់ចាំបាច់ ដើម្បីឱ្យក្រុមប្រឹក្សាឃុំ សង្កាត់អាចបំពេញភារកិច្ចដែលច្បាប់បានតម្រូវជាធម្មតា ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានសិទ្ធិចុះកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរជាមួយបុគ្គល ឬអង្គការណាមួយ ឬធ្វើការណែនាំជាលាយលក្ខណ៍អក្សរដល់មន្ត្រីជាតំណាងរាជរដ្ឋាភិបាលតាមថ្នាក់រដ្ឋបាលដែនដីខេត្ត ក្រុង ស្រុក ខ័ណ្ឌឱ្យបំពេញការងារចាំបាច់ដើម្បីធ្វើអន្តរាគមន៍ក្នុងនាមខ្លួនចំពោះកិច្ចការណាមួយ ។

**មាត្រា ៥៧.-**

កាលបើការធ្វើអន្តរាគមន៍មិនទទួលបានលទ្ធផលចំពោះភារកិច្ចដែលច្បាប់បានតម្រូវណាមួយ ឬមួយចំនួនក្នុងអំឡុងពេល ៦ខែ ហើយភារកិច្ចដែលច្បាប់បានតម្រូវជាទូទៅក្រុមប្រឹក្សាឃុំ សង្កាត់ក៏មិនអាចបំពេញបាន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវសំរេចរំសាយក្រុមប្រឹក្សាឃុំ សង្កាត់ ហើយធ្វើការបោះឆ្នោតឡើងវិញទៅតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងច្បាប់នេះ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។ល។

**មាត្រា ៥៨.-**

ក្នុងករណីក្រុមប្រឹក្សាឃុំ សង្កាត់ណាធ្វើសកម្មភាពផ្ទុយនឹងរដ្ឋធម្មនុញ្ញ ផ្ទុយនឹងនយោបាយរដ្ឋាភិបាល រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវសំរេចរំសាយក្រុមប្រឹក្សាឃុំ សង្កាត់ នោះជាបន្ទាន់ ហើយត្រូវធ្វើការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នោះឡើងវិញ ទៅតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងច្បាប់នេះនិងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ៥៩.-**

ត្រូវបង្កើតឱ្យមានអង្គភាពមួយចំណុះក្រសួងមហាផ្ទៃដើម្បីធ្វើជាសេនាធិការអំពីការងាររដ្ឋបាលមូលដ្ឋាន ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពនេះត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## ជំពូកទី ៦
## ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

**មាត្រា ៦០.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរៀបចំ អនុម័តនិងអនុវត្តនូវផែនការអភិវឌ្ឍន៍ឃុំសង្កាត់ក្នុងគោលបំណងកំណត់នូវទស្សនវិស័យ កម្មវិធីនិងកិច្ចអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួន ។

**មាត្រា ៦១.-**

ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ត្រូវឱ្យស្របទៅនឹងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ចរបស់ជាតិ ។

**មាត្រា ៦២.-**

ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ត្រូវអនុម័តយល់ព្រមដោយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងឆ្នាំទី ១ នៃអាណត្តិរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយត្រូវពិនិត្យឡើងវិញដើម្បីផ្តល់ទិន្នន័យថ្មីៗជារៀងរាល់ឆ្នាំ ដោយក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន ។ ល.រ.

**មាត្រា ៦៣.-**

ក្នុងការរៀបចំផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចាត់វិធានការដូចតទៅ :

- វាយតំលៃអំពីកំរិតអត្ថិភាពនៃការអភិវឌ្ឍន៍និងសកម្មភាពអភិវឌ្ឍន៍នៅក្នុងឃុំ សង្កាត់របស់ខ្លួន

- ប្រមូលផ្តុំសេចក្តីត្រូវការក្នុងឃុំ សង្កាត់និងកំណត់អាទិភាពចំពោះសេចក្តីត្រូវការទាំងនោះ ដោយផ្អែកទៅលើធនធានទាំងឡាយដែលឃុំ សង្កាត់មាននិងធនធានដែលបានទទួល

- រៀបចំកម្មវិធីដែលអាចឆ្លើយតបនឹងសេចក្តីត្រូវការនានា តាមរយៈការផ្តល់សេវានិងការអភិវឌ្ឍន៍ ហើយកម្មវិធីទាំងនេះត្រូវបញ្ចូលក្នុងថវិកាប្រចាំឆ្នាំរបស់ឃុំ សង្កាត់

- ផ្តល់សេវានិងការអភិវឌ្ឍន៍ អនុលោមទៅតាមថវិការបស់ខ្លួន

- ពិនិត្យ តាមដាននិងវាយតំលៃចំពោះលទ្ធផលនៃការអនុវត្តផែនការអភិវឌ្ឍន៍

- ប្រើប្រាស់លទ្ធផលផ្សេងៗ ដើម្បីវាយតំលៃអំពីកំរិតនៃការអភិវឌ្ឍន៍ថ្មីៗក្នុងឃុំ សង្កាត់របស់ខ្លួន

- ធ្វើសេចក្តីរាយការណ៍អំពីលទ្ធផលនៃការអនុវត្តផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ជូនប្រជាពលរដ្ឋរបស់ខ្លួន ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវដឹកនាំការងារឱ្យស្របទៅនឹងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួន ។

**មាត្រា ៦៤.-**

ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ត្រូវរៀបចំជាលាយលក្ខណ៍អក្សរដោយមានផែនទី ស្ថិតិនិងសំណុំឯកសារពាក់ព័ន្ធផ្សេងៗទៀតភ្ជាប់ជាមួយផង ។

ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ក៏ត្រូវកំណត់ផងដែរនូវវិធីសាស្ត្រនិងមធ្យោបាយនានាដើម្បីបង្កលទ្ធភាពឱ្យមានការចូលរួមពីប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួនក្នុងកិច្ចដំណើរការទាំងមូល ។ ល.ក.

**មាត្រា ៦៥.-**

ក្នុងករណីដែលផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ណាមួយធ្វើឡើងមិនស្របតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងច្បាប់នេះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវណែនាំឱ្យក្រុមប្រឹក្សាឃុំ សង្កាត់កែតម្រូវផែនការរបស់ខ្លួនឱ្យបានសមស្របក្នុងអំឡុងពេលយ៉ាងយូរ ៤៥ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលច្បាប់ចម្លងនៃផែនការនោះ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការកែសម្រួលផែនការអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួនឱ្យបានសមស្របតាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៦៦.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការតាមដាន ត្រួតពិនិត្យនិងវាយតំលៃរាល់ការអនុវត្តផែនការ កម្មវិធី គំរោងនិងការផ្តល់សេវានានាប្រកបដោយតម្លាភាពនិងមានការទទួលខុសត្រូវខ្ពស់ ។

**មាត្រា ៦៧.-**

ក្រុមប្រឹក្សាឃុំ សង្កាត់នៅតែជាអ្នកទទួលខុសត្រូវក្នុងការតាមដាន ការត្រួតពិនិត្យនិងការវាយតំលៃចំពោះផែនការ កម្មវិធីនិងគំរោងនានា ទោះជាការងារនោះត្រូវបានអនុវត្តដោយសមាសភាពណាក៏ដោយដែលខ្លួនបានជ្រើសយក ។

**មាត្រា ៦៨.-**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវណែនាំក្រុមប្រឹក្សាឃុំ សង្កាត់អំពីវិធីផ្សេងៗក្នុងការអនុវត្តផែនការនិងក្នុងការត្រួតពិនិត្យ វាយតំលៃចំពោះការប្រើប្រាស់មូលនិធិសំរាប់ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ។

**មាត្រា ៦៩.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើសេចក្តីរាយការណ៍ប្រចាំឆ្នាំអំពី :

- កិច្ចការជាអាទិភាព គោលដៅសំរាប់ផ្តល់សេវានិងគំរោងផែនការអភិវឌ្ឍន៍របស់ឃុំ សង្កាត់នាឆ្នាំសារពើពន្ធកន្លងមក
- លទ្ធផលនៃការអនុវត្តចំពោះកិច្ចការជាអាទិភាព គោលដៅសំរាប់ផ្តល់សេវានិងគំរោងផែនការអភិវឌ្ឍន៍ទាំងនោះរបស់ឃុំ សង្កាត់ ។ល។

- វិធានការធ្វើឱ្យ បានល្អប្រសើរចំពោះវិស័យនានាដែលមានការខ្វះចន្លោះក្នុងការអនុវត្តកន្លងមក

- កិច្ចការជាអាទិភាព គោលដៅសំរាប់ផ្តល់សេវានិងគំរោងផែនការអភិវឌ្ឍន៍របស់ឃុំ សង្កាត់ក្នុងឆ្នាំសារពើពន្ធបច្ចុប្បន្ន ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវអនុម័តសេចក្តីរាយការណ៍នេះក្នុងអំឡុងពេលយ៉ាងយូរ ៤៥ថ្ងៃ បន្ទាប់ពីបំណាច់ឆ្នាំសារពើពន្ធនីមួយៗ ។

**មាត្រា ៧០.-**

សេចក្តីរាយការណ៍ប្រចាំឆ្នាំដូចមានចែងក្នុងមាត្រា ៦៩នៃច្បាប់នេះ ក្រោយពីបានអនុម័តយល់ព្រមដោយក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវ :

- ចម្លងជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- តម្កល់ទុកជាសាធារណៈ
- ចម្លងចែកជូនអង្គការ សមាគមនិងសាធារណជនសំខាន់ៗដោយគិតត្រឹមថ្លៃដើម ។

**មាត្រា ៧១.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវពិនិត្យពិចារណាទៅលើមតិយោបល់ផ្សេងៗដែលបានផ្តល់ចំពោះសេចក្តីរាយការណ៍ដូចមានចែងក្នុងមាត្រា ៦៩ និងមាត្រា ៧០នៃច្បាប់នេះ ហើយត្រូវទទួលយកនូវមតិយោបល់ល្អៗ ដើម្បីដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ។

**មាត្រា ៧២.-**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវពិគ្រោះពិភាក្សាជាមួយក្រសួងស្ថាប័នពាក់ព័ន្ធដើម្បីចេញសេចក្តីណែនាំអនុវត្តជាក់ស្តែងនូវបទប្បញ្ញត្តិនានា ដែលបានចែងក្នុងជំពូកទី ៦ នៃច្បាប់នេះ ។

## ជំពូកទី ៧

## ហិរញ្ញវត្ថុឃុំ សង្កាត់

**មាត្រា ៧៣.-**

ឃុំ សង្កាត់មានធនធានហិរញ្ញវត្ថុ ថវិកានិងទ្រព្យសម្បត្តិផ្ទាល់ ។ ៸៸.

**មាត្រា ៧៤.-**

ឃុំ សង្កាត់មានសិទ្ធិទទួលចំណូលផ្ទាល់ដែលបានមកពីចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធនិងកំរៃសេវាផ្សេងៗ ។

ពន្ធខាងលើនេះរាប់បញ្ចូលនូវពន្ធលើដីធ្លី ពន្ធលើអចលនទ្រព្យនិងពន្ធនៃការជួល ។

ក្នុងករណីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុប្រមូលចំណូលផ្ទាល់របស់ឃុំ សង្កាត់ ការប្រមូលចំណូលនេះត្រូវធ្វើក្នុងនាមឃុំ សង្កាត់ ។

ប្រភេទ កំរិតនិងរបៀបរបបនៃការប្រមូលចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធនិងកំរៃសេវាផ្សេងៗ ខាងលើនេះត្រូវកំណត់ដោយច្បាប់ ។

**មាត្រា ៧៥.-**

ឃុំ សង្កាត់មានសិទ្ធិទទួលបាននូវធនធានវិភាជន៍ពីចំណូលរដ្ឋ សំរាប់ថវិការបស់ខ្លួន ។

ធនធានវិភាជន៍នេះរួមមាន:

- ការផ្ទេរទាំងមូលឬមួយផ្នែកនូវប្រាក់ចំណូលសារពើពន្ធនិងចំណូលមិនមែនសារពើពន្ធដីជាក់លាក់របស់រដ្ឋ
- ទាយជ្ជទាននិងធនធានវិភាជន៍ ឧបត្ថម្ភធន ឬអនុប្បទានដែលបានមកពីប្រាក់ចំណូលរដ្ឋ ។

ធនធានវិភាជន៍ខាងលើនេះត្រូវផ្តល់ទៅឱ្យឃុំ សង្កាត់តាមរតនាគារខេត្ត ក្រុង ។

ការរៀបចំនិងនីតិវិធីនៃការផ្ទេរប្រាក់វិភាជន៍ខាងលើនេះត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៧៦.-**

ឃុំ សង្កាត់នីមួយៗ មានសិទ្ធិទទួលបាននូវប្រាក់កំរៃ ចំពោះការអនុវត្តនូវតួនាទីជាភ្នាក់ងារតំណាងរដ្ឋដែលរាជរដ្ឋាភិបាល ឬក្រសួងស្ថាប័នណាមួយនៃរាជរដ្ឋាភិបាលបានប្រគល់ឱ្យអនុវត្ត ។

ប្រាក់កំរៃខាងលើនេះគឺជាប្រាក់បន្ថែមពីលើប្រាក់ចំណូលរបស់ឃុំ សង្កាត់ ឬប្រាក់វិភាជន៍ផ្សេងៗដែលឃុំ សង្កាត់ទទួលបានពីប្រាក់ចំណូលរដ្ឋ ។ល។

រាជរដ្ឋាភិបាលឬក្រសួងស្ថាប័នណាមួយនៃរាជរដ្ឋាភិបាលត្រូវផ្តល់កំរៃសមស្របដល់ឃុំ សង្កាត់ ដែលបានអនុវត្តតួនាទីជាភ្នាក់ងារតំណាងរដ្ឋដូចបានចែងខាងលើ ។

ក្នុងករណីដែលការប្រគល់អំណាច មុខងាររបស់រដ្ឋមានលក្ខណៈជាអចិន្ត្រៃយ៍ទៅឱ្យឃុំ សង្កាត់រាជរដ្ឋាភិបាលត្រូវរៀបចំឱ្យមានធនធានហិរញ្ញវត្ថុរយៈពេលយូរអង្វែងសំរាប់ផ្តល់ឱ្យឃុំ សង្កាត់ ។

ការរៀបចំប្រាក់កំរៃខាងលើនេះត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៧៧.-**

រដ្ឋបង្កើតឱ្យមានមូលនិធិឃុំ សង្កាត់ ។

មូលនិធិឃុំ សង្កាត់បង្កើតឡើងក្នុងគោលដៅដើម្បីធ្វើការផ្ទេរនូវប្រាក់ចំណូលពីជាតិនិងប្រាក់ចំណូលផ្សេងៗទៀតទៅឱ្យថវិកាឃុំ សង្កាត់ ។

ការផ្ទេរប្រាក់ចំណូលពីជាតិទៅមូលនិធិខាងលើនេះត្រូវធ្វើឡើងទៅតាមរូបមន្តឬតាមអត្រាជាក់លាក់មួយសំរាប់ថេរៈវេលាយ៉ាងតិច ៣ឆ្នាំ និងមិនលើសពី ៥ឆ្នាំដែលកំណត់ដោយអនុក្រឹត្យ ។

នីតិវិធីអនុវត្តជាក់ស្តែងនៃមាត្រានេះត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៧៨.-**

មូលនិធិឃុំ សង្កាត់បានមកពី :

- ការធ្វើវិភាជន៍នូវចំណែកដ៏ជាក់លាក់នៃប្រាក់ចំណូលរដ្ឋ ពីថវិការដ្ឋប្រចាំឆ្នាំដែលកំណត់ដោយអនុក្រឹត្យ
- អនុប្បទាននិងការខ្ចីពីប្រភពក្នុងប្រទេសនិងក្រៅប្រទេស ។

ការធ្វើវិភាជន៍នូវធនធានប្រចាំឆ្នាំទៅឱ្យឃុំ សង្កាត់តាមមូលនិធិឃុំ សង្កាត់ត្រូវធ្វើឡើងទៅតាមរូបមន្តដែលកំណត់ដោយអនុក្រឹត្យ ។

របៀបរបបចាត់ចែង វិធាននៃការប្រើប្រាស់និងនីតិវិធីនៃការបើកប្រាក់ចំ-ណាយពីមូលនិធិឃុំ សង្កាត់ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៧៩.-**

ឃុំ សង្កាត់ត្រូវរៀបចំនិងអនុម័តថវិការបស់ខ្លួនជារៀងរាល់ឆ្នាំ ។ល.ល.

ថវិកាឃុំ សង្កាត់ត្រូវរៀបចំទៅតាមទំរង់មួយនិងអនុម័តនៅក្នុងកាលបរិច្ឆេទ ឬមុនកាលបរិច្ឆេទមួយអនុលោមទៅតាមប្រពន្ធ័ថវិកាជាតិ ។

ថវិកាឃុំ សង្កាត់ត្រូវមានតុល្យភាពរវាងចំណូលសរុបនិងចំណាយសរុប ។

ឃុំ សង្កាត់អាចបង្កើនចំណាយបាន តែត្រូវឱ្យស្របទៅតាមចំណូលរបស់ខ្លួន ។

ថវិកាឃុំ សង្កាត់ត្រូវឆ្លុះបញ្ចាំងអំពីអាទិភាពនិងសេចក្តីត្រូវការនៃផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគរបស់ឃុំ សង្កាត់ ។

នីតិវិធីនៃការរៀបចំនិងការអនុម័តថវិកាខាងលើត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៨០.-**

ឃុំ សង្កាត់គ្មានសិទ្ធិខ្ចីប្រាក់បានឡើយ ។

ឃុំ សង្កាត់មិនអាចធានារ៉ាប់រងចំពោះការខ្ចី ឬកាតព្វកិច្ចហិរញ្ញវត្ថុណាមួយបានឡើយ ។

**មាត្រា ៨១.-**

ឃុំ សង្កាត់មានសិទ្ធិទទួលបាននូវការផ្ទេរទ្រព្យសម្បត្តិមួយផ្នែករបស់រដ្ឋមកជាទ្រព្យសម្បត្តិរបស់ឃុំ សង្កាត់ ។

ឃុំ សង្កាត់ត្រូវគ្រប់គ្រងឱ្យបានល្អនូវទ្រព្យសម្បត្តិដែលរកបានដោយខ្លួនឯងនិងទ្រព្យសម្បត្តិដែលរដ្ឋបានប្រគល់ឱ្យ ។

ឃុំ សង្កាត់អាចប្រើប្រាស់និងទាញយកផលចំណូលពីទ្រព្យសម្បត្តិដែលរដ្ឋបានប្រគល់ឱ្យខ្លួនគ្រប់គ្រង ។

ឃុំ សង្កាត់ត្រូវថែរក្សាការពារទ្រព្យសម្បត្តិដែលរដ្ឋប្រគល់ឱ្យៗបានគង់វង្ស ហើយទ្រព្យសម្បត្តិទាំងនោះ ឃុំ សង្កាត់គ្មានសិទ្ធិលក់ដូរឬផ្ទេរកម្មសិទ្ធិ ឬផ្ទេរការប្រើប្រាស់ដោយគ្មានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីមានយោបល់ឯកភាពរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានឡើយ ។

នីតិវិធីចាត់ចែងនិងប្រើប្រាស់ទ្រព្យសម្បត្តិខាងលើ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៨២.-**

ឃុំ សង្កាត់ត្រូវបង្កើតឱ្យមាននូវប្រព័ន្ធគ្រប់គ្រង តាមដាននិងត្រួតពិនិត្យហិរញ្ញ-វត្ថុរបស់ខ្លួនដែលរួមមាន : ម.ត.

- បទដ្ឋានហិរញ្ញវត្ថុនិងការអនុវត្តជាក់ស្តែងផ្នែកគណនេយ្យ

- ការចាត់ចែង គ្រប់គ្រងទ្រព្យសម្បត្តិ

- តំរូវការផ្សេងៗ ក្នុងការធ្វើសវនកម្ម

- ការគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយតម្លាភាព ប្រសិទ្ធិភាពនិងការទទួលខុសត្រូវ ។

ប្រព័ន្ធនៃការគ្រប់គ្រង ការតាមដាននិងការត្រួតពិនិត្យហិរញ្ញវត្ថុឃុំ សង្កាត់ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៨៣.-**

របបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ឃុំ សង្កាត់ត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីបានពិភាក្សាឯកភាពលើគោលការណ៍ជាមួយក្រសួងមហាផ្ទៃ ។

## ជំពូកទី ៨
## ទោសប្បញ្ញត្តិ

**មាត្រា ៨៤.-**

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលមិនគោរពតាមបទប្បញ្ញត្តិនៃច្បាប់នេះត្រូវទទួលវិន័យដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ។

វិន័យរួមមាន :

- ស្តីបន្ទោសក្នុងអង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ដោយមានកំណត់ហេតុច្បាស់លាស់

- ករណីនៅតែបន្តប្រព្រឹត្តកំហុស ត្រូវកាត់មួយផ្នែកឬទាំងអស់នូវប្រាក់ឧបត្ថម្ភ ។

វិន័យដែលតម្រូវឱ្យកាត់មួយផ្នែកឬទាំងអស់នូវប្រាក់ឧបត្ថម្ភដូចចែងខាងលើអាចអនុវត្តបាន លុះត្រាតែមានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមសេចក្តីស្នើសុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

ប្រាក់ឧបត្ថម្ភដែលកាត់នេះត្រូវបានមកជាប្រយោជន៍នៃថវិកាឃុំ សង្កាត់ ។ល។

ក្នុងករណីបានអនុវត្តបកាពវិន័យទាំងពីរខាងលើរួចហើយ តែសាមីខ្លួននៅតែមិនរាងចាល ក្រុមប្រឹក្សាឃុំ សង្កាត់អាចបញ្ឈប់ជននោះពីមុខតំណែងជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដោយការបោះឆ្នោតអនុម័តតាមសម្លេងភាគច្រើនដាច់ខាតនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូល ហើយត្រូវធ្វើការជ្រើសរើសសមាជិកថ្មីមកជំនួសតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងវាក្យខ័ណ្ឌទី ២ មាត្រា ១៦នៃច្បាប់នេះ ។

ក្នុងករណីប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ជាមេឃុំ ចៅសង្កាត់ទទួលវិន័យ ត្រូវជ្រើសយកសមាជិកណាម្នាក់ក្នុងក្រុមប្រឹក្សាឬមន្ត្រីម្នាក់ដែលចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃឱ្យដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីអនុវត្តបកាពវិន័យខាងលើនេះ ។

មន្ត្រីដែលចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃឱ្យដឹកនាំកិច្ចប្រជុំខាងលើនេះពុំមានសិទ្ធិអនុម័តឡើយ ។

## ជំពូកទី ៩
## អន្តរប្បញ្ញត្តិ

**មាត្រា ៨៥.-**

ដើម្បីមានមូលដ្ឋានសំរាប់រៀបចំបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់និងគ្រប់គ្រងឃុំ សង្កាត់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញប្រកាសអំពីចំនួន ឈ្មោះនិងព្រំប្រទល់របស់ឃុំ សង្កាត់ ក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជាឱ្យបាន ៩ខែមុនកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិដំបូងនេះ ។

**មាត្រា ៨៦.-**

ក្រោយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិទី ១ នេះ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗ ត្រូវរៀបចំឡើងវិញនូវមេភូមិនានាចំណុះឃុំ សង្កាត់របស់ខ្លួនទៅតាមបែបបទនីតិវិធីដូចមានចែងក្នុងមាត្រា ៣០នៃច្បាប់នេះ ។

**មាត្រា ៨៧.-**

ដើម្បីបង្កលក្ខណៈសម្បត្តិដល់ការគ្រប់គ្រងឃុំ សង្កាត់តាមប្រព័ន្ធវិមជ្ឈការត្រូវបង្កើតគណៈកម្មាធិការអន្តរក្រសួងមួយឈ្មោះថា "គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់" ដែលមានរដ្ឋមន្ត្រីក្រសួងមហាផ្ទៃជាប្រធាន ។ល។

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ត្រូវបង្កើតឡើងដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី ។

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ត្រូវបង្កើតបន្ទាប់ពីច្បាប់នេះបានចូលជាធរមាន ហើយត្រូវបញ្ចប់អាណត្តិរបស់ខ្លួនឱ្យបាន ៩ខែមុនកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិបន្ទាប់ ។

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់អាចចែកចេញជាអនុគណៈកម្មការតាមការចាំបាច់ ។

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ត្រូវយកអង្គភាពដែលបានបង្កើតឡើងស្របតាមមាត្រា ៥៩នៃច្បាប់នេះធ្វើជាលេខាធិការដ្ឋាន ។

**មាត្រា ៨៨.-**

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់មានសមត្ថកិច្ចធ្វើសេចក្តីស្នើយោបល់ទៅក្រសួងមហាផ្ទៃនិងរាជរដ្ឋាភិបាលអំពីបញ្ហានានាដូចខាងក្រោម :

- សិក្សាស្រាវជ្រាវកំណត់ឡើងវិញនូវព្រំប្រទល់ឃុំ សង្កាត់ទាំងអស់ក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា
- បែងចែកមុខងារ សិទ្ធិអំណាចនិងភារកិច្ចផ្សេងៗ រវាងរាជរដ្ឋាភិបាលនិងឃុំ សង្កាត់ព្រមទាំងរៀបចំឱ្យមានកិច្ចសហការសំរបសំរួលរវាងឃុំ សង្កាត់ ពីរឬច្រើន ។
- បណ្តុះបណ្តាល បង្កើនសមត្ថភាពដល់ក្រុមប្រឹក្សាឃុំ សង្កាត់
- រៀបចំប្រាក់ចំណូលនិងសារពើពន្ធសំរាប់ឃុំ សង្កាត់
- គាំទ្រផ្នែកបច្ចេកទេសដល់ឃុំ សង្កាត់
- វិធានការយោបាយសំរាប់ផ្តល់ពត៌មាននិងគំរង់ទិសរដ្ឋបាលសាធារណៈអំពីកិច្ចដំណើរការនៃប្រព័ន្ធគ្រប់គ្រងឃុំ សង្កាត់តាមបែបប្រជាធិបតេយ្យនិងវិមជ្ឈការ
- ផ្តល់យោបល់ដល់រាជរដ្ឋាភិបាលអំពីការអនុវត្តនយោបាយវិមជ្ឈការក្រោមអំណាចនៃច្បាប់នេះនិងផ្តល់យោបល់លើការកែទម្រង់រដ្ឋបាលសាធារណៈ
- រៀបចំព្រាងលិខិតបទដ្ឋានសំរាប់អនុវត្តច្បាប់នេះ
- រួមយោបល់ទៅលើអនុក្រឹត្យដែលមានការពាក់ព័ន្ធដល់ការងារនៅថ្នាក់ឃុំ សង្កាត់ ល។

- កំណត់របបគ្រប់គ្រងរដ្ឋបាលអន្តរកាលចំពោះឃុំ សង្កាត់ដែលពុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីអនុវត្តនយោបាយវិមជ្ឈការ ។

**មាត្រា ៨៩.-**

ក្រោយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិដំបូងនេះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដោយផ្អែកតាមសេចក្តីស្នើយោបល់របស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់អាចស្នើបង្កើតឃុំ សង្កាត់ លុបចោលឃុំ សង្កាត់ កែប្រែព្រំប្រទល់ឃុំ សង្កាត់ ផ្លាស់ប្តូរឈ្មោះឃុំ សង្កាត់ តាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ៦ និងមាត្រា ១៧នៃច្បាប់នេះ សំរាប់ដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាអាណត្តិទី ២ ។

## ជំពូកទី ១០
## អវសានប្បញ្ញត្តិ

**មាត្រា ៩០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។៚

រាជធានីភ្នំពេញថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០០១

ក្នុងព្រះបរមនាមនិងតាមព្រះរាជបង្គាប់

ប្រមុខរដ្ឋស្តីទី

**ហត្ថលេខា**

**ជា ស៊ីម**

បានបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

**ហត្ថលេខា**

**ស ខេង យូ ហុកគ្រី**

លេខ : ៧០ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញថ្ងៃទី ២១ ខែ ០៣ ឆ្នាំ២០០១

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាវ ឆី ស្វាន**

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ..១៤៣..អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការប្តូរឃុំនៃរាជធានីភ្នំពេញទៅជាសង្កាត់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៤ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០២០ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៦ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សា ស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១០/៧៦៣ ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១០ ស្តីពីការកែ សម្រួលព្រំប្រទល់រដ្ឋបាលរវាងរាជធានីភ្នំពេញ និងខេត្តកណ្តាល ដោយកាត់យកឃុំចំនួន ២០ នៃខេត្តកណ្តាល មកបញ្ចូលក្នុងរាជធានីភ្នំពេញ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

ត្រូវបានប្តូរឃុំចំណុះខណ្ឌសែនសុខ រាជធានីភ្នំពេញ មកជាសង្កាត់ មានដូចខាងក្រោម :

- ឃុំព្រែកព្នៅ ទៅជា សង្កាត់ព្រែកព្នៅ
- ឃុំសំរោង ទៅជា សង្កាត់សំរោង
- ឃុំពញាពន់ ទៅជា សង្កាត់ពញាពន់ ។

**មាត្រា ២.-**

ត្រូវបានប្តូរឃុំចំណុះខណ្ឌដង្កោ រាជធានីភ្នំពេញ មកជាសង្កាត់ មានដូចខាងក្រោម :

- ឃុំពន្សាំង ទៅជា សង្កាត់ពន្សាំង
- ឃុំស្នោរ ទៅជា សង្កាត់ស្នោរ
- ឃុំឪឡោក ទៅជា សង្កាត់ឪឡោក
- ឃុំបឹងធំ ទៅជា សង្កាត់បឹងធំ
- ឃុំកំបូល ទៅជា សង្កាត់កំបូល
- ឃុំកន្ទោក ទៅជា សង្កាត់កន្ទោក
- ឃុំគងនយ ទៅជា សង្កាត់គងនយ
- ឃុំទៀន ទៅជា សង្កាត់ទៀន
- ឃុំរលួស ទៅជា សង្កាត់រលួស
- ឃុំស្ពានថ្ម ទៅជា សង្កាត់ស្ពានថ្ម
- ឃុំព្រែកកំពឹស ទៅជា សង្កាត់ព្រែកកំពឹស ។

**មាត្រា ៣.-**

ត្រូវបានប្តូរឃុំចំណុះខណ្ឌមានជ័យ រាជធានីភ្នំពេញ មកជាសង្កាត់ មានដូចខាងក្រោម :

- ឃុំវាលស្បូវ ទៅជា សង្កាត់វាលស្បូវ
- ឃុំព្រែកឯង ទៅជា សង្កាត់ព្រែកឯង
- ឃុំក្បាលកោះ ទៅជា សង្កាត់ក្បាលកោះ
- ឃុំព្រែកថ្មី ទៅជា សង្កាត់ព្រែកថ្មី ។

**មាត្រា ៤.-**

ត្រូវបានប្តូរឃុំចំណុះខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ មកជាសង្កាត់ មានដូចខាងក្រោម :

- ឃុំបាក់ខែង ទៅជា សង្កាត់បាក់ខែង
- ឃុំកោះដាច់ ទៅជា សង្កាត់កោះដាច់ ។

**មាត្រា ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ អភិបាលខណ្ឌពាក់ព័ន្ធ និងចៅសង្កាត់ពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ២០១០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៦*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខណ្ឌច្បារអំពៅ
រដ្ឋបាលសង្កាត់ក្បាលកោះ

សៀវភៅ

# កម្មវិធីវិនិយោគបីឆ្នាំរំកិល

## ២០១៨-២០២០

របស់

## សង្កាត់ក្បាលកោះ

ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ

# មាតិកា


សេចក្តីសម្រេចស្តីពីការដាក់ឲ្យប្រើប្រាស់កម្មវិធីវិនិយោគបីឆ្នាំរំកិល ២០១៨-២០២០.......... ១
អារម្ភកថា ៖.......................................................................................... ២
សេចក្តីផ្តើម ៖....................................................................................... ៣
ផែនទីសង្កាត់ ៖.................................................................................... ៤
**ជំពូកទី ១ ៖** ស្ថានភាពសេដ្ឋកិច្ច ............................................................ ៥
១.១ សេចក្តីសង្ខេបទិន្នន័យចម្បងក្នុងសង្កាត់.................................................. ៦
១.២ ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈម ....................................................... ៧
-ផ្នែកសេដ្ឋកិច្ច ..................................................................................... ៧
-ផ្នែកសង្គមកិច្ច..................................................................................... ៨
-ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ....... ១០
-ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ........................................ ១១
**ជំពូកទី២ ៖** គម្រោង សកម្មភាពនៃកម្មវិធីវិនិយោគបីឆ្នាំរំកិលសង្កាត់.................. ១៣
២.១ តារាងសង្ខេបប្រភពមូលនិធិ................................................................ ១៣
២.២ តារាងគម្រោង សកម្មភាពកំពុងដំណើរការ.................................................. ២២
២.៣ តារាងគម្រោង សកម្មភាពមានថវិកាគាំទ្រ.................................................. ១៦
២.៤ តារាងគម្រោង សកម្មភាពមិនមានការថវិកាគាំទ្រ......................................... ២៤
២.៥ កម្មវិធីប្រតិបត្តិការសេវារដ្ឋបាល.............................................................. ២៦
២.៦ តារាងការដាក់ចេញលិខិតបទដ្ឋានគតិយុត្តនានា.......................................... ២៧
**ជំពូកទី៣ ៖** ការតាមដាន និងវាយតម្លៃ ការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលសង្កាត់........ ២៨
៣.១ ក្របខណ្ឌតាមដាន និងវាយតម្លៃ................................................................ ២៨
៣.២ ការបែងចែកភារកិច្ចរបស់អ្នកពាក់ព័ន្ធ ក្នុងការតាមដាន និងវាយតម្លៃ.............. ២៩
៣.៣ របាយការណ៍ ស្តីពីលទ្ធផលតាមដាន និងវាយតម្លៃកម្មវិធីវិនិយោគបីឆ្នាំរំកិល..... ៣០
**ឧបសម្ព័ន្ធ ៖**
១.១ ការកំណត់បញ្ហា តម្រូវការ និងដំណោះស្រាយតាមភូមិ.................................... ៤១
១.២ ការកំណត់បញ្ហា តម្រូវការ និងដំណោះស្រាយថ្នាក់សង្កាត់............................ ៤៥
កំណត់ហេតុកិច្ចប្រជុំវិសាមញ្ញ ដើម្បីអនុម័តលើកម្មវិធីវិនិយោគបីឆ្នាំរំកិល.................. ៤៩
................................................................................................................ ៥០
បញ្ជីវត្តមានកិច្ចប្រជុំវិសាមញ្ញ.....................................................................

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខណ្ឌច្បារអំពៅ
រដ្ឋបាលសង្កាត់ក្បាលកោះ
០២៣ / ១៨ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការដាក់ឲ្យប្រើប្រាស់កម្មវិធីវិនិយោគបីឆ្នាំរំកិល ២០១៨-២០២០
## របស់ក្រុមប្រឹក្សាសង្កាត់ក្បាលកោះ

-ព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩-មីនា-២០០១ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់ ។
-អនុក្រឹត្យលេខ ២២ អនក្រ.បក ចុះថ្ងៃទី២៥-មីនា-២០០២ ស្តីពីការផ្ទេរមុខងារអំណាច តួនាទីនិងភារកិច្ចទៅឱ្យ ក្រុមប្រឹក្សាឃុំ/សង្កាត់
-ប្រកាសលេខ ៨៣៣៩ ប្រ.ក ចុះថ្ងៃទី ២០-ធ្នូ-២០១៧ របស់ក្រសួងមហាផ្ទៃ ស្តីពីការទទួលស្គាល់សមាភាព ក្រុមប្រឹក្សាសង្កាត់ ប្រធានក្រុមប្រឹក្សាសង្កាត់ ចៅសង្កាត់ ចៅសង្កាត់រងទី១ ចៅសង្កាត់រងទី២ នៃសង្កាត់ក្បាលកោះ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ។
-កិច្ចប្រជុំវិសាមញ្ញក្រុមប្រឹក្សាសង្កាត់អនុម័ត ថ្ងៃទី ០៩-មីនា-២០១៨
-ភារកិច្ចចាំបាច់ចំពោះមុខ ។

## សម្រេច

**ប្រការ១:** ដាក់ឲ្យប្រើប្រាស់នូវកម្មវិធីវិនិយោគបីឆ្នាំរំកិល ( ២០១៨-២០២០ ) របស់សង្កាត់ក្បាលកោះ ដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាសង្កាត់ ក្នុងកិច្ចប្រជុំវិសាមញ្ញលើកទី ៣ អាណត្តិទី៤ នាថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០១៨ ។

**ប្រការ២ :** ក្រុមប្រឹក្សាសង្កាត់ត្រូវចាត់ចែងផ្សព្វផ្សាយផែនការនេះ ដល់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា ក្នុងមូលដ្ឋានសង្កាត់ ព្រមទាំងត្រូវចាត់ចែងសម្របសម្រួល និងតៀងគរធនធាននានាក្នុងការអនុវត្តផែនការនេះ ប្រកបដោយតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពខ្ពស់ ។

**ប្រការ៣:** ក្រុមប្រឹក្សាសង្កាត់ ត្រូវរៀបចំតាមដាន និងវាយតម្លៃការអនុវត្តការនេះ ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្ត ។

**ប្រការ៤ :** ក្រុមប្រឹក្សាសង្កាត់ ត្រូវការវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលនេះ នៅពាក់កណ្តាលអាណត្តិ និងចុងអាណត្តិរបស់ក្រុមប្រឹក្សា ដើម្បីវាយតម្លៃអំពីលទ្ធផលដែលអាចសម្រេចបាន ធៀបនឹងគោលដៅ និងគោលបំណង ដែលបានកំណត់ក្នុងផែនការអភិវឌ្ឍន៍សង្កាត់ ។

**ប្រការ៥:** រដ្ឋបាលសង្កាត់និងអង្គភាពពាក់ព័ន្ធ ត្រូវអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ថ្ងៃសុក្រ ៨រោច ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស២៥៦១
ក្បាលកោះ ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ២០១៨
ចៅសង្កាត់ក្បាលកោះ

ឃី_សុខ

ចម្លងជូន
-រដ្ឋបាលខណ្ឌច្បារអំពៅ
(ដើម្បីជូនជ្រាប)
-ដូចប្រការ៥
(ដើម្បីអនុវត្ត)
-ឯកសារ កាលប្បវត្តិ

# អារម្ភកថា

ក្រុមប្រឹក្សាសង្កាត់ក្បាលកោះ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ អាណត្តិទី៤ បានប្រសូត្រឡើង ដោយ...បោះឆ្នោត នាថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១៧ ហើយបាននឹង កំពុងដំណើរការរួមគ្នាបំរើប្រជាពលរដ្ឋជា...នៅក្នុងសង្កាត់និងអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ។

ក្រុមប្រឹក្សាសង្កាត់ក្បាលកោះ បានរៀបចំកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល ( ២០១៨-២០២០ ) ដោយ...លើផែនការអភិវឌ្ឍន៍រយៈពេល ៥ ឆ្នាំ (២០១៨-២០២២) សម្រាប់ជួយដល់ក្រុមប្រឹក្សាសង្កាត់ក្នុងការចាត់...ង សម្របសម្រួល គៀងគរធនធាននានា ក្នុងការអនុវត្តគម្រោង ឬ សកម្មភាពអភិវឌ្ឍន៍ ឲ្យឆ្លើយតបទៅនឹង...ត្រូវការពិតប្រាកដរបស់ប្រជាពលរដ្ឋនៅក្នុងសង្កាត់ ប្រកបដោយតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពខ្ពស់...ជាកែលម្អ និងលើកកម្ពស់គុណភាពនៃការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ ។

ក្នុងនាមក្រុមប្រឹក្សាសង្កាត់ក្បាលកោះអាណត្តិទី៤ ខ្ញុំសូមថ្លែងអំណរគុណដល់ប្រជាពលរដ្ឋក្នុងសង្កាត់...ដែលបានចូលរួមក្នុងការលើកឡើង អំពីបញ្ហាជាក់ស្តែងបានជួបប្រទះ និង សេចក្តីត្រូវការអភិវឌ្ឍន៍នានា ។ ...មួយគ្នានេះ ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់គណៈកម្មការកសាងផែនការ និង ថវិកាសង្កាត់ជន...បង្គោលនានារបស់សង្កាត់ មន្ត្រីបច្ចេកទេសគាំទ្រសង្កាត់ តំណាងមន្ទីរនានា ទីចាត់ការផែនការនិងវិនិយោគ និង...អង្គការសង្គមស៊ីវិល វិស័យឯកជន អ្នកពាក់ព័ន្ធនានា ដែលបានរួមចំណែក និងគាំទ្រនៅក្នុងដំណើរការរៀបចំក...សាងកម្មវិធីវិនិយោគបីឆ្នាំរំកិលនេះ រហូតសម្រេចជាស្ថាពរ ។

ក្នុងនាមក្រុមប្រឹក្សាសង្កាត់ក្បាលកោះ ខ្ញុំសូមអំពាវនាវដល់មន្ទីរជំនាញ អង្គការជាតិ អង្គការអន្តរជាតិ...ប្បុរសជន និងដៃគូអភិវឌ្ឍន៍នានា ជួយគាំទ្ររាល់គម្រោងឬ សកម្មភាពជាអាទិភាព ដែលមាននៅក្នុងកម្មវិធី...វិនិយោគបីឆ្នាំរំកិលនេះ ។

ខ្ញុំសូមប្រសិទ្ធិពរជ័យ មហាប្រសើរមានដល់ ឯកឧត្តម លោកឧកញ៉ា លោក-លោកស្រី នាងកញ្ញាទាំង...អស់ជានិច្ចនិរន្តន៍តរៀងទៅ ។

ថ្ងៃសុក្រ ៨រោច ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស ២៥៦១

ក្បាលកោះ ថ្ងៃទី [illegible] មីនា ឆ្នាំ ២០១៨

ចៅសង្កាត់ក្បាលកោះ

ឃី_សុខ

# ជំពូកទី១

## ស្ថានភាពទូទៅ និងបញ្ហាប្រឈមក្នុងសង្កាត់

# ជំពូកទី១
## ស្ថានភាពទូទៅ និងបញ្ហាប្រឈមសង្កាត់ក្បាលកោះ

### ១. ស្ថានភាពព័ត៌មានទូទៅរបស់សង្កាត់ក្បាលកោះ
#### ១.១ ស្ថានភាពភូមិសាស្ត្រ

សង្កាត់ក្បាលកោះ គឺជាសង្កាត់មួយក្នុងចំណោមសង្កាត់សរុប ៨ នៃខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ដែលមានព្រំប្រទល់ខាងលិចទល់នឹង សង្កាត់ព្រែកឯង ខណ្ឌច្បារអំពៅ ខាងកើតទល់នឹងឃុំភូមិធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល ខាងជើងទល់នឹងទន្លេមេគង្គ ស្រុកល្វាឯម ខេត្តកណ្តាល ខាងត្បូងទល់នឹង សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មានផ្ទៃដីសរុបចំនួន ២៩១១,៤៥ ហិចតា ,និងមានភូមិចំនួន ៨ គឺភូមិជ្រោយអំពិល,ភូមិជ្រោយអំពិល១ ,ភូមិជ្រោយអំពិល២, ភូមិយកបាត្រ , ភូមិយកបាត្រ១ , ភូមិព្រែកធំ , ភូមិព្រែកធំ១ ,ភូមិព្រែកធំ២ ។

#### ១.២ សេចក្តីសង្ខេបព័ត៌មាន និងទិន្នន័យសេដ្ឋកិច្ច សង្គមកិច្ច ៖

( សេចក្តីសង្ខេបទិន្នន័យចម្បងរបស់សង្កាត់ក្បាលកោះ )

| ល.រ | បរិយាយ | ឆ្នាំ២០១៧ |
|---|---|---|
| **ព័ត៌មានទូទៅ** | | |
| ១ | ផ្ទៃដី សង្កាត់ (ហិចតា) | ២៩១១,៤៥ ហត |
| ២ | ចំនួនភូមិ | ៨ភូមិ |
| ៣ | ចំនួនគ្រួសារ | ៣៧៦៥ |
| ៤ | %មេគ្រួសារជាស្ត្រី | ២៣,៣% |
| ៥ | ចំនួនប្រជាជនសរុប | ១៦៨៦៩ |
| ៦ | ចំនួនស្រី | ៩១៤៣ |
| ៧ | ចំនួនប្រុស | ៧៧២៦ |
| ៨ | %អ្នកមានអាយុពី០-១៧ឆ្នាំ | ១៩,៤% |
| ៩ | %អ្នកមានអាយុពី១៨-៦០ឆ្នាំ | ៦៧,០% |
| ១០ | %អ្នកមានអាយុពី៦១ឆ្នាំឡើង | ១៣,៦% |
| ១១ | កំណើនប្រជាជនប្រចាំឆ្នាំ (%) | ១៥,៣% |
| ១២ | អត្រាភាពក្រីក្រ (%) | ១៤,៣% |
| ១៣ | %អ្នកមានមុខរបរចម្បងផ្នែកកសិកម្ម | 0 |
| ១៤ | %អ្នកមានមុខរបរចម្បងផ្នែកសិប្បកម្ម | ១,១% |
| ១៥ | %អ្នកមានមុខរបរចម្បងផ្នែកសេវាកម្ម | ៩៨,៩% |
| ១៦ | %មនុស្សទៅរកការងារធ្វើនៅក្នុងប្រទេស | ១.៨% |
| ១៧ | %មនុស្សទៅរកការងារធ្វើនៅក្រៅប្រទេស | 0,៧% |
| ១៨ | %ខ្នងផ្ទះមានអគ្គិសនីប្រើប្រាស់ | ១00% |

| | | |
|---|---|---|
| ៤៣ | ចំនួនអ្នកស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍ | ០ |
| ៤៤ | ចំនួនអ្នកស្លាប់ដោយអំពើហិង្សានានា | ០ |
| ៤៥ | ចំនួនគ្រួសារមានសមាជិកប្រើប្រាស់គ្រឿងញៀន | ០៦ |

## ១. ២ ការវិភាគស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈម

### ១.២.១ -ផ្នែកសេដ្ឋកិច្ច

+ស្ថានភាពមុខរបរ ៖ គ្រួសារមានមុខរបរធ្វើកសិកម្ម ជាចំបងសំដៅលើគ្រួសារធ្វើស្រែ ដាំដំណាំ ដាំបន្លែ ចិញ្ចឹមសត្វ មានមុខរបរពីអនុផលព្រៃឈើ ស្មើនឹង ០,៣៣% គ្រួសារដែលមានមុខរបរសិប្បកម្មជាចំបងសំដៅលើគ្រួសារដែលធ្វើការផលិតទ្វារ បង្អួច ពោះវៀនកង់ ម៉ូតូ គ្រឿង ឧបភោគបរិភោគ និងសិប្បកម្មផ្សេងៗស្មើនឹង ០,០៨% គ្រួសារប្រកបមុខរបរសេវាកម្ម ជាចំបងរួមមានមុខរបរធ្វើជំនួញ ជាងជួសជុល មុខរបរដឹកជញ្ជូន និង សេវាកម្មផ្សេងៗមានចំនួន ៧,៩២% គ្រួសារប្រកបមុខរបរមិនច្បាស់លាស់ (ចំរុះ) ក្រៅពីមុខរបរចំបងខាងលើចំនួន ១៨,៣២% ដែលជាសក្តានុពលយ៉ាងសំខាន់ក្នុងការទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ក្នុងសង្កាត់ទាំងមូល ។

**+ ការងារសាធារណការ៖** ក្នុងសង្កាត់មានផ្លូវខ្វាត់ខ្វែងគ្រប់ប្រភេទ ដូចជាផ្លូវបេតុង ផ្លូវដីស ព្រមទាំងមានភ្លើងបំភ្លឺផ្លូវសាធារណៈមួយចំនួនធំដែលបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋនិងភ្ញៀវទេសចរណ៍ ក្នុងការធ្វើដំណើរ និងប្រកបមុខរបរបានទាំងពេលយប់ទាំងពេលថ្ងៃ ។ ផ្លូវ និងភ្លើងបំភ្លឺទាំងនេះស្ថាបនាឡើងដោយថវិកាវិភាជន៍របស់រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលផ្តល់សំរាប់គម្រោងកម្មវិធីគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) សាលារាជធានីភ្នំពេញ សប្បុរសជន អង្គការដៃគូនានា និងមានការចូលរួមចំណែកពីប្រជាពលរដ្ឋផងដែរ ។ ទន្ទឹមនឹងការងារគមនាគមន៍ សង្កាត់ក៏នៅមានផ្លូវដីស ផ្លូវទាល់ ផ្លូវតូចចង្អៀតជាច្រើនទៀត និងផ្លូវដែលបានស្ថាបនារួចហើយមានការខូចខាតទៅវិញ ដោយសាររដូវវស្សាមានទឹកភ្លៀង និងទឹកជំនន់លិច ។ ផ្លូវខ្លះខ្វះ ប្រព័ន្ធលូ ផ្លូវចាស់ទ្រុឌទ្រោម ការស្ថាបនាផ្លូវកន្លងមកនៅខ្វះបច្ចេកទេស និងនៅមានការសង់លំនៅដ្ឋានរំលោភលើចំណីផ្លូវ ហើយមានការដាក់លក់ដូរលើចិញ្ចើមផ្លូវ លើសពីនេះនៅមានផ្លូវជាច្រើនខ្សែទៀត ដែលមិនទាន់មានភ្លើងបំភ្លឺសាធារណៈ ទាមទារការចូលរួមពីប្រជាពលរដ្ឋនៅតាមផ្លូវនោះ ។

ក្នុងរយៈពេលកន្លងមកក្រុមប្រឹក្សាសង្កាត់អាណត្តិទី៣ ក៏បានខិតខំប្រឹងប្រែងយកអស់លទ្ធភាពអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធក្នុងមូលដ្ឋាន បានលទ្ធផលល្អគួរឲ្យមោទនៈភាពខ្ពស់ក៏ប៉ុន្តែនៅមានចំណុចសេសសល់ខ្លះទៀត ដែលក្រុមប្រឹក្សាសង្កាត់អាណត្តិទី៤ នេះ ត្រូវតែពុះពារអភិវឌ្ឍន៍ឲ្យទទួលបានលទ្ធផលខ្ពស់បន្តទៀត ដើម្បីបំពេញតម្រូវការរបស់ប្រជាពលរដ្ឋ ។

**+ការងារកសិកម្ម ៖** ដោយសារតែសង្កាត់ស្ថិតនៅក្នុងតំបន់កំពុងអភិវឌ្ឍន៍ ដូច្នេះការងារកសិកម្មនៅមានសកម្មភាពបន្តិចបន្តួច ។

**+ការងារពាណិជ្ជកម្ម និងអាជីវកម្ម ៖** នៅក្នុងសង្កាត់មានអាជីវកម្មខ្នាតតូច ១២៥ ទីតាំង ដែលបានចុះបញ្ជីពាណិជ្ជកម្ម ដែលចែកចេញជាផ្នែកទំនិញ ឧបភោគបរិភោគ អាជីកម្មហូបចុក និងអាជីវកម្មផ្សេងៗ ដែលជាប្រភពសក្តានុពលផ្នែករាជីវ កម្មពាណិជ្ជកម្មសំរាប់ទ្រទ្រង់ជីវភាពមួយផ្នែកធំរបស់ប្រជា

ដល់ផ្ទះតាមការអនុវត្តជាក់ស្តែង មូលដ្ឋានពាណិជ្ជកម្ម អាជីវកម្មភាគច្រើនមានលក្ខណៈជាគ្រួសារ ... ពិតប្រាកដនៅឡើយ ។

•ការងារឧស្សាហកម្ម និងសិប្បកម្ម ៖ នៅក្នុងសង្កាត់មានសិប្បកម្មផលិតក្រមា និងគ្រឿងប្រើប្រាស់ជាច្រើនមុខទៀត ។ ផលិតផលទាំងនេះ មានគុណភាព និងមួយចំនួនទៀតបាននាំទៅលក់តាមទីផ្សារនានា ក្នុងទូទាំងប្រទេស។ ទោះបីយ៉ាងណានេះក្តី ក៏នៅមានសិប្បកម្មមួយចំនួនបានផលិតរបស់របរ ខ្វះគុណភាព សមស្របតាមស្តង់ដា និងការធ្វើអាជីវកម្មមួយចំនួនមិនទាន់ប្រើប្រាស់ស្លាកសញ្ញាត្រឹមត្រូវ ការពារអនុគតន្តមក បញ្ហាប្រឈមខាងលើ ដោយសារក្នុងផលិតកម្មមានបច្ចេកទេសទាប ឧបករណ៍ និងសម្ភារៈប្រើប្រាស់មិនទាន់គ្រប់គ្រាន់ និងទំនើប ជាពិសេសការយល់ដឹងរបស់ម្ចាស់សិប្បកម្ម នៅមានកម្រិត និងមិនគោរពទៅតាមច្បាប់ ស្តីពីការគ្រប់គ្រងសិប្បកម្ម ។

•ការងារទេសចរណ៍៖ អាជីវកម្ម សេវាកម្ម ក្នុងវិស័យទេសចរណ៍ មានការកើនឡើង ជាពិសេសម្ចាស់អាជីវកម្មមួយចំនួនមានការយល់ដឹង និងបានពង្រឹងគុណភាពសេវាកម្ម បានផ្តល់ផាសុកភាពជូនភ្ញៀវ ដើម្បីបានចូលរួមក្នុងការប្រកួតប្រជែង ទីក្រុងស្អាត របៀបភោជនីយដ្ឋានស្អាត សេវាល្អ ដែលជាខ្សែ... ស្របតាមគោលនយោបាយ ក្នុងចំណោមខេត្តក្រុងទាំង២៥ ។ តែក៏នៅមានចំណុចមួយចំនួនប្រកបអាជីវកម្ម ដោយគ្មានអាជ្ញាប័ណ្ណ ភាគច្រើនអាជីវកម្មភោជនីយដ្ឋាន គ្មានអនាម័យ គ្មានចំណតយានយន្តត្រឹមត្រូវ បានបង្កការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងមួយចំនួនទៀតមិនសូវយកចិត្តទុកដាក់លើការ ការពារសន្តិសុខ សុវត្ថិភាពដល់ភ្ញៀវ និងការតក់ក្រហល់ក្នុងសណ្ឋាគារភ្ញៀវ ។

•ការងារប្រមូលទិន្នន័យ៖ ការរៀបចំប្រមូលទិន្នន័យភូមិ សង្កាត់ គឺជាស្ថិតិដែលតំណាងឲ្យ ... ជាជាដែលមាននៅភូមិសង្កាត់ ជារៀងរាល់ឆ្នាំគ្រប់ភូមិទាំង០៨ និងថ្នាក់សង្កាត់ ត្រូវបានចងក្រងរៀបចំប្រមូលទិន្នន័យភូមិ សង្កាត់បានត្រឹមត្រូវមានសុក្រឹតភាព ទៅតាមការណែនាំរបស់មន្ទីរផែនការខេត្ត ទាំងស្រុង និងចងក្រងបានជាសៀវភៅទិន្នន័យភូមិ ទិន្នន័យសង្កាត់ សម្រាប់ជាមូលដ្ឋាន ក្នុងការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ ឃុំសង្កាត់ និងពង្រាយទៅធ្វើសាធារណកម្មដែនការសង្កាត់នៅថ្នាក់ខេត្ត ជារៀងរាល់ឆ្នាំ ។

ទោះជាយ៉ាងនេះក្តី ក៏ការប្រមូលចងក្រងទិន្នន័យភូមិ សង្កាត់ ក៏នៅមិនទាន់បានគ្រប់គ្រាន់ ប្រាកដត្រឹមត្រូវ ១០០% នៅឡើយ ដែលធ្វើឲ្យការរៀបចំផែនការអភិវឌ្ឍន៍ របស់សង្កាត់នៅមិនទាន់បាន គ្រប់ជ្រុងជ្រោយ ហេតុនេះត្រូវមានការបណ្តុះបណ្តាល និងការកែលម្អបន្ថែមទៀត ។

### ១.២.២ ផ្នែកសង្គមកិច្ច

•ការងារអប់រំយុវជន និងកីឡា ៖ នៅក្នុងសង្កាត់មានសាលាបឋមសិក្សា ៤ កន្លែង អនុវិទ្យាល័យ ០១ កន្លែង និងមានសាលាឯកជនជាច្រើនកន្លែងទៀត ដែលបង្កលក្ខណៈងាយស្រួលដល់ការសិក្សា របស់សិស្សានុសិស្សឲ្យទទួលបាននូវការអប់រំប្រកបដោយសមធម៌ ។ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ធ្វើ អប់រំ គ្រប់ក្រសួងតែងខិតខំប្រឹងប្រែងលើកស្ទួយគ្រប់ការងារទាំងអស់ ដើម្បីឆ្លើយតបទៅនឹងគោលនយោបាយ ... និងប្រសិទ្ធភាពនៅឆ្នាំ ២០២២ ។ ផ្អែកតាមលទ្ធផលជាក់ស្តែងក្នុងឆ្នាំ ២០១៨ បានបង្ហាញថា៖ -កុមារក្នុងវ័យមត្តេយ្យ(អាយុ៥ឆ្នាំ)បានចូលរៀន ៧៦,៣៥%

-កុមារដល់វ័យ(អាយុ៦ ឆ្នាំ) បានចូលរៀន ៩៩%

-កុមារក្នុងវ័យបឋមសិក្សា (៦ដល់១១ឆ្នាំ) បានចូលរៀន ៩៩%

-កុមារអាយុ ១២ ដល់១៤ឆ្នាំ បានចូលរៀន ៩៣%

ពិតមែនតែលទ្ធផលជាក់ស្តែងខាងលើបានបង្ហាញនូវការរីកចំរើនលើសបណ្តាលឆ្នាំកន្លងទៅ ប៉ុន្តែមិនទាន់ឆ្លើយតបទៅនឹងចំណុចដៅរបស់ថ្នាក់ជាតិនៅឡើយ ដោយនៅមានបញ្ហាប្រឈម មួយចំនួនដែលជារបសគ្គក្នុងការអនុវត្ត ដូចជា ៖ កម្រិតជីវភាពប្រជាពលរដ្ឋមួយចំនួន ជួបការ លំបាក តម្រូវការកំលាំងកូនជួយការងារក្នុងផ្ទះ ជួយប្រកបរបរ ទ្រទ្រង់ជីវភាពគ្រួសារ (លក់ការសែត , ដើរលក់របស់របរតាមបណ្តោយពេលយប់, ដើររើសកាកសំណល់.)

ការគ្រប់គ្រងស្ថិតិកុមារ(០ដល់១៧ឆ្នាំ) តាមកម្រិតអាយុនៅមិនទាន់ច្បាស់លាស់ អនក្ខជន មានស្ថិតិតែរកមនុស្សមិនឃើញ ។ ក្នុងសង្កាត់មានតែសាលាបឋមសិក្សា០៤ កន្លែង មិនទាន់សមាមាត្រនឹងចំនួនសិស្ស សម្ភារៈបរិក្ខាចាំបាច់ ( អាគារ ទីធ្លា បង្គន់ កន្លែងលាងដៃ តុ កៅអី ) មិនទាន់គ្រប់គ្រាន់ ។ បញ្ហាប្រឈមទាំងអស់នេះបន្តស្ថិតនៅជាការលំបាកក្នុងការអនុវត្តន៍ នូវគោលនយោបាយរបស់ថ្នាក់ជាតិ ៣ ចំណុចសំខាន់ៗគឺ ៖

១-ការប្រមូលកុមារចូលរៀនប្រកបដោយសមធម៌

២-ការពង្រឹងគុណភាព និងប្រសិទ្ធភាពអប់រំ

៣-ការអភិវឌ្ឍន៍សមត្ថភាព និងស្ថាប័ន

ដែលទាមទារប្រមូលគ្រប់ធនធាន ទាំងធនធានមនុស្ស ថវិកា សម្ភារៈទើបអាចដោះស្រាយ បញ្ហាបានដោយជោគជ័យ ។

**+ការងារសុខាភិបាល** ៖ នៅក្នុងសង្កាត់ មានមណ្ឌលសុខភាព១កន្លែង និងមានគ្លីនិកឯកជនឱសថស្ថានរង បន្ទប់ពិគ្រោះព្យាបាល រួមទាំងវេជ្ជបណ្ឌិត ទន្តបណ្ឌិត គ្រូពេទ្យ ឱសថការី គិលានុបដ្ឋាកពេទ្យឆ្មប ដៃគូរអភិវឌ្ឍន៍នានា និងទទួលបានសេវាកម្មជាតិលើកកម្ពស់សុខភាព រៀងរាល់ឆ្នាំ និងបានផ្តល់ជាបំណ្ណមូលនិធិសមធម៌ ។ ទោះបីយ៉ាងនេះក្តី ក៏មានប្រជាពលរដ្ឋមួយចំនួនតូច មិនយកកូនទៅទៅចាក់ ថ្នាំបង្ការ និងមិនយកចិត្តទុកដាក់ថែទាំសុខភាព និងបង្ការជំងឺឆ្លងផ្សេងៗ ។ ស្ត្រីមួយចំនួនតូចមិន ទៅទទួលយកសេវាសុខភាពបន្តពូជ ដោយនៅមានការអៀនខ្មាស់ ពិសេសតាមសហគមន៍ ក្រីក្រនិងសំណង់មិនរៀបរយ ។ បន្ទប់ពិគ្រោះព្យាបាលជម្ងឺ និងឱសថស្ថានមួយចំនួនគ្មានច្បាប់ អនុញ្ញាតត្រឹមត្រូវនិង នៅមានចរាចរឱសថក្លែងក្លាយ ឱសថហួសកាលកំណត់ប្រើប្រាស់តាម បណ្តាឱសថស្ថាន ឱសថស្ថានរងមួយចំនួនតូច ។

**+ការងារសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ៖** ក្នុងសង្កាត់មានសមាគមមនុស្សចាស់១ និងអង្គការមួយចំនួនដែលបានគ្រប់គ្រងស្ថិតិច្បាស់លាស់។ មានប្រជាពលរដ្ឋរស់នៅសំណង់មិនរៀបរយមួយចំនួន ដែលប្រមូលផ្តុំទៅដោយអ្នកមានជីវភាព ក្រីក្រ ខ្វះចំណេះដឹង ធ្វើឲ្យការរស់នៅរបស់ពួកគាត់ជួយការលំបាក មុខរបររកកំរៃមិនតុល្យភាពនឹងចំណាយសំរាប់ផ្គត់ផ្គង់ជីវភាពរស់នៅប្រចាំថ្ងៃ ។ សង្កាត់បានខិតខំទំនាក់ទំនងជាមួយដៃគូរអភិវឌ្ឍន៍នានា ដើម្បីជួយផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈ ផ្តល់ឥនទាណសាច់ប្រាក់ និងផ្តល់មូល និធិមួយចំនួនឲ្យពួកគាត់ខ្ចី ដោយបង់រំលោះសំរាប់ពង្រីកមុខរបរ និងកាត់បន្ថយភាពក្រីក្រ ។

**+ការងារយេនឌ័រ** ៖ ក្នុងបរិបទស្ត្រីជាឆ្អឹងខ្នងនៃការអភិវឌ្ឍន៍ភាពរីកចំរើនរបស់សង្គមជាតិ បច្ចុប្បន្នតួនាទីស្ត្រីត្រូវបានលើកកម្ពស់ក្នុងគ្រប់រចនាសម្ព័ន្ធសង្គមទាំងមូល ពីថ្នាក់ជាតិ រហូតដល់ថ្នាក់មូលដ្ឋានភូមិ/សង្កាត់ ។

+**ការងារគ្រប់គ្រងកាកសំណល់រឹងរាវ ៖** ដោយសារសង្កាត់ ស្ថិតនៅជាប់មាត់ទន្លេមេគង្គបេតុនេះផលប៉ះពាល់អាចកើតមានឡើងដល់បរិស្ថាន គឺ ការបង្ហូរកាកសំណល់ រឹង រាវ មានជាតិគីមីចូលទៅក្នុងទន្លេ ដែលមានជាតិពុលពីមួយឆ្នាំទៅមួយឆ្នាំ ប៉ះពាល់សុខភាពប្រជាពលរដ្ឋ ដែលទាមទារការអប់រំផ្សព្វផ្សាយឲ្យបានទូលំទូលាយថែមទៀត ជាពិសេសបញ្ហាសំរាមដែលកកស្ទះមុខលំនៅដ្ឋានរបស់ប្រជាពលរដ្ឋ និងរាយប៉ាយរថយន្តចូល មិនរួចផ្លូវតូចចង្អៀត មិនទាន់យល់ដឹងពីវិធីវេចខ្ចប់សំរាម នៅមានទំលាប់ចោលសំរាមផ្តេសផ្តាស ម្យ៉ាងក្រុមហ៊ុនមិនសូវយកចិត្តទុកដាក់ប្រមូលឲ្យបានទាន់ពេលវេលាកំណត់ ។

+**ការងារលូបង្ហូរទឹកស្អុយ ៖** ចំពោះប្រព័ន្ធលូបង្ហូរទឹកស្អុយ ថ្វីត្បិតតែមិនទាន់បានស្តាបនាពិតមែនតែនឹងខិតខំតៀងតរប្រភពថវិកា ដើម្បីកសាងថ្មីឲ្យឆ្លើយតបទៅនឹងតម្រូវការនិងស្ថានភាពជាក់ស្តែង នៃកំណើនប្រជាពលរដ្ឋក្នុងមូលដ្ឋាន ដែលក្នុងនោះត្រូវទាមទារការស្តាបនាប្រព័ន្ធលូថ្មីៗ ។

+**ការងារគ្រប់គ្រងគ្រោះមហន្តរាយ ៖** សង្កាត់មានគណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់សង្កាត់ ដែលដឹកនាំអំពីការ បង្ការទប់ស្កាត់គ្រោះអគ្គីភ័យ និងគ្រោះទឹកជំនន់ ។ សង្កាត់បានធ្វើការ[illegible]ដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋានឲ្យយល់ដឹង និងចេះប្រុងប្រយត្ន័ជាប្រចាំ ។

ដោយមានការសហការពីអង្គការដៃគូនានា បានជួយឧបត្ថម្ភ និងគាំទ្រជួយបណ្តុះបណ្តាលដល់ថ្នាក់ភូមិ និងប្រជាពលរដ្ឋ ។ ទោះបីមានការខិតខំយ៉ាងដូចនេះក្តី សង្កាត់កំនៅ ជួបប្រទះនូវគ្រោះអគ្គីភ័យ និងគ្រោះទឹកជំនន់ បណ្តាលឲ្យឆេះផ្ទះ និងបាក់ច្រាំងទន្លេរៀងរាល់ឆ្នាំ ប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងខូចខាតហេដ្ឋារចនាសម្ព័ន្ធមួយចំនួន។

**១.២.៤ ផ្នែករដ្ឋបាល និងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ៖**

សង្កាត់បានអនុវត្តការងារក្រោមច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់ ក្នុងនោះសង្កាត់មានគណៈបញ្ជាការឯកភាពសង្កាត់ ដែលបាននឹងកំពុងអនុវត្តគោលនយោបាយភូមិសង្កាត់មានសុវត្ថិភាពធានាបាននូវលក្ខណៈ សម្បត្តិ ៨ យ៉ាង ៖ គ្មានសកម្មភាព លួច ឆក់ ប្លន់ គ្រប់ប្រភេទ គ្មានការផលិតចែកចាយ និងប្រើប្រាស់គ្រឿងញៀនខុសច្បាប់ គ្មានអំពើអនាចារ ការជួញដូរស្ត្រី និងកុមារ គ្មានអំពើហឹង្សាក្នុងគ្រួសារ គ្មានក្មេងទំនើង គ្មានការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ គ្មានការប្រើប្រាស់[illegible]ជាតិផ្ទុះខុសច្បាប់ និងបទល្មើសគ្រប់ ប្រភេទ ។ សង្កាត់ កំពុងគ្រប់គ្រងអនុវត្តការងាររបស់ខ្លួនជាប្រចាំ ។ ប៉ុន្តែបញ្ហាប្រឈមនៅតែ កើតមាន ដែលតម្រូវឲ្យសង្កាត់យកចិត្តទុកដាក់ និងដោះស្រាយជាបណ្តើរៗដូចជា ៖ ការលួច ឆក់ ប្លន់ ការគំរាមកំហែង ការប្រើប្រាស់គ្រឿងញៀន ការផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ជូនប្រជាពលរដ្ឋ ការគ្រប់គ្រងអ្នកស្នាក់នៅបណ្តោះអាសន្ន អំពើហឹង្សាក្នុងគ្រួសារ ក្មេងទំនើង ល្បែងស៊ីសង សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ សមត្ថភាពមន្ត្រីរាជការ ការចុះបញ្ជីអត្រានុកូលដ្ឋាន និងការផ្តល់សេវាផ្សេងៗ ដើម្បីធានានូវសន្តិសុខ សុវត្ថិភាពសង្គម ឆ្លើយតបបាននូវ អភិបាលកិច្ចល្អ ។

**ក.ការងាររដ្ឋបាលដែនដី និងអភិបាលកិច្ច ៖** ដើម្បីធានាការគ្រប់គ្រង និងបំរើសេវាសាធារណៈ ការថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សុវត្ថិភាពសង្គម ជូនដល់ប្រជាជនឲ្យបានល្អប្រសើរក្នុងមូលដ្ឋាន និងយោងលើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់ ដែលប្រកាសឲ្យប្រើ ដោយព្រះរាជក្រមលេខ ន.ស/រ.ក.ម/០៣០១/១៥ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០០១ ជាត្រីវិស័យក្នុងការបំពេញភារៈកិច្ច ។ ក្រុមប្រឹក្សាសង្កាត់ផ្សារថ្មីទី៣ បានយកចិត្តទុកដាក់បំរើប្រជាជនប្រកបដោយប្រសិទ្ធិភាព និងទាន់ពេលវេលានូវរាល់ឯកសារដែលជាតម្រូវការប្រើប្រាស់របស់ប្រជាជន ។ ទោះបីជាមានលក្ខណៈល្អប្រសើរ

ហើយក្តី យើងក៏ពិនិត្យឃើញថា ការកត់ត្រាបញ្ជីអត្រានុកូលដ្ឋាន និងការយល់ដឹងពី អត្ថប្រយោជន៍ នៃឯកសារអត្រានុកូលដ្ឋាន ក៏នៅមានកំរិត ។

ការគ្រប់គ្រងស្ថិតិប្រជាជន ការផ្តល់សៀវភៅស្នាក់នៅ សៀវភៅគ្រួសារ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងឯកសារផ្លាស់ប្តូរទីលំនៅ ឬការបញ្ចូលឈ្មោះសមាជិក ក៏នៅយឺតយ៉ាវមិនទាន់ឆ្លើយតបទៅនឹង តម្រូវការរបស់ប្រជាជនឲ្យបានទាន់ពេលវេលា ។

**ខ.ការពង្រឹងសមត្ថភាព** ក្រុមប្រឹក្សាសង្កាត់ តែងតែទទួលបាននូវការបណ្តុះបណ្តាលជាច្រើន ដើម្បីតម្រង់ទិសក្រុមប្រឹក្សាសង្កាត់ឲ្យអនុវត្តបានត្រឹមត្រូវទៅតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

គណៈកម្មាធិការ គណៈកម្មការ ជនបង្គោលនានា ត្រូវបានរៀបចំឡើងដើម្បីជួយដល់ក្រុមប្រឹក្សាសង្កាត់ ព្រមទាំងបានផ្សព្វផ្សាយពីតួនាទីភារៈកិច្ចរបស់ខ្លួន បានយល់ដឹងត្រឹមត្រូវ ។

ស្មៀន និងមន្ត្រីជំនួយការ ត្រូវបានទទួលនូវការបណ្តុះបណ្តាលជាច្រើន ពីសាលារាជធានី សាលាខណ្ឌ និងក្រុមប្រឹក្សាសង្កាត់ ពីការងាររដ្ឋបាល និងទម្រង់ឯកសាររដ្ឋបាលទៅតាមសារាចរណែនាំរបស់ក្រសួងមហាផ្ទៃស្តីពីកិច្ចការរដ្ឋបាលឃុំ សង្កាត់ ។

មេភូមិ និងជំនួយការមេភូមិក៏ត្រូវបានរៀបចំទៅតាមច្បាប់ និងនីតិវិធីនៃការជ្រើសរើសមេភូមិរបស់ក្រសួងមហាផ្ទៃ និងបានបំពេញតួនាទី ភារៈកិច្ច ទៅតាមច្បាប់បានល្អប្រសើរ ។

ទោះបីជាមានការបើកវគ្គបណ្តុះបណ្តាលខ្លីៗ និងការណែនាំជាច្រើនក្តី ក៏នៅជួបប្រទះការលំបាកមួយចំនួនផងដែរ ដូចជាសមត្ថភាពបំពេញភារៈកិច្ច នៅមិនទាន់បានយល់ និងដូចៗគ្នាដែរទាមទារឲ្យមានការបើកវគ្គបំពាក់បំប៉នបន្ថែមទៀត ដូចជាការកសាងផែនការអភិវឌ្ឍន៍ឃុំសង្កាត់។

**គ.ការធានាសន្តិសុខ** អនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល ពិសេសគឺការអនុវត្តន៍គោលនយោបាយ ភូមិសង្កាត់មានសុវត្ថិភាព និងឆ្លងតាមការរៀបចំវេទិការសាធារណៈពិគ្រោះយោបល់ប្រចាំខែ ធ្វើឲ្យប្រជាជនមានការចូលរួមយ៉ាងសស្រាក់សស្រាំ និងផ្តល់កិច្ចសហការណ៍ផ្តល់ដំណឹង ផ្តល់ពីកង្វល់ជូនដល់គណៈបញ្ជាការឯកភាពសង្កាត់ លើខ្លឹមសារគោលនយោបាយទាំង៥ចំណុច របស់រាជរដ្ឋាភិបាល ។ អំពើល្មើសច្បាប់ទាំងឡាយត្រូវបានបង្ក្រាប បង្ការទប់ស្កាត់បានទាន់ពេលវេលា និងកាត់បន្ថយបានជាអតិបរិមា ។ ទោះបីជាកងកំលាំងនគរបាលសង្កាត់ ប្រជាការពារ កំលាំងសមត្ថកិច្ចថ្នាក់ខណ្ឌ ថ្នាក់រាជធានីនិងការចូលរួមសហការណ៍របស់ប្រជាជនយ៉ាងណាក្តី ក៏សកម្មភាពល្មើសច្បាប់មួយចំនួនក៏នៅមានខ្លះទៀតដែរដូចជាការឆក់ ការចែកចាយ និងការប្រើប្រាស់ថ្នាំញៀនខ្លះៗ ការប្រើអំពើហិង្សា និងល្បែងស៊ីសង ក៏នៅមានសកម្មភាពខ្លះដែរ ដែលទាមទាត្រូវតែជំរុញ និងបង្កើនការបង្កា បង្ក្រាប ទប់ស្កាត់ឲ្យកាន់តែមុះមុតថែមទៀតដើម្បីរួមចំណែកលើកកំពស់សេចក្តីសុខជូនប្រជាជន ។

**ឃ.ការធានាសណ្តាប់ធ្នាប់សាធារណៈ** ៖ ការរៀបចំសណ្តាប់ធ្នាប់សាធារណៈ ក៏បានអនុវត្តន៍ជាប្រចាំ ដោយទន្ទឹមនឹងការអប់រំណែនាំនិងវិធានការណ៍រដ្ឋបាលមួយចំនួន ។

ការលក់ដូរ ក៏នៅមានការលក់ដូរលើចិញ្ចើមផ្លូវចេញចូលនៅឡើយទោះបីជាក្នុងសង្កាត់មានការជូនដំណឹងនិងណែនាំក្នុងការលក់ដូរមួយចំនួន ក៏នៅតែជាបញ្ហាដែលទាមទារត្រូវបន្តអប់រំណែនាំ និងមានវិធានការណ៍រដ្ឋបាលបន្ថែមទៀត ដើម្បីឲ្យសណ្តាប់ធ្នាប់ក្នុងមូលដ្ឋាន មានលក្ខណៈកាន់តែប្រសើរឡើងថែមទៀត ។

# ផ្នែកទី២

## គម្រោង សកម្មភាពនៃកម្មវិធីវិនិយោគ
## បីឆ្នាំរំកិលសង្កាត់

| | | | | | | |
|---|---|---|---|---|---|---|
| ២.៩ | មន្ទីរឧស្សាហកម្ម សិប្បកម្ម | ៩ | ៤,៥០០ | មន្ទីរឧស្សាហកម្ម | ៩ | ៤,៥០០ |
| | | | | ដៃគូអភិវឌ្ឍន៍ | ០ | ០ |
| ២.៦ | មន្ទីរសង្គមកិច្ច | ៥ | ២,៥០០ | មន្ទីរសង្គមកិច្ច | ៥ | ២,៥០០ |
| | | | | ដៃគូអភិវឌ្ឍន៍ | ០ | ០ |
| ២.៧ | មន្ទីរអប់រំ | ១ | ៥០០ | មន្ទីរអប់រំ | ១ | ៥០០ |
| | | | | ដៃគូអភិវឌ្ឍន៍ | ០ | ០ |
| ២.៨ | មន្ទីរកសិកម្ម | ១ | ៥០០ | មន្ទីរកសិកម្ម | ១ | ៥០០ |
| | | | | ដៃគូអភិវឌ្ឍន៍ | ០ | ០ |
| ២.៩ | រដ្ឋបាលខណ្ឌច្បារអំពៅ | ៣២ | ១៦,០០០ | ខណ្ឌច្បារអំពៅ | ៣២ | ១៦,០០០ |
| | | | | ដៃគូអភិវឌ្ឍន៍ | ០ | ០ |
| សរុប | | ៧៥ | ២២៤,២០០ | មន្ទីររដ្ឋបាលខណ្ឌ | ៧៥ | ២២៤,២០០ |
| | | | | ដៃគូអភិវឌ្ឍន៍ | ០ | ០ |
| ៣ | ការគាំទ្រពីអង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធ | | | | | |
| ៣.១ | អង្គការ អ.អ.ស.ស | ១ | ៥០០ | អង្គការ អ.អ.ស.ស | ១ | ៥០០ |
| ៣.២ | អង្គការ CODO | ៤ | ២,០០០ | អង្គការ CODO | ៤ | ២,០០០ |
| ៣.៣ | អង្គការមិត្តសំឡាញ់ | ៤ | ២,០០០ | អង្គការមិត្តសំឡាញ់ | ៤ | ២,០០០ |
| ៣.៤ | អង្គការទស្សនៈពិភពលោក | ៨ | ៤,០០០ | ទស្សនៈពិភពលោក | ៨ | ៤,០០០ |
| ៣.៥ | អង្គការ SCC | ១ | ៥០០ | អង្គការ SCC | ១ | ៥០០ |
| សរុប អង្គការ | | ១៨ | ៩,០០០ | | ១៨ | ៩,០០០ |
| សរុបរួម ( ១+២+៣ ) | | ៩៣ | ២៣៣,២០០ | | ៩៣ | ២៣៣,២០០ |

## ២.២ តារាងគម្រោង សកម្មភាពកំពុងដំណើរការ

| ល.រ | ឈ្មោះគម្រោង | ឆ្លើយតបគោលដៅ | ទីតាំងគម្រោង | លទ្ធផលគ្រោង | | រយៈពេលអនុវត្ត | ប្រភពមូលនិធិ | តំរិតទុនវិនិយោគ(លានរៀល) | | | អង្គភាពអនុវត្ត | កំណត់សម្គាល់ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | បរិមាណ | ឯកតា | | | ២០១៨ | ២០១៩ | ២០២០ | | |
| ១ | ផ្នែកសេដ្ឋកិច្ច | | | | | | | | | | | |
| | គ្មាន | | | | | | | | | | | |
| | | | | | | | | | | | | |
| ២ | ផ្នែកសង្គមកិច្ច | | | | | | | | | | | |
| | គ្មាន | | | | | | | | | | | |
| | | | | | | | | | | | | |
| ៣ | ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ | | | | | | | | | | | |
| | គ្មាន | | | | | | | | | | | |
| | | | | | | | | | | | | |
| ៤ | ផ្នែករដ្ឋបាល និងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ | | | | | | | | | | | |
| | គ្មាន | | | | | | | | | | | |
| | | | | | | | | | | | | |

២.៣ តារាងគម្រោង សកម្មភាពវិនិយោគដែលមានថវិកាគាំទ្រ

| ល.រ | ឈ្មោះគម្រោង | ទីតាំងគម្រោង | លទ្ធផលគ្រោង | | រយៈពេលអនុវត្ត | តម្លៃ (ពាន់រៀល) | ប្រភពមូលនិធិ | គំរិតទុនយោគ(ពាន់រៀល) | | | | អង្គភាពអនុវត្ត |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | បរិមាណ | ឯកតា | | | | ២០១៨ | ២០១៩ | ២០២០ | សរុប | |
| **ក-គម្រោង សកម្មភាពប្រើប្រាស់មូលនិធិសង្កាត់** | | | | | | | | | | | | |
| **I-ផ្នែកសេដ្ឋកិច្ច** | | | | | | | | | | | | |
| ១ | ជួសជុលចាក់ថ្នូរបេតុងគ្មានសរសៃដែក ប្រវែង ៦៥ម ទទឹង ៤ម | ព្រោយអំពិល | ១ | ខ្សែ | ១ឆ្នាំ | 22,880 | សង្កាត់ | 22,880 | - | - | 22,880 | សង្កាត់ |
| ២ | ជួសជុលចាក់ថ្នូរបេតុងគ្មានសរសៃដែក ប្រវែង ១៤៦ម ទទឹង ៤ម | ព្រែកធំ២ | ១ | ខ្សែ | ១ឆ្នាំ | 51,392 | សង្កាត់ | 51,392 | - | - | 51,392 | សង្កាត់ |
| ៣ | ជួសជុលចាក់ថ្នូរបេតុងគ្មានសរសៃដែក ប្រវែង ១៧៦ម ទទឹង ៤ម និងប្រវែង ៧៣ម ទទឹង ៣ម | ព្រែកធំ១ | ២ | ខ្សែ | ១ឆ្នាំ | 81,224 | សង្កាត់ | 81,224 | - | - | 81,224 | សង្កាត់ |
| **II-ផ្នែកសង្គមកិច្ច** | | | | | | | | | | | | |
| ១ | គ្មាន | | | | | | | | | | | |
| **III-ផ្នែកធនធានធម្មជាតិ បរិស្ថាន និងបន្សាំនឹងការប្រែប្រួលអាកាសធាតុ** | | | | | | | | | | | | |
| ១ | ដាក់លូមូលដោះទឹកធំហំ ០,៦០ម ប្រវែង ១៣៥ ម | ព្រែកធំ១ | ១ | ខ្សែ | ១ឆ្នាំ | 34,000 | សង្កាត់ | 34,000 | - | - | 34,000 | សង្កាត់ |
| **IV-ផ្នែករដ្ឋបាល និងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ** | | | | | | | | | | | | |
| ១ | គ្មាន | | | | | | | | | | | |

## ខ-អនុវត្ត សកម្មភាពមានការគាំទ្រមូលនិធិពីមន្ទីរ ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធ

### I-ផ្នែកសេដ្ឋកិច្ច

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ១ | ប្រមូល ចងក្រងទិន្នន័យភូមិ សង្កាត់ | សង្កាត់ | ១ | វគ្គ | ១ឆ្នាំ | 500 | ម.ផែនការ | 500 | - | - | 500 | ម.ផែនការ |
| ២ | សិក្ខាសាលាសមាហរណកម្មផែនការ | សាលាខណ្ឌ | ១ | លើក | ១ឆ្នាំ | 500 | ម.ផែនការ | 500 | - | - | 500 | ម.ផែនការ |
| ៣ | ផ្សព្វផ្សាយច្បាប់ទេសចរណ៍ | សាលាខណ្ឌ | ១ | វគ្គ | ១ឆ្នាំ | 500 | ម.ទេសចរណ៍ | 500 | - | - | 500 | ម.ទេសចរណ៍ |
| ៤ | ផ្សព្វផ្សាយចលនាប្រឡងប្រណាំងទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ | សាលាខណ្ឌ | ១ | វគ្គ | ១ឆ្នាំ | 500 | ម.ទេសចរណ៍ | 500 | - | - | 500 | ម.ទេសចរណ៍ |
| ៥ | វគ្គបណ្តុះបណ្តាលបដិសណ្ឋារកិច្ច | សាលាខណ្ឌ | ១ | វគ្គ | ១ឆ្នាំ | 500 | ម.ទេសចរណ៍ | 500 | - | - | 500 | ម.ទេសចរណ៍ |
| ៦ | វគ្គបញ្ច្រាបយេនឌ័រក្នុងវិស័យទេសចរណ៍ | សាលាខណ្ឌ | ១ | វគ្គ | ១ឆ្នាំ | 500 | ម.ទេសចរណ៍ | 500 | - | - | 500 | ម.ទេសចរណ៍ |
| ៧ | វគ្គបច្ចេកទេសដាំបន្លែ | សាលាខណ្ឌ | ១ | វគ្គ | ១ឆ្នាំ | 500 | ម.កសិកម្ម | 500 | - | - | 500 | ម.កសិកម្ម |
| ៨ | វគ្គបណ្តុះបណ្តាលបច្ចេកទេសប្រើប្រាស់ថ្នាំកសិកម្ម | សាលាខណ្ឌ | ១ | វគ្គ | ១ឆ្នាំ | 500 | ម.កសិកម្ម | 500 | - | - | 500 | ម.កសិកម្ម |
| ៩ | ផ្តល់ការចាក់វ៉ាក់សាំងសត្វ | សាលាខណ្ឌ | ២ | លើក | ១ឆ្នាំ | 500 | ម.កសិកម្ម | 500 | - | - | 500 | ម.កសិកម្ម |
| ១០ | ផ្តល់ការដាំកូនឈើ | សង្កាត់ | ២ | លើក | ១ឆ្នាំ | 500 | ម.កសិកម្ម | 500 | - | - | 500 | ម.កសិកម្ម |
| ១១ | ជួសជុលនិងថែទាំរថយន្ត | ទ.ពិភពលោក | ១ | វគ្គ | ១ឆ្នាំ | 500 | ទ.ពិភពលោក | 500 | - | - | 500 | ទ.ពិភពលោក |
| ១២ | ជួសជុលម៉ាស៊ីនត្រជាក់ | ទ.ពិភពលោក | ១ | វគ្គ | ១ឆ្នាំ | 500 | ទ.ពិភពលោក | 500 | - | - | 500 | ទ.ពិភពលោក |
| ១៣ | ជួសជុលជណ្តើរយន្ត | ទ.ពិភពលោក | ១ | វគ្គ | ១ឆ្នាំ | 500 | ទ.ពិភពលោក | 500 | - | - | 500 | ទ.ពិភពលោក |
| ១៤ | តបណ្តាញអគ្គិសនី និងទឹក | ទ.ពិភពលោក | ១ | វគ្គ | ១ឆ្នាំ | 500 | ទ.ពិភពលោក | 500 | - | - | 500 | ទ.ពិភពលោក |
| ១៥ | ជំនាញផ្សារដែក | ទ.ពិភពលោក | ១ | វគ្គ | ១ឆ្នាំ | 500 | ទ.ពិភពលោក | 500 | - | - | 500 | ទ.ពិភពលោក |
| ១៦ | កម្មវិធីមុខរបរខ្នាតតូច | ទ.ពិភពលោក | ១ | វគ្គ | ១ឆ្នាំ | 500 | ទ.ពិភពលោក | 500 | - | - | 500 | ទ.ពិភពលោក |
| ១៧ | អប់រំបច្ចេកទេសវិជ្ជាជីវៈ | ទ.ពិភពលោក | ១ | វគ្គ | ១ឆ្នាំ | 500 | ទ.ពិភពលោក | 500 | - | - | 500 | ទ.ពិភពលោក |
| ១៨ | វគ្គបណ្តុះបណ្តាលរកជីវកម្មខ្នាតតូច | សង្កាត់ | ១ | វគ្គ | ១ឆ្នាំ | 500 | CO DO | 500 | - | - | 500 | CO DO |

II-វិស័យសង្គមកិច្ច

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ១ | គម្រោងអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំ | ឃ.ភិកពលោក | ១ | វគ្គ | ១ឆ្នាំ | 500 | ឃ.ភិកពលោក | 500 | - | - | 500 | ឃ.ភិកពលោក |
| ២ | ជួយបុណ្យសពអ្នកក្រីក្រ | សង្កាត់ | ៥ | នាក់ | ១ឆ្នាំ | 500 | SCC | 500 | - | - | 500 | SCC |
| ៣ | ផ្សព្វផ្សាយ/ជំរុញឪពុកម្ដាយនាំកូនចូលរៀន | សង្កាត់ | ១ | លើក | ១ឆ្នាំ | 500 | ម.អប់រំ | 500 | - | - | 500 | ម.អប់រំ |
| ៤ | ស្រង់ស្ថិតិជនពិការក្រីក្រតាមសហគមន៍ | សង្កាត់ | ១ | លើក | ១ឆ្នាំ | 500 | ម.សង្គមកិច្ច | 500 | - | - | 500 | ម.សង្គមកិច្ច |
| ៥ | គាំពារសង្គ្រោះកុមារកំព្រា | សង្កាត់ | ១ | លើក | ១ឆ្នាំ | 500 | ម.សង្គមកិច្ច | 500 | - | - | 500 | ម.សង្គមកិច្ច |
| ៦ | លុបបំបាត់/កាត់បន្ថយការកេងប្រវ័ញ្ចពលកម្មកុមារ | សង្កាត់ | ១ | លើក | ១ឆ្នាំ | 500 | ម.សង្គមកិច្ច | 500 | - | - | 500 | ម.សង្គមកិច្ច |
| ៧ | បង្កើត/គាំទ្រសមាគមមនុស្សចាស់ | សង្កាត់ | ១ | លើក | ១ឆ្នាំ | 500 | ម.សង្គមកិច្ច | 500 | - | - | 500 | ម.សង្គមកិច្ច |
| ៨ | គាំពារក្រុមជនងាយរងគ្រោះ | សង្កាត់ | ១ | លើក | ១ឆ្នាំ | 500 | ម.សង្គមកិច្ច | 500 | - | - | 500 | ម.សង្គមកិច្ច |
| ៩ | វេទិកាសុខុមាលភាព និងយុវត្តិ ស្ដីពីការអប់រំសុខភាព និងមេរោគអេដស៍ | សង្កាត់ | ១ | វគ្គ | ១ឆ្នាំ | 500 | ម.កិច្ចការនារី | 500 | - | - | 500 | ម.កិច្ចការនារី |
| ១០ | អប់រំក្រៅប្រព័ន្ធ(បញ្ជូនសិស្សទៅកាន់សាលារដ្ឋ ) | សង្កាត់ | ១ | លើក | ១ឆ្នាំ | 500 | អ.មិត្តសំឡាញ់ | 500 | - | - | 500 | អ.មិត្តសំឡាញ់ |
| ១១ | បន្តគាំទ្រសម្ភារៈសិក្សាដល់សិស្សក្រីក្រ | សង្កាត់ | ១ | លើក | ១ឆ្នាំ | 500 | អ.មិត្តសំឡាញ់ | 500 | - | - | 500 | អ.មិត្តសំឡាញ់ |
| ១២ | ផ្ដល់ការបណ្ដុះបណ្ដាលវិជ្ជាជីវៈ | សង្កាត់ | ១ | លើក | ១ឆ្នាំ | 500 | អ.មិត្តសំឡាញ់ | 500 | - | - | 500 | អ.មិត្តសំឡាញ់ |
| ១៣ | គាំទ្រយុវជន/អាណាព្យាបាលទៅរកការងារ និងអាជីវកម្ម | សង្កាត់ | ១ | លើក | ១ឆ្នាំ | 500 | អ.មិត្តសំឡាញ់ | 500 | - | - | 500 | អ.មិត្តសំឡាញ់ |
| ១៤ | ផ្សព្វផ្សាយពីសិទ្ធិ និងយន្តការការពារកុមារ | សង្កាត់ | ១ | វគ្គ | ១ឆ្នាំ | 500 | CO DO | 500 | - | - | 500 | CO DO |
| ១៥ | អប់រំក្រៅប្រព័ន្ធ | សង្កាត់ | ១ | វគ្គ | ១ឆ្នាំ | 500 | CO DO | 500 | - | - | 500 | CO DO |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ១៦ | ការផ្សព្វផ្សាយពីផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងញៀន | សង្កាត់ | ១ | លើក | ១ឆ្នាំ | 500 | អ.អ.ស.ស | 500 | - | - | 500 | អ.អ.ស.ស |
| ១៧ | វគ្គអប់រំចំណេះដឹងជម្ងឺអេដស៍ | សង្កាត់ | ១ | វគ្គ | ១ឆ្នាំ | 500 | ម.សុខាភិបាល | 500 | - | - | 500 | ម.សុខាភិបាល |
| ១៨ | ទិវាអេដស៍ | សង្កាត់ | ១ | លើក | ១ឆ្នាំ | 500 | ម.សុខាភិបាល | 500 | - | - | 500 | ម.សុខាភិបាល |
| ១៩ | ចុះដាក់ថ្នាំអាបែតក្នុងទឹកពាងតាមផ្ទះ | សង្កាត់ | ១ | លើក | ១ឆ្នាំ | 500 | ម.សុខាភិបាល | 500 | - | - | 500 | ម.សុខាភិបាល |
| ២០ | អប់រំចំណេះដឹងជម្ងឺគ្រុនឈាមនិងវិធានការការពារ | សង្កាត់ | ១ | លើក | ១ឆ្នាំ | 500 | ម.សុខាភិបាល | 500 | - | - | 500 | ម.សុខាភិបាល |
| ២១ | យុទ្ធនាការបាញ់ថ្នាំមូស ការការពារជម្ងឺគ្រុនឈាមក្នុងភូមិ | សង្កាត់ | ១ | លើក | ១ឆ្នាំ | 500 | ម.សុខាភិបាល | 500 | - | - | 500 | ម.សុខាភិបាល |
| ២២ | អប់រំចំណេះដឹងអំពីជម្ងឺឆ្លង និងវិធានការការពារ | សង្កាត់ | ១ | លើក | ១ឆ្នាំ | 500 | ម.សុខាភិបាល | 500 | - | - | 500 | ម.សុខាភិបាល |
| ២៣ | អប់រំចំណេះដឹងពីអនាម័យសុវត្ថិភាពចំណីអាហារ | សង្កាត់ | ១ | លើក | ១ឆ្នាំ | 500 | ម.សុខាភិបាល | 500 | - | - | 500 | ម.សុខាភិបាល |
| ២៤ | អប់រំសុខភាព ដើម្បីកាត់បន្ថយការជក់បារី | សង្កាត់ | ១ | លើក | ១ឆ្នាំ | 500 | ម.សុខាភិបាល | 500 | - | - | 500 | ម.សុខាភិបាល |
| ២៥ | កម្មវិធីពន្យាលកំណើត | សង្កាត់ | ១ | លើក | ១ឆ្នាំ | 500 | ម.សុខាភិបាល | 500 | - | - | 500 | ម.សុខាភិបាល |
| ២៦ | ផ្តល់វ៉ាក់សាំងដល់ស្រ្តី និងកុមារ | សង្កាត់ | ១ | លើក | ១ឆ្នាំ | 500 | ម.សុខាភិបាល | 500 | - | - | 500 | ម.សុខាភិបាល |
| ២៧ | ផ្តល់ថ្នាំទម្លាក់ព្រូននិងអប់រំសុខភាពដល់កុមារ | សង្កាត់ | ១ | លើក | ១ឆ្នាំ | 500 | ម.សុខាភិបាល | 500 | - | - | 500 | ម.សុខាភិបាល |
| ២៨ | ផ្តល់សេវាពិគ្រោះ និងពិនិត្យព្យាបាលជម្ងឺជូនដល់ប្រជាពលរដ្ឋក្រីក្រ | សង្កាត់ | ១ | លើក | ១ឆ្នាំ | 500 | ម.សុខាភិបាល | 500 | - | - | 500 | ម.សុខាភិបាល |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ២៩ | ការចុះស្រង់ស្ថិតិ និងឧបត្ថម្ភជនពិការ | សង្កាត់ | ១ | លើក | ១ឆ្នាំ | 500 | សាលាសង្កាត់ | 500 | - | - | 500 | សាលាសង្កាត់ |
| ៣០ | បង្កើត/គាំទ្រដំណើរការសមាគមមនុស្សចាស់ | សង្កាត់ | ១២ | លើក | ១ឆ្នាំ | 500 | សាលាសង្កាត់ | 500 | - | - | 500 | សាលាសង្កាត់ |
| ៣១ | ការពារក្រុមជនងាយរងគ្រោះ | សង្កាត់ | ១ | លើក | ១ឆ្នាំ | 500 | សាលាសង្កាត់ | 500 | - | - | 500 | សាលាសង្កាត់ |
| III-ផ្នែកធនធានធម្មជាតិ បរិស្ថាន និងបន្សាំនឹងការប្រែប្រួលអាកាសធាតុ | | | | | | | | | | | | |
| ១ | កសាងចំណុចផ្សព្វផ្សាយបរិស្ថាន | សង្កាត់ | ៣ | ផ្ទាំង | ១ឆ្នាំ | 1,500 | សង្កាត់ | 1,500 | - | - | 1,500 | ម.បរិស្ថាន |
| ២ | គាំទ្រដំណើរការកាត់បន្ថយគ្រោះមហន្តរាយ | សង្កាត់ | ១ | លើក | ១ឆ្នាំ | 500 | សាលាសង្កាត់ | 500 | - | - | 500 | សាលាសង្កាត់ |
| ៣ | អប់រំពីការគ្រប់គ្រងកាកសំណល់ | សង្កាត់ | ១ | លើក | ១ឆ្នាំ | 500 | សាលាសង្កាត់ | 500 | - | - | 500 | សាលាសង្កាត់ |
| ៤ | វិធានការគ្រប់គ្រងកាកសំណល់ | សង្កាត់ | ១ | លើក | ១ឆ្នាំ | 500 | សាលាសង្កាត់ | 500 | - | - | 500 | សាលាសង្កាត់ |
| IV-ផ្នែករដ្ឋបាល និងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ | | | | | | | | | | | | |
| ១ | រៀបចំកិច្ចប្រជុំជាមួយអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារ | សង្កាត់ | ១២ | លើក | ១ឆ្នាំ | 500 | ម.កិច្ចការនារី | 500 | - | - | 500 | ម.កិច្ចការនារី |
| ២ | ប្រជុំ/សិក្ខាសាលាជាមួយថ្នាក់ដឹកនាំដើម្បីស្វែងរកការគាំទ្រមតិ | ខណ្ឌ | ៣ | លើក | ១ឆ្នាំ | 500 | ម.កិច្ចការនារី | 500 | - | - | 500 | ម.កិច្ចការនារី |
| ៣ | រៀបចំកិច្ចប្រជុំជាមួយមន្ត្រីបង្គោលយេនឌ័រថ្នាក់ខណ្ឌ | ខណ្ឌ | ៣ | លើក | ១ឆ្នាំ | 500 | ម.កិច្ចការនារី | 500 | - | - | 500 | ម.កិច្ចការនារី |
| ៤ | រៀបចំវេទិកាសហគមន៍ ស្តីពីការលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី | ខណ្ឌ | ១ | លើក | ១ឆ្នាំ | 500 | ម.កិច្ចការនារី | 500 | - | - | 500 | ម.កិច្ចការនារី |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ៥ | ពង្រឹងសមត្ថភាពស្ត្រីជាថ្នាក់ដឹកនាំ ភូមិ សង្កាត់ ខណ្ឌ | ខណ្ឌ | ១ | លើក | ១ឆ្នាំ | 500 | ម.កិច្ចការនារី | 500 | - | - | 500 | ម.កិច្ចការនារី |
| ៦ | វេទិកាអប់រំផ្សព្វផ្សាយទំនៀមទម្លាប់ ប្រពៃណីតម្លៃស្ត្រី និងគ្រួសារខ្មែរ | សង្កាត់ | ១ | លើក | ១ឆ្នាំ | 500 | ម.កិច្ចការនារី | 500 | - | - | 500 | ម.កិច្ចការនារី |
| ៧ | ផ្សព្វផ្សាយសុខភាពផ្លូវចិត្ត និងគោរពសិទ្ធិមនុស្ស | សង្កាត់ | ១ | លើក | ១ឆ្នាំ | 500 | ម.កិច្ចការនារី | 500 | - | - | 500 | ម.កិច្ចការនារី |
| ៨ | ផ្សព្វផ្សាយច្បាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ការជួញដូរស្ត្រី កុមារ និងការរំលោភសេពសន្ថវៈ | សង្កាត់ | ១ | លើក | ១ឆ្នាំ | 500 | ម.កិច្ចការនារី | 500 | - | - | 500 | ម.កិច្ចការនារី |
| ៩ | ចុះស្រង់ស្ថិតិ/ជំរុញការចុះបញ្ជី និងផ្សព្វផ្សាយច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម | សង្កាត់ | ១ | លើក | ១ឆ្នាំ | 500 | ម.ឧស្សាហកម្ម | 500 | - | - | 500 | ម.ឧស្សាហកម្ម |
| ១០ | ពង្រឹងការតាមដានត្រួតពិនិត្យជាប្រចាំលើផលិតផលឧស្សាហកម្ម សិប្បកម្ម ដើម្បីធានាគុណភាព និងបរិមាណ | សង្កាត់ | ១ | លើក | ១ឆ្នាំ | 500 | ម.ឧស្សាហកម្ម | 500 | - | - | 500 | ម.ឧស្សាហកម្ម |
| ១១ | បណ្តុះបណ្តាលឧស្សាហករ សិប្បកម្ម ពីការអនុវត្តន៍ផលិតកម្មល្អ( GMP) និងអនាម័យល្អ ( GHP ) | សង្កាត់ | ១ | វគ្គ | ១ឆ្នាំ | 500 | ម.ឧស្សាហកម្ម | 500 | - | - | 500 | ម.ឧស្សាហកម្ម |
| ១២ | ចុះត្រួតពិនិត្យថ្លឹងថ្នាក់ចំណុះតាមស្ថានីយ៍ប្រេងឥន្ធនៈ | សង្កាត់ | ១ | លើក | ១ឆ្នាំ | 500 | ម.ឧស្សាហកម្ម | 500 | - | - | 500 | ម.ឧស្សាហកម្ម |
| ១៣ | ចុះណែនាំម្ចាស់ស្ថានីយ៍ប្រេងឥន្ធនៈ អំពីសុវត្ថិភាពរបស់ស្ថានីយ៍ | សង្កាត់ | ១ | លើក | ១ឆ្នាំ | 500 | ម.ឧស្សាហកម្ម | 500 | - | - | 500 | ម.ឧស្សាហកម្ម |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១៤ | ចុះយកផលិតផលទំនិញវេចខ្ចប់ ពិនិត្យបរិមាណទម្ងន់ និងចំណុះ | សង្កាត់ | ១ | លើក | ១ឆ្នាំ | 500 | ម.ឧស្សាហកម្ម | 500 | - | - | 500 | ម.ឧស្សាហកម្ម |
| ១៥ | សហការចុះត្រួតពិនិត្យជញ្ជីងដែលមានស្ថានភាពក្រោម ១០០០គ.ក្រ | សង្កាត់ | ១ | លើក | ១ឆ្នាំ | 500 | ម.ឧស្សាហកម្ម | 500 | - | - | 500 | ម.ឧស្សាហកម្ម |
| ១៦ | ចុះធ្វើអធិការកិច្ចរោងចក្រ និងសិប្បកម្ម | សង្កាត់ | ១ | លើក | ១ឆ្នាំ | 500 | ម.ឧស្សាហកម្ម | 500 | - | - | 500 | ម.ឧស្សាហកម្ម |
| ១៧ | ជំរុញ/ពង្រឹងកិច្ចការចុះបញ្ជីអត្រានុកូលដ្ឋានគ្រប់ប្រភេទ | សង្កាត់ | ១ | លើក | ១ឆ្នាំ | 500 | សាលាខេត្ត | 500 | - | - | 500 | សាលាខេត្ត |
